

# ទ្រឹស្តីកម្មផល

# The Law of Action and Result

រៀបរៀងដោយ

ឃុន គឹមអៀត

បោះពុម្ពលើកទី១១ សម្រាប់ចែកជាធម្មទាន គ.ស. ២០១៦

# ទ្រឹស្តីកម្មផល

# The Law of Action and Result

រៀបរៀងដោយ

**ឈុន គីមអៀត**

អតីតនិស្សិតអនុបរិញ្ញាបត្រនៃមហាវិទ្យាល័យ
ក្រុងឡុងប៊ីច, រដ្ឋកាលីហ្វ័រនីញ៉ា ស រ អ

ពិនិត្យនិងកែសម្រួលដោយ

ភិក្ខុ វិនយធរោ

មហា **យិន នឿន**

ប្រធានពុទ្ធិកសមាគមខ្មែរទីក្រុងសាន់តាអាណា,
រដ្ឋកាលីហ្វ័រញ៉ា ស រ អ

បណ្ឌិតធម្មាចារ្យ

**ប៊ុត សាវង្ស**

បោះពុម្ពលើកទី១១ចំនួន១០០០០ច្បាប់

*Revised Edition*

សម្រាប់ចែកជាធម្មទាន

រក្សាសិទ្ធិគ្រប់យ៉ាង

ព.ស.២៥៥៩ គ.ស.២០១៦

# មាតិកា

ឧទ្ទិសកថា ....................................................... 5
សេចក្តីថ្លែងអំណរគុណ ....................................................... 6
វាចាអ្នករៀបរៀង ....................................................... 7
អំពីអ្នកនិពន្ធ ....................................................... 9
១. អារម្ភកថា ....................................................... 10
២. សេចក្តីផ្តើម ....................................................... 12
២.១ ព្រហ្មញ្ញសាសនា ....................................................... 14
២.២ ពុទ្ធសាសនា ....................................................... 18
៣. ពុទ្ធប្រវត្តិ ....................................................... 24
៣. ១ បដិសន្ធិ ....................................................... 24
៣.២ ការត្រាស់ដឹង ....................................................... 25
៣.៣ ធម្មទេសនា ....................................................... 28
៣.៤ បរិនិព្វាន ....................................................... 29
៣.៥ ពុទ្ធកាល ....................................................... 30
៤. ព្រះត្រៃបិដក ....................................................... 33
៥. អរិយសច្ច ៤ ....................................................... 37
៥.១ ទុក្ខអរិយសច្ច ....................................................... 37
៥.១.១ ទុក្ខ ១២ កង ....................................................... 37
៥.២ ទុក្ខសមុទយអរិយសច្ច ....................................................... 38
៥.២.១ អវិជ្ជា ....................................................... 39
៥.២.២ តណ្ហា ....................................................... 40
៥.៣ ទុក្ខនិរោធអរិយសច្ច ....................................................... 41
៥.៤ មគ្គអរិយសច្ច ....................................................... 41

៥.៤.១ អដ្ឋង្គិកមគ្គ ....................................................................................42
៦. ទ្រឹស្តីកម្មផល.....................................................................................................47
៦.១ កុសលកម្ម.......................................................................................................50
៦.១.១ កុសលកាយកម្ម ...........................................................................................50
៦.១.២ កុសលវចីកម្ម ...............................................................................................50
៦.១.៣ កុសលមនោកម្ម............................................................................................50
៦.២ អកុសលកម្ម .....................................................................................................51
៦.២.១ អកុសលកាយកម្ម .........................................................................................51
៦.២.២ អកុសលវចីកម្ម.............................................................................................51
៦.២.៣ អកុសលមនោកម្ម..........................................................................................52
៦.៣ អព្យាកតកម្ម......................................................................................................52
៦.៤ អនន្តរិយកម្ម .....................................................................................................52
៦.៥ ទ្រឹស្តីបដិច្ចសមុប្បាទ ..........................................................................................53
៧. ព្រះត្រៃលក្ខណ៍ ...................................................................................................55
៧.១ អនិច្ច...............................................................................................................55
៧.២ ទុក្ខ.................................................................................................................58
៧.៣ អនត្តា ..............................................................................................................59
៨. សំសារៈ............................................................................................................63
៨.១ ជីវិតទាំង ៣ ជាតិ...............................................................................................63
៨.២ កម្ម .................................................................................................................64
៨.៣ មនុស្ស ៤ ពួក ....................................................................................................67
៩. បុណ្យ ................................................................................................................69
៩.១ បសាទៈ .............................................................................................................70
៩.២ សំវេគៈ .............................................................................................................70
៩.៣ តេសុចរិតា .........................................................................................................70

៩.៤ បុញ្ញហេតុ ........ 71
៩.៥ បុញ្ញកិរិយា ........ 71
៩.៦ បុញ្ញផល ........ 72
៩.៧ ការធ្វើបុណ្យ និង ការលាងបាប ........ 72
៩.៨ អានិសង្សបុណ្យ ........ 75
៩.៨.១ អានិសង្សសាធារណៈ ........ 76
៩.៨.២ អានិសង្សសីល ........ 77
៩.៨.៣ សីល ៤ យ៉ាង ........ 77
៩.៨.៤ និច្ចសីល ........ 77
៩.៨.៥ ឧបោសថសីល ........ 78
៩.៨.៦ ទសសីល ........ 79
៩.៨.៧ ចតុប្បារិសុទ្ធិសីល ........ 80
៩.៨.៨ ប្រភេទរបស់សីល ........ 80
៩.៨.៩ អានិសង្សសីល ........ 81
១០. ខ្លួនទីពឹងខ្លួន ........ 85
១០.១ លោកិយបញ្ញា ........ 87
១០.២ លោកុត្តរបញ្ញា ........ 87
១១. ទសបារមី ........ 89
១២. កតញ្ញូកតវេទី ........ 92
១២.១ ព្រះព្រហ្ម ........ 94
១២.២ ព្រះបុព្វទេវា ........ 94
១២.៣ ព្រះបុព្វាចារ្យ ........ 95
១២.៤ ព្រះអាហុនេយ្យៈ ........ 95
១២.៥ ត្រៃបណាម ........ 96
១២.៦ ច្បាប់គោរពមាតាបិតា ........ 97

១៣. ត្រៃសរណគមន៍.....102
១៣.១ ព្រះពុទ្ធ.....103
១៣.១.១ បូជាព្រះពុទ្ធបដិមា.....104
១៣.១.២ អាមិសបូជា.....106
១៣.១.៣ បដិបត្តិបូជា.....107
១៣.២ ព្រះធម៌.....107
១៣.៣ ព្រះសង្ឃ.....109
១៣.៣.១ សម្មតិសង្ឃ.....109
១៣.៣.២ អរិយសង្ឃ.....110
១៤. ពុទ្ធសាសនសុភាសិត.....112
១៤.១ សម្រង់ពុទ្ធភាសិតខ្លះៗ.....112
១៤.២ មន្ទិល ៩ ប្រការ.....116
១៥. អវសានកថា.....118
១៦. ឯកសារយោង.....122
១៧. បញ្ជីរាយនាមសប្បុរសជន.....125

*

"ទ្រព្យសម្បត្តិចម្បងរបស់មនុស្សគឺសុខភាព" ។

***"The first wealth is health."***

Ralph Waldo Emerson (1803-1882)

***

# ឧទ្ទិសកថា

ខ្ញុំសូមឧទ្ទិសបុណ្យកុសល ដែលកើតឡើងពីវណ្ណកម្មនេះ ជូនចំពោះមាតាបិតា, ញាតិកា ៧ សន្តាន, លោកគ្រូ, អ្នកគ្រូ និង អ្នកប្រាជ្ញខាងអក្សរសាស្ត្រ និង ពុទ្ធសាសនា ដែលបានចែកស្ថាន និង កំពុងរស់នៅសព្វថ្ងៃ ។ ជាពិសេស ខ្ញុំសូមឧទ្ទិសស្នាដៃនេះចំពោះអតីតសម្តេចព្រះសង្ឃរាជ ជួន ណាត (1883-1969) ព្រមទាំងអតីតសម្តេចព្រះសង្ឃរាជ ហួត តាត (1892-1975) ដែលបានបង្កើតអក្សរសាស្ត្រខ្មែរ ឲ្យមានបទដ្ឋានត្រឹមត្រូវ និង បានបង្កើតក្បួនខ្នាតផ្សេងៗ ខាងពុទ្ធសាសនាឲ្យសមស្របតាមសម័យទំនើប ។ ប្រសិនបើគ្មានសមិទ្ធិផលរបស់ភិក្ខុសង្ឃទាំងពីរព្រះអង្គនេះទេ នោះអក្សរសាស្ត្រខ្មែរក៏គ្មានបទដ្ឋានត្រឹមត្រូវ ហើយពុទ្ធសាសនិកជនខ្មែរ ក៏គ្មានក្បួនខ្នាតខាងពុទ្ធសាសនាថេរវាទ សមរម្យតាមសម័យទំនើបដែរ ។

សូមអានិសង្សនៃធម្មទាននេះ ជួយដឹកនាំវិញ្ញាណក្ខន្ធរបស់ភិក្ខុសង្ឃ និង លោកអ្នកទាំងនោះ ទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ ។ សូមសាសនារបស់ព្រះសមណគោតមបរមគ្រូ មានអាយុយឺនយូរគ្រប់កំណត់ ៥០០០ ព្រះវស្សា ដើម្បីជាម្លប់សាខា ត្រសុំត្រសាយ ត្រជាក់ត្រជុំ ដល់មនុស្សលោក ដែលកំពុងស្រេកឃ្លានសន្តិភាព, យុត្តិធម៌ និង សមធម៌ ។

ទីក្រុងឡុងប៊ិច, រដ្ឋខាលីហ្វ័រញ៉ា, សហរដ្ឋអាមេរិក
ថ្ងៃ ៥ កើត ខែ មិគសិរ ព.ស. ២៥៥៩
ត្រូវនឹងថ្ងៃទី ១៥ ខែ ធ្នូ គ.ស. ២០១៥
ឈុន គឹមអៀត

***

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំសូមថ្លែងអំណរព្រះគុណ និងអរគុណចំពោះ ៖

១. ភិក្ខុវិនយធរោ មហា យិន នឿន ប្រធានពុទ្ធិកសមាគម ខ្មែរ នៅទីក្រុង សាន់តាអាណា រដ្ឋខាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក ដែលព្រះអង្គបានជួយកែសម្រួល វាក្យស័ព្ទភាសាបាលី និង អត្ថន័យ ព្រមទាំងជួយផ្តល់នូវក្បួនច្បាប់ផ្សេងៗ សម្រាប់ ដកស្រង់មកបញ្ចូលក្នុងសៀវភៅនេះ ។

២. ធម្មាចារ្យ ប៊ុត សាវង្ស ដែលបានចំណាយពេលវេលាដ៏មានតម្លៃជួយ ត្រួតពិនិត្យ កែសម្រួលពាក្យពេចន៍ និង អត្ថន័យផ្សេងៗ ដើម្បីធ្វើឲ្យសៀវភៅនេះល្អ ប្រសើរឡើងតាំងពីដើមរហូតដល់ចប់ ។

៣. លោក ពេជ្រ វិសុទ្ធី ឱម ហៅ ឱម សុជាត់ អាចារ្យវត្តខេមរពុទ្ធិការាម ដែលបានផ្តល់យោបល់ល្អៗ និង ខ្នះខ្នែងនាំសំណៅនេះទៅប្រគេនភិក្ខុវិនយធរោ មហា យិន នឿន ដើម្បីសុំឲ្យព្រះអង្គជួយពិនិត្យកែសម្រួលឲ្យល្អប្រសើរឡើង ។

៤. លោក អ៊ុច ណាត នៅទីក្រុង ឡុងប៊ិច រដ្ឋខាលីហ្វ័រញ៉ា ដែលបានជួយឲ្យ យោបល់ល្អៗ ព្រមទាំងសៀវភៅច្រើនក្បាលជាភាសាអង់គ្លេស ដើម្បីដកស្រង់ បញ្ចូលក្នុងវណ្ណកម្មនេះ ។

៥. លោក គុជ សុជាតិ ដែលបានចំណាយពេលវេលា ជួយរចនាក្រប សៀវភៅនេះ ឲ្យមានសោភណភាព គួរជាទីរីករាយ ។

ប្រសិនបើគ្មានការឧបត្ថម្ភជ្រោមជ្រែង ពីសំណាក់ភិក្ខុសង្ឃ និង អស់លោក ដែលមាននាមខាងលើនេះទេ សៀវភៅ ទ្រឹស្តីកម្មផល នេះ ប្រាកដជាមិនអាចមាន រូបរាង ជាសមិទ្ធិកម្មថ្លៃថ្លា សម្រាប់ព្រះពុទ្ធសាសនាឡើយ ។

***

# ទាចារ្យអ្នករៀបរៀង

ខ្ញុំបានបោះពុម្ពសៀវភៅ "ទ្រឹស្តីកម្មផល" នេះសម្រាប់ចែកផ្សាយជាធម្មទាន លើកដំបូងនៅឆ្នាំ ២០០១ ហើយសប្បុរសជន លោកអ្នកអានគ្រប់មជ្ឈដ្ឋានបាន និយមអាន និង គាំទ្រយ៉ាងខ្លាំង តាំងពីពេលនោះ រហូតមកដល់សព្វថ្ងៃ ។ ខ្ញុំបាន បោះពុម្ពវណ្ណកម្មនេះ ផ្សាយជាធម្មទានចំនួន ១០ លើកមកហើយ ប៉ុន្តែភិក្ខុសង្ឃ និង ពុទ្ធបរិស័ទ នៅតែបន្តស្នើសុំឲ្យខ្ញុំបោះពុម្ពចែកជាធម្មទានបន្ថែមទៀត ។ ដើម្បី បំពេញបំណងនេះ ខ្ញុំក៏បានពឹងលោកប្អូន វ៉ាត ភិរក្ស នៅទីក្រុងម៉ុងរេអាល់[1] ប្រទេស កាណាដា ឲ្យវាយចម្លងសៀវភៅ "ទ្រឹស្តីកម្មផល" នេះឡើងវិញ ព្រោះខ្ញុំបានបាត់ សំណៅដើម ។ លោកប្អូន វ៉ាត ភិរក្ស ដែលមានទឹកចិត្តជ្រះថ្លាយ៉ាងខ្លាំងក្នុងធម្មទាន ក៏បានយកចិត្តទុកដាក់ ចំណាយពេលវេលាដ៏មានតម្លៃ បំពេញកិច្ចការនេះ លុះត្រា តែបានសម្រេចជាស្ថាពរ ។

ដើម្បីធ្វើឲ្យសៀវភៅ "ទ្រឹស្តីកម្មផល" នេះមានអត្ថរូប អត្ថរស និង អត្ថន័យ កាន់តែប្រសើរឡើង សម្រាប់បោះពុម្ពលើកទី ១១ និង លើកក្រោយទៀត ខ្ញុំបាន ត្រួតពិនិត្យសារឡើងវិញ នូវវាក្យស័ព្ទ អក្ខរាវិរុទ្ធ និយមន័យ និង បន្ថែមសេចក្តីខ្លះ តាមតម្រូវការ ។ ព្រមជាមួយគ្នានេះដែរ ខ្ញុំក៏បានពឹងលោកក្មួយ ជិន វិសាល ឲ្យជួយ កែលម្អរចនាបទសៀវភៅនេះ តម្រូវតាមបទដ្ឋាន (Standard) ឲ្យមានសោភណភាព ខ្លឹមសារ ប្រសើរឡើង ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសហការីទាំងពីររូបរបស់ខ្ញុំគឺ លោកប្អូន វ៉ាត ភិរក្ស និង លោកក្មួយ ជិន វិសាល ដែលបានរួមចំណែកកសាងសមិទ្ធិ កម្មដ៏ថ្លៃថ្លា សម្រាប់ព្រះពុទ្ធសាសនាទាំងអស់គ្នា ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា

---

[1] Montreal, Canada

សៀវភៅ "ទ្រឹស្តីកម្មផល" នេះ នឹងបានជាប្រយោជន៍ដល់ពុទ្ធបរិស័ទគ្រប់ៗគ្នា ជានិច្ច និរន្តរ៍ តទៅអនាគត ។

ថ្ងៃ ៥ កើត ខែ មិគសិរ ព.ស. ២៥៥៩
ត្រូវនឹងថ្ងៃទី ១៥ ខែ ធ្នូ គ.ស. ២០១៥
ឈុន គឹមអៀត

***

# ស្នាដៃរបស់ខ្ញុំ

1. ទ្រឹស្តីកម្មផល — រៀបរៀងនៅ ព.ស. ២៥៤៥, គ.ស. 2001
2. ព្រះពុទ្ធដីកា — រៀបរៀងនៅ ព.ស. ២៥៥២, គ.ស. 2008
3. អាមិសទានធម្មទាន — រៀបរៀងនៅ ព.ស. ២៥៥៤, គ.ស. 2010
4. និព្វានគឺជាអ្វី? — រៀបរៀងនៅ ព.ស. ២៥៥៦, គ.ស. 2012
5. សត្រូវនៃព្រហ្មចរិយធម៌ — រៀបរៀងនៅ ព.ស. ២៥៥៧, គ.ស. 2013
6. ពោធិបក្ខិយធម៌ — រៀបរៀងនៅ ព.ស. ២៥៥៨, គ.ស. 2014

*

សាមញ្ញជនរមែងជឿលើភ័ព្វព្រេងសំណាង ឬជោគជតារាសី ។
មហាបុរសជឿលើហេតុ និង ផលបុណ្ណោះ ។

**"Shallow men believe in luck or circumstance.**
**Strong men believe in cause and effect."**
-- Ralph Waldo Emerson

***

# អំពីអ្នកនិពន្ធ

ខ្ញុំបាទកើតនៅឆ្នាំ ១៩៤៦ (ថ្ងៃខែមិនប្រាកដ) នៅភូមិជ្រៃ ឃុំជ្រៃ ស្រុកមោងឬស្សី ខេត្តបាត់ដំបង ។ លោកឪពុកខ្ញុំឈ្មោះ ឈុន ហួយ និង អ្នកម្តាយខ្ញុំឈ្មោះ ពោលន់ ។ ខ្ញុំបាទមានបងប្អូន ៥ នាក់ ប្រុស ២ នាក់ និង ស្រី ៣ នាក់ ហើយខ្ញុំបាទជាកូនប្រុសច្បង ។

នៅខែ សីហា ឆ្នាំ ១៩៨១ ខ្ញុំត្រូវបានរដ្ឋាភិបាលសហរដ្ឋអាមេរិក អនុញ្ញាតឲ្យចូលមករស់នៅទីក្រុងឡុងប៊ិច[2] រដ្ឋខាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក ក្នុងឋានៈជាជនភៀសខ្លួន ។ ថ្វីត្បិតតែខ្ញុំក្លាយខ្លួនជាជនអន្តោប្រវេសន៍ ខ្ញុំនៅតែមានជំនឿលើពុទ្ធសាសនា ដោយបានដើរតាមគន្លងព្រះពុទ្ធោវាទ,បានធ្វើតាមមាគ៌ាខ្លះៗនៃមាគ៌ាទាំង ៨ ពោលគឺ សម្មាវាយាមៈ (ព្យាយាមត្រូវ) សម្មាកម្មន្តៈ (ការងារត្រឹមត្រូវ) និង សម្មាអាជីវៈ (ចិញ្ចឹមជីវិតត្រឹមត្រូវ) ។ កត្តាទាំងនោះបានធ្វើឲ្យជីវិតខ្ញុំបានប្រកបដោយសេចក្តីសុខចម្រើន និង មានជីវភាពសមរម្យនៅលើទឹកដីថ្មីនេះ ។

*

"វីរិយេន ទុក្ខមច្ចេតិ"
"ដោយសេចក្តីព្យាយាម មនុស្សអាចឆ្លងផុតពី
ទុក្ខទោសគ្រប់យ៉ាងបាន" ។

***

---

[2] Long Beach, California, USA

# ១. អារម្ភកថា

សៀវភៅ "ទ្រឹស្តីកម្មផល" នេះគឺជាវណ្ណកម្មទីមួយ ដែលខ្ញុំបានខិតខំព្យាយាមប្រមូលចងក្រងបោះពុម្ពចែកចាយជាធម្មទាន ។ ក្នុងការនិពន្ធសៀវភៅនេះ ខ្ញុំមានគោលបំណងសំខាន់ ២ ។ គោលបំណងទី ១ គឺដើម្បីពង្រីកចំណេះដឹងផ្ទាល់ខ្លួន ក្នុងវិស័យព្រះពុទ្ធសាសនាឲ្យកាន់តែទូលំទូលាយ ។ គោលបំណងទី ២ គឺដើម្បីចែករំលែកចំណេះដឹងនេះជាមួយអ្នកអាន ឲ្យយល់ច្បាស់ទ្រឹស្តីសំខាន់ៗ នៅក្នុងព្រះពុទ្ធសាសនា និង គោលគំនិតពិតរបស់ព្រះពុទ្ធចំពោះមនុស្សជាតិ ។

កាលខ្ញុំសរសេរសៀវភៅនេះចប់ លោក ពេជ្រ វិសុទ្ធី ឱម ហៅ ឱម សុផាត់ អាចារ្យវត្ត ខេមរពុទ្ធិការាម (វត្តខ្មែរនៅក្រុងឡុងប៊ិច) បានជួយខ្នះខ្នែងយកសំណៅដើមទៅប្រគេន ភិក្ខុវិនយធរោ មហា យិន នឿនដែលជាប្រធានពុទ្ធិកសមាគមខ្មែរនៅ ក្រុងសាន់តាអាណា[3] រដ្ឋខាលីហ្វ័រញ៉ា ជួយពិនិត្យកែសម្រួល ដើម្បីឲ្យសៀវភៅនេះមានខ្លឹមសារប្រសើរថែមទៀត ។ បន្ទាប់ពីភិក្ខុវិនយធរោ មហា យិន នឿន បានពិនិត្យ និង កែសម្រួលរួចហើយ ខ្ញុំបាននាំសំណៅដើមទៅជូនធម្មាចារ្យ ប៊ុត សាវង្ស ជួយពិនិត្យ និង កែសម្រួលផងដែរ ។ ធម្មាចារ្យ ប៊ុត សាវង្ស មានចិត្តជ្រះថ្លាបានជួយពិនិត្យ និង កែសម្រួលសំណៅដើមរហូតចប់សព្វគ្រប់ ។ ការឧបត្ថម្ភជ្រោមជ្រែងរបស់ភិក្ខុមហា យិន នឿន និង ធម្មាចារ្យ ប៊ុត សាវង្ស បានធ្វើឲ្យខ្ញុំមានបីតិសោមនស្សយ៉ាងក្រៃលែង ។

ដោយសារខ្ញុំជាពុទ្ធសាសនិកមួយរូប ដែលមានចិត្តជ្រះថ្លាចង់ចូលរួមចំណែកជួយបំភ្លឺពុទ្ធបរិស័ទទាំងឡាយ ឲ្យស្គាល់សេចក្តីបង្រៀនពិតរបស់ព្រះពុទ្ធ ហើយខ្ញុំក៏ពេញចិត្តពុទ្ធវចនៈថា "ធម្មទានឈ្នះអាមិសទានទាំងពួង..." ទើបខ្ញុំបាន

---

[3] City of Santa Ana, Orange County, California, USA

ខិតខំប្រឹងប្រែងពុះពារឧបសគ្គគ្រប់យ៉ាង ដើម្បីចងក្រងសៀវភៅ "ទ្រឹស្ដីកម្មផល"នេះទុកជាធម្មទាន ។ ទោះបីស្នាដៃនេះមិនមានព័ត៌មានលំអិតគ្រប់ជ្រុងជ្រោយក៏ដោយ ក៏គង់អាចបានជាប្រទីបតូចមួយជួយបំភ្លឺមិត្តអ្នកអាន ឲ្យយល់ច្បាស់នូវខ្លឹមសារនៃសេចក្ដីបង្រៀន និង គោលបំណងពិតរបស់ព្រះពុទ្ធដែរ ។

ប្រសិនបើលោកអ្នកប្រាជ្ញ រាជបណ្ឌិតខាងពុទ្ធសាសនា បានជួបប្រទះចំណុចឆ្គាំឆ្គងណាមួយ ផ្នែកនិយមន័យរបស់ពាក្យពេចន៍, ឃ្លាប្រយោគ ឬ អក្ខរាវិរុទ្ធ សូមមេត្តាជួយកែលម្អដោយសន្ដានចិត្តអនុគ្រោះ ។ ខ្ញុំបាទជាអ្នកនិពន្ធរង់ចាំទទួលការរិះគន់ស្ថាបនារបស់លោកអ្នកដោយចិត្តស្មោះសរ រីករាយជាទីបំផុត ។

ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៥
ក្រុងឡុងប៊ិច រដ្ឋខាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក

*

ដំរីជើងបួនគង់មានភ្លាត់
អ្នកប្រាជ្ញចេះស្ទាត់គង់មានភ្លេច ។
កំហុសរមែងមានដល់អ្នកធ្វើ
អ្នកនៅឥតអំពើបានអ្វីនឹងខុស ។
(បុរាណភាសិត)

***

# ២. សេចក្តីផ្តើម

មនុស្សច្រើននាក់រួបរួមប្រមូលផ្តុំគ្នា កើតបានជាសង្គម ។ សង្គមនីមួយៗមានវឌ្ឍនភាព ឬឱនភាពអាស្រ័យទៅលើមារយាទ បែបបទ និង ការប្រព្រឹត្តិនៃមនុស្សដែលជាឧបករណ៍របស់សង្គមនោះ ។ នៅពេលសង្គមកើតមាន សាសនាក៏កើតមានឡើងតាមនោះដែរ ។ ចំពោះសង្គមខ្មែរ ប្រជាជនខ្មែរនិយមរាប់អាន ជឿជាក់លើព្រះពុទ្ធសាសនា ដែលជាសាសនាលើកយក កម្មផលជាមូលដ្ឋាន ។ អាស្រ័យហេតុនេះទើបសង្គមខ្មែរមានឈ្មោះថា សង្គមព្រះពុទ្ធសាសនា ។

ពាក្យថា ព្រះពុទ្ធសាសនា ផ្សំដោយពាក្យ ពុទ្ធ និង សាសនា ហើយមានន័យថា សាសនាដែលយកសេចក្តីបង្រៀនរបស់ព្រះពុទ្ធជាគោលការណ៍ដឹកនាំជីវិត ។ តើព្រះពុទ្ធជានរណា ? តើសាសនាជាអ្វី ? ព្រះពុទ្ធគឺជាបុរសដ៏ឆ្នើម ដឹងច្បាស់អំពីបញ្ហាមនុស្សលោក មានកំណើតនៅប្រទេសឥណ្ឌា ភាគខាងជើង នាសតវត្សទី ៦ មុនគ្រិស្តសករាជ ក្នុងខត្តិយត្រកូល ។ ព្រះអង្គបានត្រាស់ដឹងសម្មាសម្ពោធិញ្ញាណ (Enlightenment) ហើយបានបរិនិព្វានទៅកាន់ស្ថានបរមសុខ (Nirvana) ។

ពាក្យថា ត្រាស់ដឹង មានន័យថា រកឃើញដោយប្រាជ្ញាញាណនូវអ្វីៗដែលអ្នកដទៃរកមិនឃើញ ។ រីឯពាក្យ និព្វាន គឺជា បរមត្ថធម៌ ដែលមានអត្ថន័យល្អិតសុខុមហួសវិស័យដែលមនុស្សទូទៅអាចយល់បាន ។ ប៉ុន្តែពាក្យ និព្វាន មានអត្ថន័យសង្ខេបថា អស់មានកម្មដដែលៗតទៅទៀត ពោលគឺ នៅមានតែបរមសុខ ហៅថាឯកន្តបរមសុខ តែមួយប៉ុណ្ណោះ ។ ដូច្នេះ ព្រះពុទ្ធគឺជាបុគ្គលរួចចាកកម្មទាំងឡាយ ឧទាហរណ៍កុសលកម្ម អកុសលកម្ម ជាដើម ដែលជាហេតុមិនមានកំណើតថ្មី ។ ដរាបណាកម្មមិនទាន់រលាយរលត់ ដរាបនោះជាតិទុក្ខ (ទុក្ខព្រោះមានកំណើត), ជរាទុក្ខ (ទុក្ខព្រោះចាស់ទ្រុឌទ្រោម), ព្យាធិទុក្ខ (ទុក្ខព្រោះរោគាបៀតបៀន), មរណទុក្ខ

(ទុក្ខព្រោះសេចក្តីស្លាប់) នៅតែផ្លាស់វេនគ្នាវិលបន្តជានិច្ច ដែលហៅថា វដ្តសង្សារចក្រ ឬ កង់ចក្រនៃវដ្តសង្សារ ។ ព្រះពុទ្ធទ្រង់ទតឃើញថា មនុស្សសត្វទាំងឡាយកំពុងរស់នៅក្រោមក្រញាំទុក្ខ ពុំអាចរើបម្រះបាន ។ បញ្ហាទុក្ខនេះ ពួកមេសាសនាធំៗដទៃ បានចាប់អារម្មណ៍ខ្លាំងណាស់ដែរ ប៉ុន្តែពួកគេ គ្មានលទ្ធភាពដោះស្រាយ ។ មានតែព្រះពុទ្ធប៉ុណ្ណោះ ដែលបានត្រាស់ដឹង និង បានរកឃើញច្បាស់នូវធម្មជាតិនៃទុក្ខរបស់សត្វលោក (ទុក្ខអរិយសច្ច), បានរកឃើញឫសគល់ ដើមកំណើតរបស់ទុក្ខ (ទុក្ខសមុទយអរិយសច្ច), បានរកឃើញកិរិយារំលត់ទុក្ខ (ទុក្ខនិរោធអរិយសច្ច) និង បានរកឃើញផ្លូវរំដោះទុក្ខ (មគ្គអរិយសច្ច) ។ ពួកទស្សនវិទូបស្ចិមប្រទេសបានកោតក្រែង សើ្ញចសរសើរព្រះប្រាជ្ញាញាណរបស់ព្រះពុទ្ធ ព្រមទាំងបានថ្វាយព្រះនាមដល់ព្រះអង្គថា មហាបុរសដ៏មានបេះដូងពេញដោយប្រាជ្ញាញាណ[4] ។

តើសាសនាគឺជាអ្វី ? ពាក្យថា សាសនា គឺជាពាក្យប្រើក្លាយពីភាសាបាលី សាសន មានន័យថា ឱវាទ ឬ ការទូន្មានប្រៀនប្រដៅរបស់គ្រូអាចារ្យណាមួយក្នុងលោកនេះ ។ ដូច្នេះព្រះពុទ្ធសាសនា គឺជាការប្រៀនប្រដៅរបស់ព្រះពុទ្ធ ។ មនុស្សទូទៅហៅព្រះពុទ្ធសាសនាថាព្រះពុទ្ធោវាទ, ព្រះពុទ្ធវចនៈ ឬព្រះពុទ្ធដីកាក៏បាន ។

នៅលើពិភពលោកមានសាសនាច្រើនរាប់ពាន់ ក៏ប៉ុន្តែសាសនាដែលមានមនុស្សកាន់ជឿតាមច្រើនមានដូចជា ៖

- ព្រហ្មញ្ញសាសនា (Brahmanism) មានកំណើតនៅប្រទេសឥណ្ឌា ។ បច្ចុប្បន្ននេះ មនុស្សភាគច្រើនស្គាល់ និង នាំគ្នាហៅសាសនានេះថា សាសនាហិណ្ឌូ (Hinduism) ។
- ព្រះពុទ្ធសាសនា (Buddism) មានកំណើតនៅប្រទេសឥណ្ឌា ។
- គ្រិស្តសាសនា (Christianity) មានដើមកំណើតនៅប្រទេសយូដា បច្ចុប្បន្ន

[4] The Intelligent Heart

គឺនៅប្រទេស អ៊ីស្រាអែល ។

- សាសនាអ៊ីស្លាម (Islam) មានកំណើតនៅប្រទេសអារ៉ាប់ ។
- សាសនាតៅ (Taoism) មានកំណើតនៅប្រទេសចិន ។
- សាសនាជេន (Jainism) ឬសាសនាអចេលកៈ មានកំណើតនៅឥណ្ឌា ។
- សាសនាសិន្តូ (Shintoism) មានកំណើតនៅប្រទេសជប៉ុន ។

ប្រវត្តិវិទូបានអះអាងថា នៅដើមគ្រិស្ដសករាជ ជនជាតិខ្មែរបានចាប់ផ្ដើមទទួលឥទ្ធិពលរបស់សាសនាធំៗពីរ ដែលមានកំណើតនៅប្រទេសឥណ្ឌា ពោលគឺ ព្រហ្មញ្ញសាសនា និង ពុទ្ធសាសនា ។

# ២.១ ព្រហ្មញ្ញសាសនា

ពាក្យថា "ព្រហ្មញ្ញសាសនា" (Brahmananism) មានន័យថាសេចក្ដីបង្រៀនរបស់ពួកព្រាហ្មណ៍ ឬបញ្ញារបស់ព្រះព្រហ្ម ។ យោងតាមនិទានបុរាណ (ទេវកថា) របស់ជនជាតិឥណ្ឌា (Hindu mythology) បន្ទាប់ពីផែនដីត្រូវបានបំផ្លាញដោយទឹកជំនន់ ពួកមនុស្សវណ្ណៈព្រាហ្មណ៍ (Brahmin) បានអួតអាងថា ពួកគេគឺជាពូជមនុស្សដែលកើតមកពីមាត់របស់មនុស្សបុរាណទី ១ (the current Manu) ឈ្មោះ ស្រទ្ធទេវមនុ (Sraddhadeva Manu) ដែលជាពូជមនុស្សកើតមកពីព្រះព្រហ្មរបស់ពួកគេ ។ ដូច្នេះ ពួកគេបានប្រកាសថា មានតែពួកមនុស្សនៅក្នុងវណ្ណៈព្រាហ្មណ៍ប៉ុណ្ណោះ ទើបអាចរៀនសូត្យ, បកស្រាយគម្ពីរវេទ និង ធ្វើពិធីខាងសាសនាព្រាហ្មណ៍បាន ។

នៅសម័យវេទនិយម ជនជាតិឥណ្ឌាតែងគោរពបូជា[5]ពួកអាទិទេពដែល

---

[5] បូជា (*pūjā*) ការថ្វាយឬជូនវត្ថុអ្វីៗចំពោះបូជនីយបុគ្គល, ការស្ដាប់ឱវាទ, ប្រព្រឹត្តិតាមឱវាទរបស់បុគ្គលដែលគួរគោរព ។

មានយសស័ក្តិ[6]ដូចជា ព្រះព្រហ្ម, ព្រះសិវៈ (ឥសូរ), ព្រះវិស្ណុ, ព្រះឥន្ទ, ព្រះអាទិត្យ ព្រះចន្ទ, ព្រះអគ្គិ, ព្រះវរុណ, ព្រះវាយុ (ពាយុ), ព្រះយម, ព្រះស្កន្ទ, ព្រះកាម ... ។ នៅសម័យក្រោយ ជនជាតិឥណ្ឌានៅតំបន់ខ្លះបានលើកតម្កើងព្រះព្រហ្ម, ព្រះសិវៈ និង ព្រះវិស្ណុ ឲ្យមានអំណាចលើសអាទិទេពផ្សេងទៀត ។ ឧទាហរណ៍ នៅសម័យព្រាហ្មណ៍និយម ជនជាតិឥណ្ឌាមួយភាគធំបាននាំគ្នាគោរពបូជាព្រះព្រហ្ម និង មិនខ្វល់ខ្វាយចំពោះព្រះសិវៈ និង ព្រះវិស្ណុទេ ។ សម័យក្រោយមក ពួកបរិស័ទនៃលទ្ធិព្រាហ្មណ៍ភាគច្រើន ឈប់គោរពអាទិទេពទាំង ៣ នោះទៀតហើយ ។ ពួកគេបែរជាបូជាអវតាររបស់ព្រះវិស្ណុ ដែលពួកគេបានចាត់ទុកថាជាអាទិទេព ដែលទទួលបានការពេញនិយម នៅតាមតំបន់នីមួយៗទៅវិញ ។ ឧទាហរណ៍ ជនជាតិឥណ្ឌាភាគច្រើននៅក្នុងរដ្ឋគុជរ៉ាត បាននាំគ្នាជឿថា ស្វាមីណារាយ័ន (Swaminarayan, 1781-1830) គឺជាអវតាររបស់ព្រះនារាយណ៍ ឬព្រះវិស្ណុ ហើយពួកគេបានបង្កើតឡើងនូវសាសនាហិណ្ឌូថ្មីស្រឡាងមួយទៀត ដែលមានឈ្មោះថា "សាសនាហិណ្ឌូនៃស្វាមីណារាយ័ន" (Swaminarayan Hinduism) ដែលមានព្រះវិហារធំៗច្រើនកន្លែងត្រូវបានកសាងនៅប្រទេសឥណ្ឌា និង ប្រទេសជាច្រើនទៀតនៅលើពិភពលោក ។ បច្ចុប្បន្ននេះ គេសង្កេតឃើញមាននៅសល់ភស្តុតាងខ្លះៗ នៃការគោរពលទ្ធិព្រាហ្មណ៍ នៅក្នុងប្រទេសឥណ្ឌាដែរ ។

ពួកអាចារ្យព្រាហ្មណ៍មានគម្ពីរផ្សេងៗច្រើនប្រភេទ ដែលពួកគេត្រូវទន្ទេញ

[6] សក្តិ (*shakti*, power, empowerment) អំណាច, សេចក្តីអង់អាច, សេចក្តីក្លាហាន, កម្លាំង ព្យាយាម រឹងប៉ឹង, ការខ្លាំងពូកែ, ការជំនាញ, សេចក្តីធន់, ការប៉ិនធន់ទ្រាំ, លំពែង ។

សម្រាប់ប្រើក្នុងកិច្ចពិធីសាសនា ។ គម្ពីរសំខាន់ៗមានដូចជាឫគ្វេទ[7], យជុរវេទ[8], សាមវេទ[9] និង អថព៌វេទ[10] ។ គម្ពីរទី ១ គឺគម្ពីរ ឫគ្វេទ ឬ ឥរុវេទ ដែលមានដំណើរសេចក្តីជាពាក្យឆន្ទ (កាព្យ) សម្រាប់សូត្រសរសើរពួកអាទិទេព ។ គម្ពីរទី ២ គឺគម្ពីរ យជុរវេទ ឬយជុវេទ ដែលមានដំណើរសេចក្តីជាពាក្យរាយរណ្តំសម្រាប់សូត្របូជា ឬ បួងសួងអាទិទេព ។ គម្ពីរទី ៣ គឺគម្ពីរ សាមវេទ ដែលមានដំណើរសេចក្តីជាពាក្យឆន្ទ សម្រាប់សូត្រក្នុងពិធីថ្វាយទឹកសោម[11] ។ ពួកអាចារ្យព្រាហ្មណ៍បានប្រើប្រាស់ភាសាសំស្រ្កឹត សម្រាប់តែងកំណាព្យដើម្បីទន្ទេញគម្ពីរវេទទាំង ៣ នេះ ដែលអាចហៅម្យ៉ាងទៀតថា វេទត្រ័យ, ត្រ័យវិទ្យា ឬត្រៃវេទ ។ ក្រោយមកពួកគេក៏បានបង្កើតគម្ពីរវេទទី ៤ ដែលមានឈ្មោះថា អថព៌វេទ ឬអថព្វវេទ គឺជាគម្ពីរសម្រាប់សូត្រហៅ ឬបណ្តេញខ្មោចបិសាច ឬសូត្រក្នុងពិធីលាងបាបផ្សេងៗ ។ មានអាចារ្យព្រាហ្មណ៍តិចតួចណាស់ ដែលយកកំណាព្យក្នុងគម្ពីរចុងក្រោយនេះ ទៅប្រើក្នុងពិធីផ្សេងៗ ។

ជនជាតិឥណ្ឌាភាគច្រើនមានជំនឿថា វត្ថុសព្វយ៉ាងនៅលើផែនដី និង ក្នុងចក្រវាឡ សុទ្ធតែជាស្នាដៃរបស់អាទិទេព និង មានអាទិទេពប្រចាំខ្លួន ឬជាម្ចាស់មើលការខុសត្រូវ ។ ដូច្នេះ អ្នកកាន់សាសនាហិណ្ឌូ ត្រូវធ្វើតាមបំណងហឫទ័យ

---

[7] Rig Veda ឬឥរុវេទ មកពីពាក្យថា "ឫគ" (ṛc) មានន័យថា សេចក្តីសរសើរ (praise, verse) ។

[8] Yajur Veda ឬ យជុវេទ មកពីពាក្យថា "យជុស" (yajus) មានន័យថា រូបមន្តឬក្បួនធ្វើពិធីបូជាយញ្ញ (sacrificial formula) ។

[9] Sāma Veda មកពីពាក្យថា "សាម័ន" (*sāman*) មានន័យថា ចម្រៀង (melody) ។

[10] Atharva Veda ឬអថព្វវេទ មកពីពាក្យថា "អថវ៌ន" (*Atharvan*) គឺជាឈ្មោះឫសី (ឥសី) មួយរូបនៅសម័យបុរាណ (ancient rishi) ដែលបានចូលរួមជាមួយឥសីឈ្មោះ អង្គិរ័ស (Angiras) ដើម្បីតាក់តែងគម្ពីរ អថ្វពវេទ ។

[11] Soma plant (*Ephedra sinica*) ដើមសោម ដែលជារុក្ខជាតិមានសារធាតុញៀន ។

របស់អាទិទេពទាំងនោះ ទើបពួកគេអាចរស់នៅប្រកបដោយសេចក្ដីសុខចំរើន ។ កិច្ចដែលពួកបរិស័ទត្រូវធ្វើមាន ៣ យ៉ាងគឺ (១) កិច្ចបំពេញតបៈ[12], (២) ពិធីបូជាព្រះអគ្គិ និង បូជាយញ្ញ, (៣) ពិធីសិវរាត្រី ឬពិធីថ្វាយបង្គំព្រះ និងបួងសួង ។ ពួកអ្នកកាន់លទ្ធិព្រាហ្មណ៍ មានជំនឿមុតមាំថា ការគោរពព្រះព្រហ្ម, ព្រះឥសូរ, ព្រះនារាយណ៍ និង ការប្រព្រឹត្តតាមពាក្យប្រៀនប្រដៅនៅក្នុងគម្ពីរត្រៃវេទ នាំមកនូវប្រយោជន៍ក្នុងលោកនេះ និង ក្នុងបរលោក[13] ។ ឯកសារប្រវត្តិសាស្ត្រមួយចំនួន បានបញ្ជាក់ថា ព្រហ្មញ្ញសាសនាត្រូវបាននាំចូលប្រទេសឥណ្ឌាដោយពួកអារ្យ[14] ។ ពួកអារ្យនេះបានធ្វើដំណើរមកពីតំបន់អាស៊ីកណ្ដាល ចូលលុកលុយប្រទេសអឺរ៉ុបមួយផ្នែក ហើយមួយផ្នែកទៀតចូលលុកលុយប្រទេសឥណ្ឌា ភាគខាងជើង ប្រហែល ១៥០០ ឆ្នាំមុនគ្រិស្តសករាជ ។ ដូច្នេះហើយ ទើបប្រវត្តិវិទូភាគច្រើនបានចាត់ទុកពួកអារ្យ ថាជាបុព្វបុរសនៃអំបូរឥណ្ឌូ-អឺរ៉ុប ។ ពួក មិលក្ខៈ ឬពួកទ្រាវិឌ[15] ដែលជាម្ចាស់ស្រុកបានខំតស៊ូច្បាំងនឹងពួកអារ្យយ៉ាងខ្លាំង ប៉ុន្តែមិនអាចយកជ័យជំនះបាន ព្រោះពួកអារ្យមានគ្រឿងចម្បាំងទំនើបជាង និង មានបទពិសោធន៍ច្រើនក្នុងសង្គ្រាម ។ ទីបំផុតពួកអារ្យបានគ្រប់គ្រងពួកទ្រាវិឌ ហើយក៏បានផ្សាយលទ្ធិវេទនិយម ទៅគ្រប់ទីកន្លែងនៅប្រទេសឥណ្ឌា ។ ពួកអារ្យមានចំណេះដឹងខាងវិស័យកសិកម្ម (ពិសេសខាងការចិញ្ចឹមសត្វគោ និង សេះ), តារាសាស្ត្រ, យុទ្ធសាស្ត្រ, ល្បិចកលនយោបាយ និង បច្ចេកវិជ្ជាផ្នែកសឹកសង្គ្រាម ច្រើនជាងពួកម្ចាស់ស្រុក ។ ដូច្នេះពួកអារ្យអាចគ្រប់គ្រងពួកម្ចាស់ស្រុក បានយ៉ាងមានប្រសិទ្ធភាព ។ ភស្តុតាងនៃការជិះជាន់នេះ

---

12 *Tapas* (តបៈ) គឺជាការចម្រើនភាវនា (deep meditation) ដូចជាការធ្វើសមាធិកម្មដ្ឋានតែម្នាក់ឯងនៅតាមព្រៃភ្នំ ដើម្បីសម្រេចមោក្ខ (self-realization) ។

13 *Paraloka* : the world beyond

14 *Aryan*: គឺជាក្រុមមនុស្សមកពីតំបន់អាស៊ីកណ្ដាល ដែលឈ្លានពានប្រទេសឥណ្ឌា ។

15 *Dravidans*

មានរហូតមកដល់សព្វថ្ងៃនេះ ដូចជារូបតំណាងអាទិទេពទាំងឡាយដែលជិះសត្វស្លាប ឬសត្វចតុប្បាទជាយានជំនិះផ្ទាល់ខ្លួន ។ សត្វជាយានជំនិះទាំងនោះគឺជាតំណាងសាសនានីមួយៗរបស់អ្នកស្រុកដើម នៅប្រទេសឥណ្ឌា ។

ព្រហ្មញ្ញសាសនា ប្រហែលត្រូវបានផ្សព្វផ្សាយចូលមកដល់ប្រទេសខ្មែរ មុនព្រះពុទ្ធសាសនាតាមរយៈពួកឈ្មួញឥណ្ឌា ដែលបានធ្វើដំណើរតាមសំពៅមកធ្វើអាជីវកម្មលក់ដូរជាមួយអ្នកស្រុក ។ ពួកឈ្មួញទាំងនោះ ភាគច្រើនគឺជាអ្នកគោរពលទ្ធិព្រាហ្មណ៍ ។ ឈ្មួញខ្លះបានរៀបការជាមួយស្ត្រីខ្មែរ ដែលជាកត្តានាំឲ្យប្រពៃណីរបស់ពួកព្រាហ្មណ៍ បានជ្រួតជ្រាបទៅក្នុងផ្នត់គំនិតជនជាតិខ្មែរ ។ សម័យក្រោយជនជាតិខ្មែរបានចាត់ទុកប្រពៃណីទាំងនោះ ថាជាប្រពៃណីរបស់ខ្លួនរហូតមកដល់បច្ចុប្បន្ន ។ សក្ខីភាពនៃកេរដំណែល ដែលមានសេសសល់រហូតមកដល់សព្វថ្ងៃ គឺនៅប្រាសាទអង្គរវត្តក្នុងខេត្តសៀមរាប ។ នៅទីនោះមានទេវរូបច្រើនយ៉ាង ដូចជាព្រះសិវៈ[16] ព្រះវិស្ណុ[17]និង ព្រះព្រហ្ម[18] ដែលគេធ្វើអំពីថ្មទុកជាបូជនីយវត្ថុ ។

# ២.២ ពុទ្ធសាសនា

ពុទ្ធសាសនា មានដើមកំណើតនៅប្រទេសឥណ្ឌា ប្រហែល ៥៤៣ ឆ្នាំមុនគ្រិស្តសករាជ ។ ក្រោយពីបានចាក់ឫសយ៉ាងមាំ ក្នុងប្រទេសឥណ្ឌាហើយ សាសនាព្រះសក្យមុនីត្រូវបានផ្សព្វផ្សាយ យ៉ាងឆាប់រហ័សឆ្ពោះទៅទិសខាងជើង និង ខាងកើតនៃភូមិភាគអាស៊ី ។ តាមរយៈការសាយភាយនេះ ព្រះពុទ្ធសាសនាត្រូវបានគេកែប្រែទ្រង់ទ្រាយឲ្យមានលក្ខណៈខុសគ្នាបន្តិចបន្តួច ស្របតាមលក្ខណៈភូមិសាស្ត្រ

---

16 Siva
17 Visnu
18 Brahma

សង្គម និង ប្រពៃណី របស់ប្រទេសទាំងឡាយដែលបានទទួលឥទ្ធិពល ។ ពេលក្រោយមក ពុទ្ធសាសនាបានបែកចេញជា ៣ និកាយ[19] ឬយាន[20] បន្តទៀត គឺ ហីនយាន, មហាយាន និង ពេជ្រយាន ឬ វជ្រយាន ។

និកាយហីនយាន[21] សព្វថ្ងៃហៅថា និកាយថេរវាទ[22] ដែលត្រូវបានផ្សព្វផ្សាយទៅទិសខាងត្បូងនៃប្រទេសឥណ្ឌា (ទក្ខិណនិកាយ) ។ ពុទ្ធបរិស័ទនៃនិកាយនេះយកព្រះធម៌វិន័យ[23]ជាធំ ។ ពួកគេគោរពប្រតិបត្តិតាមពុទ្ធោវាទ ដែលពួកសាវកសម័យដើម បានចងក្រងពុទ្ធវចនៈទុកក្នុងគម្ពីរជាភាសាបាលី[24] ចាប់តាំងពីពេលដែលព្រះអង្គទ្រង់បានត្រាស់ដឹង រហូតដល់ពេលដែលព្រះអង្គបរិនិព្វាន ។ សព្វថ្ងៃប្រទេសដែលកាន់ប្រពៃណីព្រះពុទ្ធសាសនាថេរវាទ មានដូចជា ប្រទេសស្រីលង្កា, ភូមា (មីយ៉ាន់ម៉ា), នេប៉ាល់, ថៃ, ឡាវ, ខ្មែរ ។ល។

និកាយមហាយាន[25] ត្រូវបានផ្សព្វផ្សាយទៅទិសខាងជើង (ឧត្តរនិកាយ) នៃប្រទេសឥណ្ឌា ។ និកាយមហាយាន អះអាងថាជាយានធំ[26]ព្រោះអាចផ្ទុកសត្វលោកបានច្រើន ដើម្បីនាំឆ្ពោះទៅដែនដីបរិសុទ្ធ (Pure Land) នៅក្នុងក្តីសុបិនរបស់ពួកគេ ។ សូមបញ្ជាក់ថា ដែនដីបរិសុទ្ធ (ពុទ្ធក្សេត្រ) គ្មានទីតាំងពិតប្រាកដទេ វាគ្រាន់តែជានាមធម៌ ឬពាក្យតាងឲ្យគំនិតមួយប៉ុណ្ណោះ ។ ពាក្យថា ដែនដីបរិសុទ្ធ មានអត្ថន័យស្រដៀងគ្នានឹងអត្ថន័យរបស់ពាក្យថា និព្វាន ដែលពុទ្ធបរិស័ទមួយចំនួននៅ

---

[19] Sect

[20] Vehicle

[21] Hinayana

[22] Theravada Buddhism, The Buddhism of the Elders

[23] In Theravada Buddhism, the Patimokkha is the basic code of monastic discipline, consisting of 227 rules for fully ordained monks (bhikkhus) and 311 for nuns (*bhikkhunis*). It is contained in the Suttavibhanga, a division of the Vinaya Pitaka.

[24] ក្នុងគម្ពីរព្រះត្រៃបិដក

[25] Mahayana

[26] Grand or Upper Vehicle

ក្នុងនិកាយថេរវាទ យល់ច្រឡំថា និព្វាន គឺជាទីតាំងពិតប្រាកដមួយដូច្នោះដែរ ។ ការពិត និព្វាន គ្រាន់តែជានាមធម៌ (name, label) សម្រាប់តាងឲ្យចិត្តស្ងប់របស់មនុស្សប៉ុណ្ណោះ ។ ពុទ្ធសាសនាមហាយាន បានបង្កើតទ្រឹស្តីថ្មីៗច្រើនសឹងរាប់មិនអស់ ។ ពួកបរិស័ទនៃនិកាយនេះ និយមស្តាប់ការបង្រៀនរបស់គ្រូអាចារ្យ (អាចរិយវាទ) ។ ពុទ្ធសាសនិកនៃនិកាយនេះគោរពព្រះពុទ្ធផង និង គោរពពោធិសត្វផង ឧទាហរណ៍ពោធិសត្វ អវលោកិតេស្វរៈ (Avalokiteshvara) មញ្ជុស្រី (Mañjushrī) មេត្រិយ (Maitreya) ឬ អមិតភៈ (Amitābha) ជាដើម ។ សព្វថ្ងៃ ប្រទេសដែលនិយមកាន់ព្រះពុទ្ធសាសនាមហាយាន មានដូចជា វៀតណាម កូរ៉េ ជប៉ុន ទីបេ ចិន ម៉ុងហ្គោលី ឥណ្ឌូណេស៊ី ។ល។ សូមបញ្ជាក់ថា នៅសម័យដើម ជនជាតិខ្មែរក៏ធ្លាប់បានកាន់ព្រះពុទ្ធសាសនាមហាយានដែរ ដែលមានប្រាសាទអង្គរធំជាភស្តុតាងបញ្ជាក់ស្រាប់ ។

ពាក្យថា ពេជ្រយាន ឬវជ្រយាន[27] មានន័យថា យានដែលរឹងមាំដូចជាដុំពេជ្រ[28] ។ ពេជ្រយាន គឺជាសាខាមួយដែលបែកចេញពីនិកាយមហាយាន ។ និកាយនេះមានកំណើតនៅប្រទេសឥណ្ឌា ភាគឦសាន និង ភាគពាយព្យ បន្ទាប់មក ក៏ត្រូវបានផ្សព្វផ្សាយទៅដល់ ទីបេ ចិន និង ជប៉ុន ។ បរិស័ទនៃនិកាយនេះគោរពគ្រូអាចារ្យរបស់ពួកគេ ដូចបរិស័ទរបស់និកាយដទៃទៀតនៃមហាយានដែរ ។ ជាទូទៅ អ្នកប្រតិបត្តិធម៌នៃនិកាយនេះប្រមូលគ្នាជាក្រុមតូចៗ ដើម្បីដើរតាមគ្រូដែលជាយោគី ។

ទ្រឹស្តី និង ការអនុវត្តរបស់និកាយទាំង ៣ មានចំណុចរួម និង ចំណុចខុសប្លែកគ្នាច្រើនអន្លើ ។ នៅពេលទ្រឹស្តីពុទ្ធសាសនាត្រូវបានផ្សាយចូលទៅដល់តំបន់ផ្សេងៗនៅលើពិភពលោក ព្រះវិន័យ និង ព្រះសូត្រត្រូវបានកែប្រែឲ្យស្របទៅតាម

---

[27] Vajrayana
[28] Diamond Vehicle

ប្រពៃណីនៃសង្គមមនុស្សនៅតាមតំបន់ទាំងនោះ ។ ដោយសារព្រះអភិធម្មគឺជាការវិភាគចិត្តសាស្រ្តមនុស្ស ហេតុដូច្នេះហើយទើបយើងឃើញទ្រឹស្ដីទាំងឡាយនៅក្នុងព្រះអភិធម្មមានចំណុចដូចគ្នាយ៉ាងច្រើននៅក្នុងនិកាយទាំង ៣ នោះ ។

ដើម្បីងាយយល់ទ្រឹស្ដីរបស់និកាយធំៗទាំងបីនៃពុទ្ធសាសនា យើងអាចប្រដូចនិកាយហីនយាន ទៅនឹងគ្រឹះវិមាននៃសម្មាសម្ពោធិញ្ញាណ ។ យើងអាចប្រដូចនិកាយមហាយាន ទៅនឹងជញ្ជាំង និង សសររបស់វិមាននោះ ។ យើងអាចប្រដូចនិកាយពេជ្រយាន ទៅនឹងដំបូលនៃវិមាន ដែលត្រូវការគ្រឹះ សរសរ និង ជញ្ជាំង ដើម្បីទ្រទ្រង់ដំបូលឲ្យតាំងនៅយ៉ាងមាំបាន ។

នៅសតវត្សទី ៣ មុនគ្រិស្តសករាជ ក្នុងរជ្ជកាលព្រះបាទ អសោក(29) ព្រះពុទ្ធសាសនាត្រូវបានផ្សាយស្ទើរពេញប្រទេសឥណ្ឌា ។ ឯកសារប្រវត្តិសាស្រ្តបានសរសេរថា នៅពុទ្ធសតវត្សទី ៣ (ព.ស. ២៣៤) គឺតាំងពីមុនគ្រិស្តសករាជ ៣០០ ឆ្នាំម្ល៉េះ ព្រះបាទអសោក ដែលជាពុទ្ធសាសនិកជនដ៏ឆ្នើមក្នុងប្រទេសឥណ្ឌា បានបញ្ជូនសមណទូត ២ អង្គ គឺ ព្រះសោណត្ថេរ និង ឧត្តរត្ថេរ ឲ្យនាំយកព្រះពុទ្ធសាសនាថេរវាទ (ហីនយាន) ទៅផ្សាយនៅសុវណ្ណភូមិ(30)។ សិលាចារឹកនៅកម្ពុជា

---

[29] Ashoka Maurya (304–232 BCE) មហារាជ អសោក ឬព្រះបាទអសោក គឺជាអធិរាជនៃប្រទេសឥណ្ឌា នៅក្នុងសន្តតិវង្សមោរ្យា (Maurya Dynasty) ។ ព្រះបាទអសោកបានគ្រប់គ្រងឧបទ្វីបឥណ្ឌាក្នុងរង្វង់ឆ្នាំ ២៩៦ ទៅដល់ ២៣២ មុនគ្រិស្តសករាជ (269 BCE - 232 BCE) ។

[30] Suvarnabhumi : ពាក្យថា "សុវណ្ណភូមិ" គឺជាពាក្យក្នុងភាសាសំស្រ្កឹត ដែលមានន័យថាទឹកដីមាស។ តាមពិត ពាក្យ "សុវណ្ណភូមិ" ត្រូវបានអ្នកកត់ត្រាប្រវត្តិសាស្រ្តសម័យដើម បានប្រើសម្រាប់ហៅឈ្មោះដែនដីមួយកន្លែងនៅតំបន់អាស៊ីភាគអាគ្នេយ៍ ដែលសព្វថ្ងៃគឺជាប្រទេសភូមាភាគខាងត្បូង, ប្រទេសថៃ, ឡាវ, កម្ពុជា និង ម៉ាឡេស៊ី ។

ក្រោមបានបង្ហាញថា ព្រះពុទ្ធសាសនាប្រហែលបានហូរចូលមកប្រទេសខ្មែរក្នុងរជ្ជកាលព្រះបាទ ស្រីមារៈ ឬ ហ្វាន់ ចេម័ន[31] ។

គួរកត់សំគាល់ថា ភាសាបាលីហូរចូលមកប្រទេសខ្មែរតាម រយៈព្រះពុទ្ធសាសនាថេរវាទ ចំណែកឯភាសាសំស្ក្រឹត បានហូរចូលមកប្រទេសខ្មែរ តាមរយៈព្រះពុទ្ធសាសនាមហាយាន និង ព្រហ្មញ្ញសាសនា ។ ហេតុនេះទើបប្រជាជនខ្មែរមួយចំនួនធំយល់ច្រឡំថា ភាសាខ្មែរ មានប្រភពពីភាសាបាលី-សំស្ក្រឹត ។ ការពិតភាសាទាំង ២ នេះបានចូលមកក្រោយពេលដែលជនជាតិខ្មែរមានភាសាផ្ទាល់ខ្លួនរួច ស្រេចទៅហើយ ។ ការដែលខ្មែរប្រើពាក្យបាលី-សំស្ក្រឹត គឺគ្រាន់តែជាពាក្យខ្ចីមកបង្គ្រប់នូវការខ្វះខាតតែប៉ុណ្ណោះ ។ រីឯពាក្យ បាលី-សំស្ក្រឹតនេះសោតទៀត ក៏ត្រូវកែប្រែ ទាំងសូរស័ព្ទ ទាំងរូបស័ព្ទ ដើម្បីសម្របសម្រួលតាមសំនៀងខ្មែរ ។

តាមការស្រាវជ្រាវនៃពួកភាសាវិទូ ភាសាបាលី-សំស្ក្រឹតត្រូវគេចាត់ចូលក្នុងអំបូរភាសាឥណ្ឌូ-អឺរ៉ុប ដែលជាអំបូរភាសាមួយដែលមនុស្សនៅទ្វីបអឺរ៉ុបស្ទើរតែទាំងអស់ និង មួយភាគធំនៃប្រទេសឥណ្ឌាកំពុងប្រើប្រាស់ ។ ភាសាខ្មែរជាភាសាមួយស្ថិតនៅក្នុងអំបូរខ្មែរ-មន ដែលជាអំបូរធំមួយនៅតំបន់ អាស៊ីអាគ្នេយ៍ ។

នៅអតីតសម័យ មានតែជនជាតិខ្មែរ និង មនទេដែលមានអារ្យធម៌ខ្ពង់ខ្ពស់ជាងគេនៅអាស៊ីអាគ្នេយ៍ ពីព្រោះជនជាតិទាំង ២ នេះ រស់នៅត្រង់តំបន់វាលទំនាបនៃទន្លេ ដែលមានដីជាតិអាចប្រកបរបរកសិកម្មបានយ៉ាងប្រសើរ ។ ជនជាតិខ្មែររស់នៅត្រង់តំបន់វាលទំនាបនៃទន្លេមេគង្គ ។ ឯជនជាតិមន រស់នៅត្រង់តំបន់មេណាម

---

[31] Fan-Che-Man : គ្រប់គ្រងរាជនៅវង្វង់ឆ្នាំ ២០០ នៃគ្រិស្តសករាជ ។

(ប្រទេសថៃ) និង តំបន់វាលទំនាបនៃទន្លេឥរាវតី(32) (ប្រទេសភូមាសព្វថ្ងៃ) ។ អាស្រ័យដោយអរិយធម៌នៃជនជាតិខ្មែរ និង មន លូតលាស់រុងរឿងនេះហើយ ទើបគេនិយមប្រើពាក្យ មន-ខ្មែរ ឬខ្មែរ-មន ដូចពាក្យអំបូរខ្មែរ-មន, អរិយធម៌ខ្មែរ-មនជាដើម ។ ប៉ុន្តែចាប់ពីសតវត្សទី ១៦ មក ជនជាតិមនក៏បានបាត់បង់ទឹកដី និងអធិបតេយ្យរបស់ខ្លួនរហូតមក ដូចជាជនជាតិចាមសព្វថ្ងៃនេះដែរ ។ គួររំលឹកថាបន្ទាប់ពីច្បាំងចាញ់ជនជាតិភូមានិងបាត់បង់ទឹកដីព្រមទាំងអំណាច សព្វថ្ងៃជនជាតិមនបានក្លាយជាជនជាតិភាគតិចមួយ ដែលមានប្រជាជនសរុបជាង ៨ លាននាក់ (ឬ ២ ភាគរយ) កំពុងរស់នៅក្នុងរដ្ឋមន (Mon State) នៃប្រទេសភូមា (មីយ៉ាន់ម៉ា) ។ ជនជាតិ មន មួយភាគទៀត (ជាង ១១ ម៉ឺននាក់) បានរត់ភៀសខ្លួនទៅតាំងលំនៅក្នុងខេត្តកញ្ចនបុរី (Kanchanaburi) នៃប្រទេសថៃរហូតដល់សព្វថ្ងៃ ។ ចំណែកឯជនជាតិចាមក៏មានវាសនាមិនខុសពីជនជាតិមនដែរ ។ ក្រោយពីច្បាំងចាញ់ជនជាតិយួន និង បាត់បង់ទឹកដីចម្ប៉ា ជនជាតិចាមខ្លះបន្តរស់នៅក្នុងភូមិភាគកណ្តាល នៃប្រទេសវៀតណាម, ខ្លះទៀតបានរត់ភៀសខ្លួនទៅរស់នៅប្រទេសខ្មែរ និង ថៃ ។

*

"សាសនារបស់ខ្ញុំងាយស្រួលបំផុត ។
សាសនារបស់ខ្ញុំគឺការមានចិត្តប្រណីចំពោះមនុស្ស ។"

**"My religion is very simple.
My religion is kindness."**
– The 14th Dalai Lama (1935 - Present)

***

[32] The Irrawaddy River, Ayeyarwady River គឺជាទន្លេវែងជាងគេនៅប្រទេសភូមា មានប្រវែង ២១៧០ គីឡូម៉ែត្រ មានប្រភពនៅភាគខាងត្បូងប្រទេសចិន និងហូរចាក់ទៅឈូងសមុទ្របឹងហ្គាល់ ។ ពាក្យថា "ឥរាវតី" ក្លាយមកពីពាក្យ "ឰរាវតី" (Airavati) **គឺជាអាទិទេពដំរី ដែលជាតំណាងឲ្យទឹក ។**

# ៣. ពុទ្ធប្រវត្តិ

ដើម្បីជួយឲ្យអ្នកអានងាយយល់មូលហេតុនៃការបង្កើត "ទ្រឹស្តីកម្មផល" ដែលជាមូលដ្ឋាននៃព្រះពុទ្ធសាសនា ខ្ញុំសូមលើកយកពុទ្ធប្រវត្តិ មកអធិប្បាយដោយសង្ខេប ។ ចំណុចសំខាន់ដែលយើងនឹងពិភាក្សាគឺ (១) ដំណើររឿងនៃបដិសន្ធិ (២) ការត្រាស់ដឹង (៣) ធម្មទេសនា (៤) បរិនិព្វាន និងពុទ្ធកាលនៃព្រះសមណគោតម ។

## ៣. ១ បដិសន្ធិ

ពុទ្ធប្បវត្តិកថាភាគច្រើនរៀបរាប់ថា ព្រះពុទ្ធទ្រង់មានព្រះនាមដើមថា សិទ្ធត្ថ (Siddhartha) និង មានព្រះរាជវង្ស គោតម (Gautama) ។ ព្រះវរបិតារបស់ព្រះអង្គមានព្រះនាមថា សុទ្ធោទនៈ (Suddhodana) ដែលជាព្រះរាជានៃកុលសម្ព័ន្ធ សាក្យ (Shakya) និង សោយរាជ្យនៅនគរ កបិលពស្តុ នៅប្រទេសឥណ្ឌាប៉ែកខាងជើង ដែលសព្វថ្ងៃនេះស្ថិតនៅក្នុងប្រទេសនេប៉ាល់ (Nepal) ។ ព្រះមាតារបស់ព្រះអង្គមានព្រះនាមថា សិរិមហាមាយា (Maya) ដែលជាបុត្រីរបស់ព្រះរាជានៃកុលសម្ព័ន្ធកោលិយៈ ដែលសោយរាជនៅនគរ ទេវទហៈ នៅជាប់ព្រំដែននគរ កបិលពស្តុ ។

ព្រះនាង សិរិមហាមាយា បានសុបិនឃើញដំរីសមួយមានភ្លុក ៦ ចុះពីស្ថានលើ មកចូលក្នុងផ្ទៃរបស់ព្រះនាងផ្នែកខាងស្តាំ ។ ព្រាហ្មណ៍បុរោហិតបានកាត់សុបិននោះ និង បានព្យាករថា ព្រះនាងសិរិមហាមាយា នឹងមានបុត្រាមួយអង្គប្រកបដោយមហាបុរិសលក្ខណៈ និង ប្រកបដោយបុណ្យបារមីដ៏លើសលប់ ។ ឯកសារពុទ្ធសាសនាថេរវាទបានរៀបរាប់ថា ព្រះរាជកុមារ សិទ្ធត្ថ បានប្រសូតនៅថ្ងៃសុក្រ ១៥ កើត ពេញបូរមី នៃខែពិសាខ ឆ្នាំច នៅក្រោមដើមសាលព្រឹក្ស (ដើមរាំង) ក្នុងឧទ្យានលុម្ពិនី ដែលស្ថិតនៅចំព្រំប្រទល់នៃនគរ កបិលពស្តុ និង នគរ ទេវទហៈ ។ លុះប្រសូតបាន ៧ ថ្ងៃ ព្រាហ្មណ៍ ៨ នាក់បានថ្វាយព្រះនាមព្រះឱរសថា សិទ្ធត្ថ ដែល

មានន័យថា អ្នកសម្រេចប្រយោជន៍គ្រប់យ៉ាង ។ ព្រាហ្មណ៍ទាំង ៧ នាក់លើកម្រាមដៃ ២ ព្យាករថា ប្រសិនបើព្រះកុមារស្ថិតនៅជាក្សត្រ នោះនឹងបានក្លាយជាស្ដេចចក្រពត្តិ ។ ប្រសិនបើព្រះអង្គទ្រង់ចេញសាងផ្នួស នោះព្រះអង្គនឹងបានត្រាស់ជាព្រះពុទ្ធ ។ ប៉ុន្តែព្រាហ្មណ៍ម្នាក់ទៀតឈ្មោះ កោណ្ឌញ្ញ ដែលមានវ័យក្មេងជាងគេ បានលើកតែម្រាមដៃមួយហើយទាយថា ព្រះរាជកុមារពិតជាបានត្រាស់ជាព្រះពុទ្ធមិនខាន ។ រយៈពេល ៧ ថ្ងៃក្រោយពេលព្រះរាជកុមារ សិទ្ធត្ថ បានប្រសូត្រ, ព្រះនាងសិរិមហាមាយាទ្រង់បានសោយព្រះពិរាល័យ[33] និង បានទៅកើតនៅស្ថានតុសិត ។ ព្រះនាង មហាបជាបតិគោតមី ដែលជាព្រះមាតុច្ឆា (ម្ដាយមីងខាងម្ដាយ) របស់ព្រះរាជកុមារ សិទ្ធត្ថ បានជួយចិញ្ចឹមបីបាច់ថែរក្សាព្រះអង្គតរៀងមក ។

## ៣.២ ការត្រាស់ដឹង

ពេលមានព្រះជន្ម ៧ ឆ្នាំ ព្រះរាជកុមារ សិទ្ធត្ថ បានសិក្សាវិជ្ជាផ្សេងៗតាមលទ្ធិព្រាហ្មណ៍ពីសំណាក់ឥសី វិស្វាមិត្រ (Vishwāmitra) ។ ព្រះរាជកុមារមានប្រាជ្ញាឆ្លាតវៃ និង ពូកែលើសគេទាំងខាងអក្សរសាស្ត្រ និង យុទ្ធសាស្ត្រ ។ ព្រះសុទ្ធោទនៈ ដែលជាព្រះវរបិតារបស់ព្រះរាជកុមារ ទ្រង់បានពេញព្រះទ័យចំពោះភាពអង់អាច និងភាពឆ្លាតវៃរបស់ព្រះរាជកុមារយ៉ាងខ្លាំង ។ ដូច្នេះព្រះវរបិតា បានត្រាស់បង្គាប់ឲ្យពួកអាមាត្យជីកស្រះ ៣ កន្លែងនៅក្នុងបរិវេណនៃព្រះរាជនិវេសន៍ ។ ស្រះទី ១ មានដាំឈូកខៀវ, ស្រះទី ២ មានដាំឈូកស និង ស្រះទី ៣ មានដាំឈូកចម្រុះពណ៌ ទុកជាទីក្រសាលរបស់ព្រះរាជឱរស ។ នៅពេលមានព្រះជន្ម ១៦ ឆ្នាំ ព្រះរាជឱរសបាន

---

[33] វីរ + អាលយ = លំនៅរបស់ជនអ្នកក្លៀវក្លា, អ្នកអង់អាច, លំនៅរបស់អ្នកចម្បាំង ឬស្ថានសួគ៌ ។ ខ្មែរប្រើពាក្យនេះសំដៅន័យថា "ដំណើរស្លាប់ទៅកើតឯស្ថានសួគ៌" សម្រាប់ហៅមរណភាពនៃព្រះអគ្គមហេសីក្សត្រិយ៍ទ្រង់រាជ្យ ។ ពាក្យ វិលាល័យ គឺជាសំនៀងអានតាមភាសាថៃ ។

រៀបអភិសេកជាមួយព្រះនាង ពិម្ពាយសោធរា (Yashodhara) ដែលមានព្រះជន្ម ១៦ ឆ្នាំដូចគ្នា ។ ព្រះនាង ពិម្ពា គឺជាព្រះរាជធីតារបស់ព្រះបាទ សុប្បពុទ្ធ (Suppabuddha) នៃក្រុង ទេវទហៈ (Devadaha) និង ជាបងប្អូនជីដូនមួយរបស់ព្រះរាជកុមារ សិទ្ធត្ថ ។ ព្រះវរបិតាបានត្រាស់បង្គាប់រាជអាមាត្យឲ្យសង់ប្រាសាទចំនួន ៣ ថ្វាយព្រះរាជកុមារ និង ព្រះមហេសី សម្រាប់ក្រសាលនៅរដូវក្តៅ, រដូវរងារ និង រដូវរំហើយ ។ ព្រះវរបិតាក៏បានបង្គាប់ឲ្យរាជអាមាត្យ តាក់តែងប្រាសាទនីមួយៗ ដោយផ្ទាំងគំនូរស្រើបស្រាល (Erotic Arts) ផ្សេងៗ ។ រៀងរាល់រាត្រី ស្រីរបាំស្រស់ស្អាតៗ បានមកប្រគំតូរ្យតន្ត្រី និង រាំច្រៀងថ្វាយព្រះរាជកុមារ សិទ្ធត្ថ ។ លើសពីនោះទៀត ស្រីស្នំស្អាតៗច្រើនរូបប្រកបដោយទេពកោសល្យខាងសិល្បៈកាមគុណ ក៏បានមកបម្រើព្រះរាជកុមារផងដែរ ។ កិច្ចការទាំងនេះ គឺជាព្រះតម្រិះរបស់ព្រះសុទ្ធោទនៈ ដើម្បីអន្ទងចងចិត្តរបស់ព្រះរាជកុមារឲ្យជាប់ជំពាក់នឹងកាមកិលេស និង កុំឲ្យព្រះរាជកុមារនឹកទៅដល់ការសាងផ្នួសដូចការទស្សន៍ទាយរបស់ព្រាហ្មណ៍ ។

ដោយសារធុញថប់នឹងជីវភាពដដែលៗនៅក្នុងព្រះរាជវាំង ក្រោមការពង្វក់របស់ព្រះវរបិតាឲ្យឈ្លក់ក្នុងកាមគុណ ព្រះរាជកុមារសិទ្ធត្ថបានសុំព្រះរាជានុញ្ញាតពីព្រះវរបិតាទៅទតមើលជីវភាពប្រជារាស្ត្រនៅក្រៅព្រះរាជវាំង ។ ព្រះរាជទស្សនកិច្ចនេះបានធ្វើឲ្យព្រះរាជកុមារ ជួបប្រទះទិដ្ឋភាពខុសប្លែកទាំងស្រុងពីជីវភាពនៅក្នុងព្រះរាជវាំង ។ នៅក្នុងព្រះរាជទស្សនកិច្ចនេះដែរ ព្រះអង្គទ្រង់បានជួបប្រទះនឹងទេពនិម្មិត ៤ លើកគឺ ៖

- ទេពនិម្មិតទី ១ ព្រះរាជកុមារទ្រង់បានទតឃើញមនុស្សចាស់ ។
- ទេពនិម្មិតទី ២ ព្រះរាជកុមារទ្រង់បានទតឃើញមនុស្សឈឺ ។
- ទេពនិម្មិតទី ៣ ព្រះរាជកុមារទ្រង់បានទតឃើញមនុស្សស្លាប់ ។
- ទេពនិម្មិតទី ៤ ព្រះរាជកុមារទ្រង់បានទតឃើញអ្នកបួស ។

ទេពនិមិត្តទាំង ៤ ប្រភេទនេះ បានធ្វើឲ្យព្រះរាជកុមារទ្រង់កើតក្តីសង្វេគចំពោះជីវិតរបស់ព្រះអង្គ និង ជីវិតរបស់មនុស្សទូទៅ ។ ចំណុចនេះបានធ្វើឲ្យព្រះរាជកុមារទ្រង់ចង់សាងផ្នួស ។ ចាប់តាំងពីពេលនោះមក ព្រះសិទ្ធត្ថកុមារទ្រង់បានចាប់ផ្តើមស្អប់ខ្ពើមលោកសន្និវាសកាន់តែខ្លាំងឡើង ។ ព្រះអង្គទ្រង់បានឈ្វេងយល់ឃើញថា គ្រឿងសប្បាយទាំងអស់ សុទ្ធតែជាវត្ថុមិនទៀង (អនិច្ច, Impermanence), មនុស្ស និង សត្វកំពុងរស់នៅក្នុងជីវិតដែលពោរពេញដោយការមិនពេញចិត្ត (ទុក្ខ, Dissatisfaction) ។ ព្រះអង្គទ្រង់បានយល់ច្បាស់ថាទ្រព្យសម្បត្តិ, អំណាច ឬ ស្រីរូបឆើត គ្រាន់តែជាគ្រឿងបញ្ឆោតចិត្តមនុស្សប៉ុណ្ណោះ ។ សេចក្តីសុខខាងផ្លូវកាយ (កាមសុខ) គឺជាសេចក្តីសុខក្លែងក្លាយ ដែលកើតឡើងដោយតណ្ហា ។ ប៉ុន្តែមនុស្សទូទៅពេញចិត្តនឹងកាមសុខណាស់ ព្រោះពួកគេគឺជាទាសករនៃអវិជ្ជា ។

ព្រះរាជកុមារសិទ្ធត្ថ ទ្រង់បានជ្រើសរើសការសាងផ្នួសជាមធ្យោបាយសម្រាប់ដោះស្រាយបញ្ហាទុក្ខរបស់មនុស្ស ។ ព្រះអង្គទ្រង់បានលះបង់រាជវង្ស, រាជសម្បត្តិ, ព្រះមហេសី, ព្រះរាជបុត្រ (រាហុលដែលទើបប្រសូត) រួចចេញសាងផ្នួស ទោះបីព្រះវរបិតាបានប្រើគ្រប់មធ្យោបាយដើម្បីរារាំងព្រះអង្គយ៉ាងណាក៏ដោយ ។

ពេលបានដឹងថាព្រះរាជកុមារ សិទ្ធត្ថ ទ្រង់បានយាងទៅបួសក្នុងព្រៃ ពេលនោះកោណ្ឌញ្ញព្រាហ្មណ៍ និង ព្រាហ្មណ៍ ៤ នាក់ទៀតក៏មានចិត្តជ្រះថ្លាចេញទៅបួសដែរ ។ ព្រាហ្មណ៍ទាំង ៥ នាក់ ឬបញ្ចវគ្គិយ មានឈ្មោះ កោណ្ឌញ្ញ, វប្បៈ, ភទ្ទិយៈ, មហានាម និង អស្សជិ ។ ព្រះរាជកុមារបានសិក្សាតបធម៌ជាមួយតាបស (អ្នកបួសក្នុងសាសនាព្រាហ្មណ៍) ២ នាក់ គឺ អាឡារតាបស និង ឧទកតាបស ។

ទោះបីព្រះរាជកុមារខំធ្វើ តបធម៌ តាមតាបសទាំង ២ យ៉ាងណា ក៏ទ្រង់នៅតែរកមិនឃើញមោក្ខធម៌ដែរ ។ តាបសទាំង ២ ចេះត្រឹមតែលោកិយធម៌ ដែលមិនមែនជាលោកុត្តរធម៌ ឬធម៌នាំឲ្យសម្រេចការត្រាស់ដឹង ។ ព្រះរាជកុមារទ្រង់បានបោះបង់

តាបសទាំង ២ ហើយទ្រង់បានស្វែងរកសច្ចធម៌ដោយព្រះអង្គឯង ។

ព្រះអង្គទ្រង់បានចំណាយពេល ៦ ឆ្នាំ ដើម្បីប្រតិបត្តិតាមផ្លូវដ៏តឹងតែងបំផុត (ទុក្ករកិរិយា) ប៉ុន្តែព្រះអង្គនៅតែមិនបានសម្រេចការត្រាស់ដឹង ។ ដូច្នេះព្រះអង្គទ្រង់បានជ្រើសយក ការប្រតិបត្តិតាមផ្លូវកណ្តាល[34]ដែលនៅចន្លោះផ្លូវធូររលុង[35] និងផ្លូវដ៏តឹងតែងបំផុត[36] ។

ព្រះអង្គទ្រង់បានសម្រេចព្រះទ័យយាងចេញពីនគរ រាជគ្រឹះ ដែលជារាជធានីនៃរដ្ឋមគធៈ ដើម្បីធ្វើដំណើរទៅស្រុកពោធិគយា (Bodh Gaya) ដែលសព្វថ្ងៃហៅថា រដ្ឋ ប៊ីហារ (Bihar) ក្នុងនគរមគធៈ ។ ព្រះរាជកុមារសិទ្ធត្ថ បានតាំងសមាធិនៅក្រោមដើមពោធិព្រឹក្សក្បែរស្ទឹងនេរញ្ជរា (Neranjara) រហូតរកឃើញមោក្ខធម៌ និង សម្រេចការត្រាស់ដឹង (Awakening) នៅថ្ងៃពុធ ១៥ កើតពេញបូរមី ខែ ពិសាខ ឆ្នាំរកា ក្នុងព្រះជន្ម ៣៥ វស្សា ។ ចាប់តាំងពីពេលនោះមក ព្រះរាជកុមារ សិទ្ធត្ថ ត្រូវបានមនុស្សទាំងឡាយប្រសិទ្ធិនាមថា ព្រះពុទ្ធ[37] ព្រោះព្រះអង្គគឺជាបុគ្គលដែលបានសម្រេចសម្មាសម្ពោធិញ្ញាណ ។

## ៣.៣ ធម្មទេសនា

នៅពេលព្រះរាជកុមារ សិទ្ធត្ថ បានត្រាស់ដឹងសម្មាសម្ពោធិញ្ញាណជាព្រះពុទ្ធ ព្រះអង្គទ្រង់បានសម្តែងធម្មទេសនាជាលើកដំបូង[38]ស្តីអំពីអរិយសច្ច[39] ៤ ដល់

[34] មជ្ឈិមាបដិបទា (*Majjhimā Patipadā*, The Middle Path)។

[35] កាមសុខល្លិកានុយោគ (*kāmasukhallikānuyoga*, self-indulgence) ។

[36] អត្តកិលមថានុយោគ (*attakilamathānuyoga*, self-mortification) ។

[37] Buddha, The Enlightened One

[38] First Sermon

[39] The Four Noble Truths

បញ្ចវគ្គិយ នៅសួនឧទ្យាន ឥសិបតនមិគទាយវ័ន[40] ។ បន្ទាប់មកព្រះអង្គទ្រង់បានសម្តែងធម្មទេសនាបង្រៀនមនុស្សនានាដោយមិនប្រកាន់វណ្ណៈ រាប់ទាំងពួកវណ្ណៈព្រាហ្មណ៍, វណ្ណៈក្សត្រ, វណ្ណៈវេស្សៈ, និង វណ្ណៈសូទ្រៈ ទាំងប្រុស ទាំងស្រី ។ មនុស្សម្នាច្រើននាក់មកពីគ្រប់វណ្ណៈបានសុំបួសក្នុងសំណាក់ព្រះពុទ្ធ ។ អស់រយៈពេល ៤៥ ឆ្នាំ ព្រះអង្គទ្រង់តែងបំពេញពុទ្ធកិច្ច ៥ ប្រការជានិច្ចដោយឥតខ្ចាចនឿយហត់ព្រះកាយពល ។ ពុទ្ធកិច្ចទាំង ៥ ប្រការគឺ ៖

- ពេលព្រឹក ទ្រង់និមន្តបិណ្ឌបាត,
- ពេលរសៀល ទ្រង់សម្តែងធម្មទេសនាដល់សាធារណជន,
- ពេលព្រលប់ ទ្រង់ប្រទានឱវាទដល់ភិក្ខុសង្ឃ,
- ពេលកណ្តាលអធ្រាត្រ ទ្រង់ដោះស្រាយប្រស្នារបស់ពួកទេវតា,
- ពេលជិតភ្លឺ ទ្រង់ប្រមើលសត្វលោក មានភ័ព្វ និង ឥតភ័ព្វ ។

## ៣.៤ បរិនិព្វាន

លុះដល់ពេលចេញវស្សាទី ៤៥ នៅថ្ងៃ ១៥ កើតពេញបូរមី ខែមាឃ ឆ្នាំម្សាញ់ ព្រះពុទ្ធទ្រង់ដាក់អាយុសង្ខាររបស់ព្រះអង្គ ដោយប្រាប់មារថា ព្រះអង្គនឹងបរិនិព្វានក្នុងរវាង ៣ ខែទៀត ។ ពេលបានដឹងថាព្រះពុទ្ធបានដាក់ព្រះជន្មាយុសង្ខារហួសទៅហើយ ពួកសាវកទាំងឡាយ ជាពិសេស ព្រះអានន្ទ បានសោយសោកយ៉ាងខ្លាំង ព្រោះគ្រប់ៗគ្នាមិនទាន់ចង់ឲ្យព្រះអង្គទ្រង់បរិនិព្វាន ។ ព្រះពុទ្ធទ្រង់បានយល់ច្បាស់ថាពួកសាវករបស់ទ្រង់នៅខ្វះការជឿជាក់លើខ្លួនឯង ទើបទ្រង់បានដាស់តឿនថា ៖ "ភិក្ខុសង្ឃនៅនឹកប៉ុនប៉ងអ្វីក្នុងតថាគតទៀត …ធម៌ដែលតថាគតសំដែងហើយ ធ្វើមិនឲ្យមានខាងក្នុងខាងក្រៅ …កណ្តាប់ដៃនៃអាចារ្យ មិនមានក្នុងធម៌ទាំងឡាយ

[40] The Deer Park, Sarnath, India

របស់តថាគតទេ ...អ្នកទាំងឡាយ ចូរយកខ្លួនជាទីពឹង យកខ្លួនជាទីរលឹក កុំយករបស់ដទៃជាទីរលឹក ចូរយកធម៌ជាទីពឹង យកធម៌ជាទីរលឹក កុំយករបស់ដទៃជាទីរលឹកឡើយ ”។[41]

បន្ទាប់ពីនោះ ព្រះអង្គទ្រង់បានយាងទៅនគរ កុសិនារា (Kushinagar) រួចទ្រង់បានយាងចូលទៅកាន់ព្រៃសាលវ័ន ។ នៅទីនោះទ្រង់បានត្រាស់ឲ្យព្រះអានន្ទរៀបចំគ្រែថ្វាយព្រះអង្គផ្ទំ ។ នៅបច្ឆិមរាត្រី ទ្រង់ត្រាស់ដល់ភិក្ខុទាំងឡាយនូវបណ្តាំចុងក្រោយថា "លុះអំណើះតតអំពីតថាគតទៅ ធម៌និងវិន័យនោះជាគ្រូរបស់អ្នកទាំងឡាយ”។[42] "សង្ខារទាំងឡាយ មានសេចក្តីវិនាសទៅជាធម្មតា អ្នកទាំងឡាយចូរញ៉ាំងកិច្ចទាំងពួងឲ្យសម្រេច ដោយសេចក្តីមិនប្រមាទចុះ” ។[43][44] ព្រះពុទ្ធទ្រង់បានបរិនិព្វាននៅក្រុង កុសិនារា នៅថ្ងៃអង្គារ ១៥ កើតពេញបូណ៌មី ខែពិសាខ ឆ្នាំម្សាញ់ (៥៤៣ ឆ្នាំមុនគ.ស.) ក្នុងព្រះជន្ម ៨០ វស្សា ។

## ៣.៥ ពុទ្ធកាល

ពុទ្ធកាល ឬពោធិកាល គឺជារយៈពេល ដែលព្រះពុទ្ធកំពុងគង់ជាធរមាន ។ ពុទ្ធកាលត្រូវរាប់ចាប់តាំងពីពេលដែលព្រះពុទ្ធ ទ្រង់បានត្រាស់ដឹង ទៅដល់ពេលដែលព្រះអង្គទ្រង់បានបរិនិព្វាន ។ ពុទ្ធកាលមានរយៈពេល ៤៥ ឆ្នាំ និង ត្រូវបានចែកជា ៣ កាល ។ បឋមពោធិកាល គិតចាប់ពីពេលដែលព្រះពុទ្ធបានត្រាស់ដឹងទៅ

---

41 ព្រះត្រៃបិដក សៀវភៅលេខ ១៦ ទំព័រទី ២១៣-២១៤ (ទ្រង់មានព្រះពុទ្ធដីកានឹងព្រះអានន្ទ)។

42 ព្រះត្រៃបិដក សៀវភៅលេខ ១៦ ទំព័រទី ៣២០ (ព្រះបច្ឆិមវាចារបស់ព្រះមានព្រះភាគ)។

43 ព្រះត្រៃបិដក សៀវភៅលេខ ១៦ ទំព័រទី ២៥៥ (មហាបរិនិព្វានសូត្រ) និង ទំព័រទី ៣២៤ ។

44 “It may be that after I am gone that some of you will think, ‘now we have no teacher.’ But that is not how you should see it. Let the Dharma and the discipline that I have taught you be your teacher. All individual things pass away. Strive on, untiringly.” A quote from The Buddha, a PBS documentary.

ដល់ឆ្នាំទី ១៥ នៃពុទ្ធកាល ។ មជ្ឈិមពោធិកាល គិតចាប់ពីឆ្នាំទី ១៦ ដល់ឆ្នាំទី ៣០ នៃពុទ្ធកាល ។ បច្ឆិមពោធិកាល គិតចាប់ពីឆ្នាំទី ៣១ ដល់ឆ្នាំទី ៤៥ នៃពុទ្ធកាល ។

តាមរយៈពុទ្ធប្រវត្តិ យើងអាចសន្និដ្ឋានបានថា ព្រះពុទ្ធទ្រង់មិនមែនជាតួអង្គអាទិទេពទេ ។ ព្រះអង្គគឺជាមនុស្សម្នាក់ដែលបានរស់នៅក្នុងសង្គមមនុស្ស, បានទទួលការអប់រំនៅក្នុងលទ្ធិព្រាហ្មណ៍, បានសាកល្បងប្រតិបត្តិតាមមាគ៌ាឆ្ពោះទៅកាន់មោក្ខធម៌របស់ពួកព្រាហ្មណ៍, បានសិក្សាដឹងបញ្ហារបស់មនុស្ស, បានរកឃើញមាគ៌ាឆ្ពោះទៅកាន់ការរំលត់ទុក្ខ ដោយព្រះអង្គឯង, បានពន្យល់ណែនាំមនុស្សឲ្យចេះរស់នៅក្នុងគុណធម៌ និង ស្គាល់មាគ៌ាពិតឆ្ពោះទៅកាន់ការចេញចាកទុក្ខ ។ ដោយសារតែទ្រឹស្តី ឬព្រះធម៌វិន័យរបស់ព្រះពុទ្ធ មានលក្ខណៈប្រាកដនិយម, មនុស្សនិយម និង ចិត្តនិយម ទើបមនុស្សរាប់រយលាននាក់នៅលើពិភពលោក កំពុងនាំគ្នាប្រតិបត្តិ និង ផ្សព្វផ្សាយ ។ គួរកត់សម្គាល់ថា ព្រះពុទ្ធទ្រង់មិនបានបង្កើតព្រះពុទ្ធសាសនានៅក្នុងទម្រង់ ដែលពុទ្ធបរិស័ទនៅក្នុងប្រទេសទាំងឡាយកំពុងប្រតិបត្តិនោះទេ ។ ពុទ្ធសាសនិកនៅក្នុងប្រទេសទាំងនោះបានកែច្នៃសេចក្តីបង្រៀនរបស់ព្រះពុទ្ធ ឲ្យប្រែក្លាយទៅជាពុទ្ធសាសនាដែលមានរូបភាពផ្សេងៗ ស្របតាមប្រពៃណី និង ទំនៀមទម្លាប់របស់ជនជាតិរៀងៗខ្លួន ។

គួររំលឹកថា សេចក្តីបង្រៀនរបស់សាសនាទាំងអស់មានទាំងចំណុចល្អ និង ចំណុចមិនល្អ ។ សេចក្តីបង្រៀនដែលផ្តល់ផលវិជ្ជមានដល់សង្គមមនុស្ស នឹងនាំឲ្យមនុស្សចេះរស់នៅចុះសម្រុងគ្នា, នាំឲ្យប្រទេសជាតិនិងពិភពលោកមានសន្តិភាព ។ រីឯសេចក្តីបង្រៀនដែលផ្តល់ផលអវិជ្ជមាន នឹងនាំឲ្យមនុស្សប្រកាន់ជ្រុល (ជ្រុលនិយម), នាំឲ្យពួកគេបាត់បង់សីលធម៌ និង មនុស្សធម៌ ។ ឧទាហរណ៍ ពួកគេបែរជាស្រឡាញ់ និង គោរពព្រះអាទិទេព ជាជាងស្រឡាញ់មនុស្សដូចគ្នា ។ ពួកគេបែរជាធ្វើបុណ្យឲ្យខ្មោច ជាជាងធ្វើបុណ្យឲ្យមនុស្សរស់ ដែលកំពុងឃ្លាន ។

លើសពីនោះទៀត កិច្ចពិធីនៃពុទ្ធសាសនាថេរវាទ ខុសប្លែកទាំងស្រុងពីកិច្ចពិធីនៃពុទ្ធសាសនានិកាយមហាយាន ។ ឧទាហរណ៍ ពិធីសុំសីល, បិណ្ឌបាត និង វេរភត្តាហារ មានតែនៅក្នុងពុទ្ធសាសនាថេរវាទប៉ុណ្ណោះ ។ សូម្បីកិច្ចពិធីពុទ្ធសាសនាថេរវាទនៅតាមប្រទេសផ្សេងៗ ក៏មានលក្ខណៈខុសគ្នាច្រើនអន្លើដែរ ។ ដូច្នេះសូមអ្នកអាន និង អ្នកសិក្សាពិចារណា និង វាយតម្លៃគ្រប់កិច្ចពិធី និង ការបង្រៀនរបស់អាចារ្យទាំងឡាយ ដោយប្រើវិចារណញ្ញាណខ្ពស់ ។

*

"កុំកែប្រែការពិតតម្រូវតាមជំនឿរបស់អ្នក
ត្រូវកែប្រែជំនឿរបស់អ្នកតម្រូវតាមការពិតវិញ" ។

**"Don't bend the truth to fit your beliefs,**
**Bend your beliefs to fit the truths."**
-- Ajahn Brahm (1951-Present)

"យើងមិនអាចបង្រៀនមនុស្សឲ្យចេះដឹងអ្វីមួយឡើយ
យើងអាចត្រឹមតែជួយពួកគេឲ្យរកឃើញចំណេះដឹងនៅក្នុងខ្លួនគេប៉ុណ្ណោះ" ។

**"We cannot teach people anything;**
**we can only help them discover it within themselves."**
-- Galileo Galilei (1564-1642)

***

# ៤. ព្រះត្រៃបិដក

សេចក្ដីបង្រៀនរបស់ព្រះពុទ្ធ (ពុទ្ធវចនៈ) ឬហៅថា ពុទ្ធធម៌ ឬពុទ្ធធម្ម (Buddha’s Dhamma) គឺជាសេចក្ដីអធិប្បាយអំពីច្បាប់ធម្មជាតិទាក់ទងនឹងទុក្ខលំបាករបស់មនុស្សលោក និង វិធីចេញចាកទុក្ខ ។ ព្រះពុទ្ធបានចំណាយពេល ៤៥ ឆ្នាំ ដើម្បីបង្រៀនមនុស្សគ្រប់វណ្ណៈឲ្យយល់ច្បាស់ថាអ្វីជាទុក្ខ, អ្វីជាមូលហេតុនៃទុក្ខ, អ្វីជាសេចក្ដីសុខពេលរលត់ទុក្ខ និង វិធីប្រតិបត្តិដើម្បីរួចចាកទុក្ខ ។ ឯកសារមួយចំនួនអះអាងថា ពុទ្ធវចនៈត្រូវបានសាវកច្រើនជំនាន់ ប្រមូលចងក្រង (Collection) ជាគម្ពីរ ដែលមានសេចក្ដីបង្រៀនសរុបប្រាំបីម៉ឺនបួនពាន់ (8400) ព្រះធម្មក្ខន្ធ ។ ពាក្យថា ធម្មក្ខន្ធ[45] គឺជាវគ្គ ឬ ចំណែកមួយនៃសេចក្ដីបង្រៀនទាក់ទងនឹងក្រមសីលធម៌ ឬ របៀបរស់នៅក្នុងសង្គមមនុស្ស ។ ពួកសាសនវិទូមួយចំនួននៅបស្ចិមប្រទេសបានហៅពុទ្ធធម៌ថាជាទស្សនវិជ្ជា (Philosophy) ។

ពេលព្រះពុទ្ធទ្រង់គង់ជាធរមាននៅឡើយ សេចក្ដីបង្រៀនទាំងនោះ មិនទាន់ត្រូវបានគេកត់ត្រាជាលាយលក្ខណ៍អក្សរនៅឡើយទេ ។ ក្រោយពេលព្រះពុទ្ធទ្រង់បានបរិនិព្វាន ពួកសាវកច្រើនអង្គបាននាំគ្នាសូត្រ (សង្គាយនា) រម្លឹក និង ផ្ទៀងផ្ទាត់ពុទ្ធវចនៈដែលពួកគេបានឮ និង ចងចាំនៅតាមទីកន្លែង និង ពេលវេលាខុសៗគ្នា ។ នេះគឺជាប្រពៃណីដែលពួកសាវកនាំគ្នាធ្វើបន្តពីជំនាន់មួយទៅជំនាន់មួយ រហូតដល់បច្ចុប្បន្ន ។ លុះពុទ្ធសាសនាកន្លងទៅប្រហែល ៥០០ ឆ្នាំ សាវកទាំងឡាយបានកត់ត្រា និង ចងក្រងពុទ្ធវចនៈដោយប្រើអក្សររបស់ជនជាតិស្រីលង្កា (Sinhalese) ។

ដំណាក់កាលដំបូង ពុទ្ធវចនៈត្រូវបានហៅថាធម្មវិន័យ ដែលមាន ធម៌ (ក្រមសីលធម៌សម្រាប់មនុស្សទូទៅ) និង វិន័យ (ច្បាប់សម្រាប់អ្នកបួស) ។ សម័យក្រោយ

---

[45] An article or section of dhamma, a portion of norm

ទើបពួកសាវក បាននាំយកការវិភាគចិត្តសាស្រ្ត (psychoanalysis) មកបញ្ចូលជាមួយនឹងធម្មវិន័យ ដោយបង្កើតជាគម្ពីរអភិធម្ម ។ ពួកសាវកបានលើកតម្កើងគម្ពីរអភិធម្ម ដោយបានប្រើប្រាស់ព្រះនាមរបស់ព្រះពុទ្ធ ដើម្បីឲ្យមនុស្សទូទៅទទួលស្គាល់ និង ផ្សព្វផ្សាយ ។ បច្ចុប្បន្ននេះ ពុទ្ធវចនៈត្រូវបានហៅថា ព្រះត្រៃបិដក ព្រោះមាន ៣ ផ្នែក ។ គួរកត់សម្គាល់ថា សម័យដើម ព្រះធម៌ទាំង ៨៤000 ព្រះធម្មក្ខន្ធត្រូវបានរក្សាទុកក្នុងកន្ត្រក ឬ កញ្ជើ ចំនួន ៣ ។ ដូច្នេះទើបមនុស្សជំនាន់ក្រោយហៅគម្ពីរទាំងនោះថា តិបិដក ឬ ត្រៃបិដក ដែលមាន ៖

- វិនយបិដក មាន ១៣ ភាគ និង មាន ២១000 ធម្មក្ខន្ធ,
- សុត្តន្តបិដក មាន ៦៤ ភាគ និង មាន ២១000 ធម្មក្ខន្ធ,
- អភិធម្មបិដក មាន ៣៣ ភាគ និង មាន ៤២000 ធម្មក្ខន្ធ ។

១. ព្រះវិនយបិដក រៀបរាប់អំពីវិន័យសម្រាប់ភិក្ខុ ដែលមាន ២២៧ សិក្ខាបទ និង ៣១១ សិក្ខាបទសម្រាប់ភិក្ខុនី[46] ។

២. ព្រះសុត្តន្តបិដក ឬ ព្រះសូត្រ រៀបរាប់អំពីព្រះធម៌ ដែលមានជំរៅដោយអត្ថដូចជាបុញ្ញកម្ម បាបកម្ម សីលធម៌ ។ល។ ជាវោហារទេសនា (Conventional Teaching) ព្រះសាវក ក៏អាចសម្តែងបានដែរ ។

៣. ព្រះអភិធម្មបិដក (អភិធម្ម) រៀបរាប់អំពីការវិភាគចិត្តសាស្រ្ត ។

ចំណុចសំខាន់នៃព្រះពុទ្ធវចនៈ គឺនៅត្រង់ព្រះពុទ្ធទ្រង់ដាស់តឿនមនុស្សឲ្យយកទ្រឹស្តី ឬ អំនួតទាំងឡាយនៃសាសនាដទៃ ទៅពិចារណា និង ពិសោធមើលសិនមុននឹងដាក់ចិត្តជឿតាម ។ ថ្វីត្បិតព្រះពុទ្ធទ្រង់បានរកឃើញព្រះធម្មវិន័យដោយព្រះ

---

[46] ក្នុងចំណោមវិន័យសម្រាប់ភិក្ខុនី គរុធម៌ ៨ គឺជាវិន័យដែលបន្ទាបបន្ថោកតម្លៃភិក្ខុនី ។ គរុធម៌ ៨ មានចែងនៅក្នុងភិក្ខុនីវិភង្គ នៅក្នុងព្រះត្រៃបិដកខ្មែរ សៀវភៅលេខ ១១ ទំព័រទី ២៦៦ ។ គរុធម៌ ៨ ទទួលរងការរិះគន់យ៉ាងខ្លាំង ព្រោះវាបានឆ្លុះបញ្ចាំងឲ្យឃើញនូវចេតនាមាក់ងាយសិទ្ធិស្ត្រីនៅក្នុងសង្គមឥណ្ឌា ។

អង្គឯងក៏ពិតមែន ក៏ទ្រង់ពុំបានបង្ខំពួកសាវកឲ្យជឿតាមពុទ្ធវចនៈទាំងងងឹតងងល់ (Blind Faith) ដែរ ។ ព្រះអង្គតែងដាស់តឿនក្រើនរំលឹកពុទ្ធសាសនិកជនឲ្យប្រើវិចារណញ្ញាណ ឬ សម្មាទិដ្ឋិ (ការយល់ត្រូវ) មុននឹងជឿអ្វីមួយ ។ សក្ខីភាពជាក់ស្តែងគឺនៅក្នុងកាលាមសូត្រ (Kalama Sutta) ដែលព្រះពុទ្ធទ្រង់បានរំលឹកពួកកាលាមជនឲ្យប្រើលក្ខណៈវិនិច្ឆ័យ ១០ យ៉ាងដើម្បីកាត់សេចក្តីរាល់ការអះអាង ឬ ទ្រឹស្តីរបស់មេដឹកនាំសាសនាទាំងឡាយ មុននឹងដាក់ចិត្តជឿលើទ្រឹស្តីទាំងនោះ ។ ព្រះពុទ្ធបានដាស់តឿនពួកកាលាមជនថា ៖ "... អ្នកកុំប្រកាន់ដោយគ្រាន់តែឮតាមគ្នា កុំប្រកាន់តាមពាក្យបរម្បរា កុំប្រកាន់ដោយបានឮថាដូច្នេះ កុំប្រកាន់ដោយអាងក្បួនតម្រា កុំប្រកាន់តាមហេតុដែលត្រិះរិះ កុំប្រកាន់ដោយកាត់ដំរួយផ្សៃផ្សំ កុំប្រកាន់ដោយគ្រាន់តែត្រិះរិះនូវអាការ កុំប្រកាន់ដោយសេចក្តីពេញចិត្តតាមការពិនិត្យសមនឹងសេចក្តីយល់ឃើញ កុំប្រកាន់ដោយយល់ថាមានសភាពគួរ (ជឿ) កុំប្រកាន់ដោយគិតថាសមណៈ (នេះ) ជាគ្រូរបស់យើង" ។[47][48]

តើអ្វីជាលក្ខណៈវិនិច្ឆ័យសម្រាប់កាត់សេចក្តីថា ទ្រឹស្តីរបស់មេដឹកនាំសាសនាណាមួយគ្មានតថភាព ឬសេចក្តីពិត? ព្រះពុទ្ធទ្រង់បានដាស់តឿនកាលាមជនថា ៖ "កាលណាបើអ្នកទាំងឡាយដឹងដោយខ្លួនឯងថា ធម៌ទាំងនេះជាអកុសល, ធម៌ទាំងនេះប្រកបដោយទោស, ធម៌ទាំងនេះអ្នកប្រាជ្ញតិះដៀល, ធម៌ទាំងនេះបុគ្គលបានសមាទានពេញលេញហើយ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តី

---

[47] ព្រះត្រៃបិដក សៀវភៅលេខ ៤១ ទំព័រទី ២១៨ (កាលាមសូត្រ) ។

[48] Don't go by reports, by legends, by traditions, by scripture, by logical conjecture, by inference, by analogies, by agreement through pondering views, by probability, or by the thought, "This contemplative is our teacher."

ទុក្ខ ... ក្នុងកាលនោះ អ្នកទាំងឡាយត្រូវលះបង់ចោលចេញ ˝ ។[49][50]

ចុះតើអ្វីទៅជាលក្ខណៈវិនិច្ឆ័យសម្រាប់កាត់សេចក្តីថា ទ្រឹស្តីរបស់មេដឹកនាំសាសនាណាមួយមានតថភាពឬសេចក្តីពិត? ព្រះពុទ្ធទ្រង់បានទូន្មានកាលាមជនបន្តទៀតថា ៖ ‶... កាលណាបើអ្នកដឹង ដោយខ្លួនឯងថា ធម៌ទាំងនេះជាកុសល, ធម៌ទាំងនេះមិនមានទោស, ធម៌ទាំងនេះដែលអ្នកប្រាជ្ញសរសើរ, ធម៌ទាំងនេះដែលបុគ្គលសមាទានពេញលេញហើយ, ប្រព្រឹត្តទៅដើម្បីជាប្រយោជន៍, ដើម្បីសេចក្តីសុខ... ក្នុងកាលនោះ អ្នកទាំងឡាយចូរដល់នូវធម៌ទាំងនោះហើយនៅ˝។ [51]

គួរឲ្យស្ងើចសរសើរណាស់ ដែលព្រះពុទ្ធទ្រង់បានដាស់តឿនពួកកាលាមជនជាង ២៥០០ ឆ្នាំកន្លងទៅហើយ ប៉ុន្តែសេចក្តីបង្រៀននេះនៅតែមានលក្ខណៈប្រាកដនិយម និង មានប្រយោជន៍សម្រាប់មនុស្សសម័យទំនើប យកធ្វើជាមាគ៌ាតម្រង់ជីវិតរបស់ពួកគេ ។ តាមរយៈពុទ្ធវចនៈនេះ យើងឃើញច្បាស់ថា ព្រះពុទ្ធទ្រង់បានផ្តល់សេរីភាពឲ្យបុគ្គលម្នាក់ៗពិចារណារាល់គំនិត, ការអះអាង ឬទ្រឹស្តីទាំងឡាយជាមុនសិន មុននឹងដាក់ចិត្តជឿ ឬ ផ្សព្វផ្សាយគំនិតទាំងនោះទៅដល់មនុស្សដទៃទៀត ។ ព្រះពុទ្ធទ្រង់បានប្រៀនប្រដៅសាវករបស់ទ្រង់ឲ្យពិចារណារាល់ពាក្យសម្តីរបស់ទ្រង់សិនមុននឹងជឿតាម ។

***

---

[49] ព្រះត្រៃបិដក សៀវភៅលេខ ៤១ ទំព័រទី ២១៨-២១៩ (កាលាមសូត្រ)

[50] When you know for yourselves that, these qualities are unskillful; these qualities are blameworthy; these qualities are criticized by the wise; these qualities, when adopted and carried out, lead to harm and to suffering — then you should abandon them.

[51] ព្រះត្រៃបិដក សៀវភៅលេខ ៤១ ទំព័រទី ២២២ (កាលាមសូត្រ)

# ៥. អរិយសច្ច ៤

អរិយសច្ច ៤ គឺជាបេះដូងនៃព្រះពុទ្ធសាសនា ហើយក៏ជាធម្មទេសនាលើកដំបូង ដែលព្រះពុទ្ធទ្រង់បានសម្តែងប្រោសបញ្ចវគ្គិយនៅព្រៃឥសិបតនៈ (Isipatana) ជិតក្រុងពារាណសី ។ ពាក្យថា អរិយសច្ចមានន័យថា ការពិតដ៏ប្រសើរឧត្តុង្គឧត្តម, ការពិតឥតល្អៀង ឬការពិតតរៀងពីដំបូងរហូតដល់ចុងបញ្ចប់ ។ រីឯពាក្យថា ចតុរារិយសច្ច គឺអរិយសច្ចទាំង ៤ ពោលគឺ ទុក្ខអរិយសច្ច, ទុក្ខសមុទយអរិយសច្ច, ទុក្ខនិរោធអរិយសច្ច និង ទុក្ខនិរោធគាមិនីបដិបទា (មគ្គអរិយសច្ច) ។

## ៥.១ ទុក្ខអរិយសច្ច

ទុក្ខ គឺអ្វីៗដែលផ្ទុយនឹង សុខ ។ ពាក្យមួយព្យាង្គនេះ មានន័យទូលំទូលាយពិបាកពណ៌នាណាស់ព្រោះ ទុក្ខ គ្មានរូបឲ្យយើងគូបាន, គ្មានទម្ងន់ឲ្យយើងថ្លឹងបាន ឬគ្មានទំហំនិងជំរៅឲ្យយើងវាស់បានទេ ។ ការពណ៌នាអំពីធ្មេញគឺជាការងាយស្រួល ប៉ុន្តែការអធិប្បាយអំពីការឈឺធ្មេញគឺជាការលំបាក ។ ទុក្ខពួនសម្ងំនៅក្នុងខ្លួនមនុស្សគ្រប់រូប ។ ប្រសិនបើមានរូប ពេលនោះប្រាកដជាមានទុក្ខ ។ បេសកកម្មរបស់ព្រះរាជកុមារ សិទ្ធត្ថ ដែលបានយាងទៅសាងផ្នួស គឺចង់ដឹងធម្មជាតិពិតរបស់ទុក្ខ និងវិធីចេញចាកទុក្ខ ។ នៅពេលព្រះអង្គទ្រង់បានត្រាស់ដឹង ព្រះអង្គទ្រង់បានសម្តែងថា ធម្មជាតិពិតនៃទុក្ខមាន ១២ កង ។

### ៥.១.១ ទុក្ខ ១២ កង

ទុក្ខ នៅក្នុងទុក្ខអរិយសច្ច ទាំង ១២ កង គឺ ៖

១. ជាតិទុក្ខ គឺទុក្ខព្រោះមានជាតិកំណើត (តាំងពីថ្ងៃបដិសន្ធិក្នុងផ្ទៃមាតា)

២. ជរាទុក្ខ គឺទុក្ខព្រោះចាស់គ្រាំគ្រា ជរាទ្រុឌទ្រោម,

៣. ព្យាធិទុក្ខ គឺទុក្ខព្រោះមានរោគាមកបៀតបៀនយាយី,

៤. មរណទុក្ខ គឺទុក្ខព្រោះមានសេចក្តីស្លាប់,

៥. សោកទុក្ខ គឺទុក្ខព្រោះស្តាយស្រណោះអ្វី ជាទីស្រឡាញ់ដែលព្រាត់ទៅ,

៦. បរិទេវទុក្ខ គឺទុក្ខព្រោះត្អូញត្អែរអំពីញាតិដែលបានព្រាត់ប្រាសទៅ,

៧. ទុក្ខទុក្ខ គឺទុក្ខលំបាកផ្លូវកាយផង ផ្លូវចិត្តផង, ទុក្ខត្រួតលើទុក្ខ,

៨. ទោមនស្សទុក្ខ គឺទុក្ខព្រោះឃ្នើសអារម្មណ៍ អាក់អន់ស្រពន់ចិត្ត,

៩. ឧបាយាសទុក្ខ គឺទុក្ខព្រោះចង្អៀតចង្អល់ចិត្តដល់សត្វ និង សង្ខារ ជាទីស្រឡាញ់ពេញចិត្ត ដែលប្រាសព្រាត់ទៅយូរហើយ,

១០. អប្បិយេហិសម្បយោគទុក្ខ គឺទុក្ខព្រោះជួបសត្វ និង សង្ខារដែលមិនត្រូវចិត្ត,

១១. បិយេហិវិប្បយោគទុក្ខ គឺទុក្ខព្រោះព្រាត់ប្រាសនិរាសចាកសត្វ និង សង្ខារដែលខ្លួនពេញចិត្ត,

១២. យម្បិច្ឆំ ន លភតិ តម្បិទុក្ខ គឺទុក្ខព្រោះប្រាថ្នា របស់អ្វីមួយហើយមិនបាននូវរបស់នោះដូចបំណង ។

ទុក្ខមានបរមត្ថន័យថា អសុក្រឹតភាព គឺភាពខ្វះចន្លោះ មិនល្អទាំងគ្រប់ (Imperfection), អនិច្ចភាព ឬភាពមិនអចិន្ត្រៃយ៍ (Impermanence), ភាពមិនពេញចិត្ត (Unsatisfactoriness), អនត្តភាព ឬភាពទទេឥតបានការ (Selflessness) ។

# ៥.២ ទុក្ខសមុទយអរិយសច្ច

ពាក្យថា សមុទយ បានសេចក្តីថា មូលហេតុ ឬ ប្រភពឫសគល់ ។ រីឯពាក្យទុក្ខសមុទយអរិយសច្ច មានន័យថា ឫសគល់ពិត ឬ កំណើតពិតនៃសេចក្តីទុក្ខ ។ កំណើត ឬ មូលហេតុដែលបណ្តាលឲ្យមានទុក្ខដល់មនុស្ស ឬ សត្វ មាន ២ គឺ អវិជ្ជា (Ignorance) និង តណ្ហា (Desire) ។

# ៥.២.១ អវិជ្ជា

អវិជ្ជា គឺជាពាក្យនៅក្នុងភាសាបាលី ឬ សំស្រ្កឹត ដែលមានន័យទូទៅថា ការមិនដឹងច្បាស់ ឬ សេចក្តីល្ងង់ ។ អវិជ្ជាប្រៀបដូចជាផ្ទាំងវាំងននដែលបាំងមិនឲ្យមនុស្សមើលឃើញវត្ថុសព្វយ៉ាង តាមសភាពពិតនៃវត្ថុទាំងនោះ ។ អត្ថន័យលំអិតរបស់ពាក្យ អវិជ្ជា គឺការមិនដឹង, មិនយល់ច្បាស់នូវវត្ថុ ៨ យ៉ាង គឺ ៖

១-ទុក្ខ : ពោលគឺ មនុស្សទាំងឡាយមិនយល់ច្បាស់នូវកងទុក្ខទាំង ១២ ក្នុងទុក្ខអរិយសច្ច ។

២-សមុទយ : ពោលគឺ មនុស្សទាំងឡាយមិនទាន់យល់ច្បាស់នូវមូលហេតុ ឬ ឫសគល់ដែលបណ្តាលឲ្យមានទុក្ខ ។

៣-និរោធ : ពោលគឺ មនុស្សទាំងឡាយមិនទាន់ស្គាល់ច្បាស់នូវទីរំលត់ទុក្ខ ឬព្រះនិព្វាន ។

៤-មគ្គ : ពោលគឺ មនុស្សទាំងឡាយមិនទាន់យល់ច្បាស់នូវផ្លូវឆ្ពោះទៅកាន់ទីរំលត់ទុក្ខ ឬ ហៅថា អដ្ឋង្គិកមគ្គ ឬ ផ្លូវប្រកបដោយអង្គ ៨ ។

៥-អតីតក្ខន្ធ : ពោលគឺ មនុស្សទាំងឡាយមិនទាន់យល់ច្បាស់នូវខន្ធទាំង ៥ ពីអតីតជាតិ ។

៦-អនាគតក្ខន្ធ : ពោលគឺ មនុស្សទាំងឡាយមិនទាន់យល់ច្បាស់នូវខន្ធទាំង ៥ នៅអនាគតជាតិ ។

៧-អតីតក្ខន្ធ និង អនាគតក្ខន្ធ : ពោលគឺ មនុស្សទាំងឡាយមិនទាន់យល់ច្បាស់នូវខន្ធទាំង ៥ ទាំងនៅក្នុងអតីតជាតិ និង អនាគតជាតិ ។

៨-បដិច្ចសមុប្បាទធម៌[52] : ពោលគឺ មនុស្សមិនទាន់យល់ច្បាស់នូវធម៌ដែល

---

[52] ព្រះត្រៃបិដក សៀវភៅលេខ ៣១ ទំព័រទី ៥៣ (បដិច្ចសមុប្បាទ) ។

ភ្ជាប់ហេតុទៅនឹងផលនៃការកើតស្លាប់ក្នុងវដ្តសង្សារ ។

នៅពេលបុគ្គលម្នាក់មិនយល់ច្បាស់នូវអវិជ្ជាទាំង ៨ នេះ ពេលនោះគាត់នឹងបណ្តោយឲ្យតណ្ហាកើតឡើងក្នុងចិត្តរបស់គាត់ ។ នៅពេលតណ្ហាកើតឡើង ពេលនោះទុក្ខក៏កើតឡើងដែរ ព្រោះតណ្ហាគឺជាប្រភពនៃទុក្ខ ។ បើតណ្ហាមានកម្លាំងតិច បុគ្គលនោះក៏មានទុក្ខតិច ។ ប្រសិនបើតណ្ហាមានកម្លាំងខ្លាំង បុគ្គលនោះក៏មានទុក្ខច្រើន ។ យើងបានដឹងហើយថា អវិជ្ជាបណ្តាលឲ្យកើតតណ្ហា ហើយតណ្ហាបណ្តាលឲ្យមានទុក្ខ ។ តើតណ្ហាជាអ្វី ?

## ៥.២.២ តណ្ហា

តណ្ហា[53] គឺ ភាពត្រេកត្រអាល, ការស្រេកឃ្លាន, ការប្រាថ្នាចង់បានអ្វីៗគ្រប់យ៉ាងមិនស្កប់ស្កល់ ។ តណ្ហាជាឫសគល់ ដែលនាំឲ្យមានទុក្ខគ្រប់ប្រការ និង នាំឲ្យមានកំណើតថ្មីបន្តគ្នា ។ ដរាបណាមនុស្សនៅមានតណ្ហា ដរាបនោះវដ្តសង្សារក៏បន្តមានជានិច្ច ។ នៅក្នុងធម្មចក្កប្បវត្តនសូត្រ[54] តណ្ហាត្រូវបានបែងចែកចេញជា ៣ គឺ កាមតណ្ហា, ភវតណ្ហា និង វិភវតណ្ហា ។

១-<u>កាមតណ្ហា</u>[55] គឺចំណង់ចំពោះកាម, ការប្រាថ្នាចង់បានមិនចេះស្កប់នៅក្នុងកាមគុណ[56] ឬ ការប្រាថ្នាក្នុងកាមភព ។ កាមគុណមាន ៥ ប្រការ គឺ រូប សម្លេង ក្លិន រស និង សម្ផស្ស ។[57]

---

[53] *Taṇhā, tṛṣṇā, trishna* : Craving, desire, thirst.

[54] ព្រះត្រៃបិដក សៀវភៅលេខ ៦ ទំព័រទី ៣១ (ធម្មចក្កប្បវត្តនសូត្រ) ។

[55] *Kama-tanha* : Sense-craving

[56] ដំណើរចំរើននៃសេចក្តីប្រាថ្នានូវអារម្មណ៍ទាំង ៥ គឺ រូប, សំឡេង, ក្លិន, រស, សម្ផស្ស ។

[57] ព្រះត្រៃបិដក សៀវភៅលេខ ២១ ទំព័រទី ១៦៣ (កាមគុណ ៥) ។

២-<u>*ភវតណ្ហា*</u>[58] គឺការប្រាថ្នាចង់បានអារម្មណ៍ទាំង ៦ គឺរូប, សំឡេង, ក្លិន, រស, សម្ផស្ស និង ធម្មារម្មណ៍ ឲ្យស្ថិតស្ថេរជាដរាប ។[59]

៣-<u>*វិភវតណ្ហា*</u>[60] គឺការប្រាថ្នាចង់បានអារម្មណ៍ទាំង ៦ គឺរូប, សំឡេង, ក្លិន, រស, សម្ផស្ស និង ធម្មារម្មណ៍ ឲ្យទៅជាសូន្យទទេ មិនកើតថ្មីទៀត ។

## ៥.៣ ទុក្ខនិរោធអរិយសច្ច

ការរលត់ផុតអស់នូវទុក្ខ ហៅថា និរោធ ហើយស្ថានភាពនៃចិត្តដែលបរិសុទ្ធផូរផង់ហៅថា និព្វាន[61]។ ត្រង់ចំណុចនេះមានន័យថា និព្វានមិនមែនជាទីកន្លែងដែលត្រូវធ្វើដំណើរទៅនោះទេ ។ ប៉ុន្តែនិព្វានគឺជាស្ថានភាពនៃចិត្ត ដែលមិនជាប់ជំពាក់លើគ្រឿងសៅហ្មងទាំងឡាយ ។ ដើម្បីបំបាត់ទុក្ខ អ្នកប្រតិបត្តិធម៌ទាំងឡាយត្រូវផ្តាច់ឫសគល់នៃទុក្ខ ពោលគឺ បំបាត់អវិជ្ជា និង រំលាយតណ្ហាឲ្យអស់ ប្រៀបដូចជាកសិករម្នាក់ជីករំលើងគល់ឈើ ដើម្បីកុំឲ្យដើមឈើនោះដុះបន្តទៀតដូច្នោះដែរ ។ នៅពេលឫសគល់នៃទុក្ខត្រូវបានកំទេចចោលអស់ ពេលនោះសេចក្តីសុខស្ងប់ដ៏ប្រណីត ក៏កើតឡើងដល់ចិត្ត ហើយចិត្តស្ងប់បែបនេះហៅថា និរោធ ។

## ៥.៤ មគ្គអរិយសច្ច

ពាក្យថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ឬ ទុក្ខនិរោធគាមិនី ឬ មគ្គសច្ច គឺជាផ្លូវ ឬ មធ្យោបាយពិតប្រាកដ ដែលនាំឲ្យអ្នកបដិបត្តិធម៌អាចរំដោះខ្លួនចេញផុត

---

58 *Bhava-tanha* : Craving to be

59 ព្រះត្រៃបិដក សៀវភៅលេខ ១៩ ទំព័រទី ១៣២ (សង្គីតិសូត្រ) ។

60 *Vibhava-tanha* : Craving not to be

61 Nirvana

ពីទុក្ខក្នុងសង្សារវដ្ត(62) ។ ដើម្បីសម្រេចនិព្វាន អ្នកបដិបត្តិធម៌ត្រូវប្រកាន់ផ្លូវកណ្តាល ឬមជ្ឈិមាបដិបទា(63) និង ប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួនតាម អដ្ឋង្គិកមគ្គ(64) ។ ផ្លូវកណ្តាលនេះស្ថិតនៅចន្លោះ អត្តកិលមថានុយោគ(65)ឬផ្លូវដ៏តឹងតែង ដែលអ្នកបដិបត្តិធម៌ធ្វើបាបខ្លួនឯងឲ្យឈឺចាប់រាងកាយឥតអំពើ និង កាមសុខល្លិកានុយោគ(66) ឬផ្លូវដ៏ធូររលុង ជំពាក់វាក់វិននឹងកាមកិលេស ដែលជាអំពើមិនថ្លៃថ្នូរ ឬគ្មានប្រយោជន៍ ។

## ៥.៤.១ អដ្ឋង្គិកមគ្គ

អដ្ឋង្គិកមគ្គ ឬផ្លូវប្រកបដោយអង្គ ៨ គឺ ៖

ក-**សម្មាទិដ្ឋិ** គឺការយល់ឃើញត្រូវ ។ ការយល់ឃើញត្រូវ គឺការមើលឃើញពិតអំពីជីវិតរបស់ខ្លួនឯងថា ជីវិតកើតឡើងដោយសារខន្ធ ៥ (រូបធម៌ និង នាមធម៌) ដែលមិនទៀងទាត់ (អនិច្ចំ), ប្រកបដោយទុក្ខ (ទុក្ខំ) និង មិនមានអត្តសញ្ញាណពិត (អនត្តា) ជាពិសេស គឺការយល់ឃើញត្រូវក្នុងអរិយសច្ចទាំង ៤ ។

ខ-**សម្មាសង្កប្បៈ** គឺការត្រិះរិះត្រូវ ។ ការត្រិះរិះត្រឹមត្រូវ គឺការប្រាថ្នាលះចោលការព្យាបាទ អំពើឃោរឃៅ និង ការបៀតបៀនជីវិតមនុស្ស និង សត្វ ។ ការត្រិះរិះត្រឹមត្រូវ ប្រកបដោយឆន្ទៈល្អ នាំឲ្យមនុស្សជួបផលល្អ និង សេចក្តីសុខចម្រើន ។ ជីវិតនៃមនុស្សម្នាក់ៗបានសុខ ឬទុក្ខ បានចម្រើន ឬវិនាស អាស្រ័យលើការត្រិះរិះគិតពិចារណា ។

គ-**សម្មាវាចា** គឺវាចាត្រូវ ។ សម្តីត្រឹមត្រូវ កើតឡើងដោយការត្រិះរិះត្រូវ ។ សម្តីសំខាន់ណាស់សម្រាប់មនុស្សម្នាក់ៗ ព្រោះសម្តីដែលនិយាយចេញមកអាចផ្តល់

---

62 *Saṃsāra*: A wandering through, endless cycle of death and rebirth, continuous flow, eternal cycle.
63 Middle Path.
64 The Eightfold Path.
65 *Attakilamatha:* Self-mortification.
66 *Kāmasukhallikānuyoga:* Devotion to the passions, to the pleasures.

សុខ ឬ ទុក្ខដល់ខ្លួន និង អ្នកដទៃ សមដូចបុរាណាចារ្យលោកពោលទុកថា "សំដីជាឯក លេខជាទោ" ។ សម្តីត្រឹមត្រូវជាសម្តីវៀរចាកវចីទុច្ចរិត ៤ យ៉ាងគឺ ៖

១-សំដីមិនពិត, កុហកបោកប្រាស់ (**មុសាវាទ**),

២-សំដីស៊កសៀត, ញុះញង់, បំបែកបំបាក់ (**បិសុណាវាទ**),

៣-សំដីជេរប្រទេច, ទ្រគោះបោះបោក, តិះដៀលដៀមដាម (**ផរុសវាទ**),

៤-សំដីឡេះឡោះ រោយរាយឥតប្រយោជន៍ (**សម្ផប្បលាបវាទ**) ។

ឃ-**សម្មាកម្មន្ត** គឺការងារត្រឹមត្រូវ ។ ការងារត្រឹមត្រូវគឺការប្រព្រឹត្តល្អ វៀរចាកកាយទុច្ចរិត ៣ យ៉ាង គឺ៖

១-ការសម្លាប់ជីវិតមនុស្ស និង សត្វ (**បាណាតិបាត**),

២-ការលួចទ្រព្យអ្នកដទៃ (**អទិន្នាទាន**),

៣. ការប្រព្រឹត្តខុសក្នុងផ្លូវកាម ដូចជាការសេពមេថុនជាមួយប្រពន្ធ ឬកូនរបស់គេជាដើម (**កាមេសុមិច្ឆាចារ**) ។

ង-**សម្មាអាជីវៈ** គឺការចិញ្ចឹមជីវិតត្រូវ ។ ការចិញ្ចឹមជីវិតត្រូវ មានន័យថាការចិញ្ចឹមជីវិតតាមគន្លងធម៌ និង ស្របតាមច្បាប់រដ្ឋ ឧទាហរណ៍ វៀរចាកការកេងប្រវ័ញ្ចការលួចប្លន់ ការលក់គ្រឿងញៀន ការជួញដូរផ្លូវភេទ ការសម្លាប់ជីវិតមនុស្សដើម្បីប្រាក់ ឬហៅថា មិច្ឆាជីវៈ (wrong livelihood) ។

ច-**សម្មាវាយាមៈ** គឺការព្យាយាមត្រូវ ។ ការព្យាយាមត្រូវ មានន័យថាការពុះពារឧបសគ្គឆ្ពោះទៅកាន់ឧត្តមជីវិត ។ យើងដឹងហើយថា ឧត្តមភាព[67] អរហត្តភាព និង

[67] Greatness

ពុទ្ធភាព សុទ្ធតែកើតឡើងដោយសារការប្រឹងប្រែង[68] ការប្តេជ្ញាចិត្ត[69] និង ការព្យាយាម[70] ។

ឆ-**សម្មាសតិ** គឺការតាំងសតិត្រូវ ។ ការតាំងសតិត្រូវ មានន័យថា ការប្រុងប្រយ័ត្ន និង ការរលឹកដឹងខ្លួនជានិច្ច ។ គោលបំណងនៃសមាធិ[71] គឺការតាំងសតិដើម្បីតាមឃ្លាំមើលចិត្តគ្រប់ខណៈពេល ។ ន័យម្យ៉ាងទៀត សមាធិ និង សតិ ជាប់ទាក់ទងគ្នាប្រៀបដូចជាទូក និង កំពង់ ។ បុគ្គលដែលអាចគ្រប់គ្រងខ្លួនឯងបានសុទ្ធតែមានការប្រុងប្រយ័ត្ន ដោយយកសតិធ្វើជាឆ្នាំ តាមឃ្លាំមើលអំពើរបស់ខ្លួនទាំងកាយ, វាចា និង ចិត្ត គ្រប់ពេលវេលា ។

ជ-**សម្មាសមាធិ** គឺការធ្វើសមាធិត្រឹមត្រូវ ។ ពាក្យថា "សមាធិត្រឹមត្រូវ" មានន័យថាការផ្ចង់ចិត្តឲ្យមូលលើអារម្មណ៍តែមួយ ។ នៅក្នុងព្រះពុទ្ធសាសនា សមាធិមានមុខងារ ២ យ៉ាងគឺ ៖

១-ធ្វើឲ្យស្ងប់អារម្មណ៍[72] តាមរយៈសមថភាវនា[73] ។

២-ការពង្រីកទស្សនញ្ញាណ ឲ្យមើលឃើញការពិតរបស់ជីវិតតាមរយៈវិបស្សនាភាវនា[74] ។

---

[68] Effort

[69] Determination

[70] Perseverance

[71] Meditation

[72] Calming of the mind

[73] Tranquility Meditation

[74] វិបស្សនាភាវនា (Insight Meditation) : មកពីពាក្យ "វិបស្សនា" ដែលមានន័យថា ឃើញរបស់ផងទាំងពួងតាមភាពពិត (insight into the true nature of reality, seeing things as they really are) និង ពាក្យ "ភាវនា" ដែលមានន័យថា ការចម្រើន, ការនឹកចំពោះត្រង់អារម្មណ៍ដ៏ល្អតែមួយដដែលៗឲ្យច្រើនៗ គឺនឹកហើយនឹកទៀតរឿយៗជាអនេក, ការស្ទឹងស្មាធិ ។

អរិយមគ្គ ឬ ផ្លូវប្រកបដោយអង្គ ៨ ត្រូវបានព្រះពុទ្ធឃោសាចារ្យ (Buddhaghosa) ហៅថា "វិសុទ្ធិមគ្គ"[75] ។ ព្រះពុទ្ធឃោសាចារ្យបានបង្រួមអរិយមគ្គទាំង ៨ នេះមកជា ៣ ផ្នែក គឺ សីល[76] សមាធិ[77] និង បញ្ញា[78] ។ ចំណែកការសិក្សា ឬ ប្រតិបត្តិសីល សមាធិ និង បញ្ញា មានឈ្មោះថា ត្រៃសិក្ខា (Threefold Training) ពោលគឺ ៖

**១-សីលសិក្ខា** (Morality, Virtue) គឺការអប់រំខ្លួនឲ្យមានកិរិយា មារយាទ ប្រកបដោយគុណធម៌ និង សីលធម៌ ។ សីលសិក្ខា មានកត្តា ៣ គឺ ៖

- សម្មាវាចា[79] គឺការពោលវាចាត្រឹមត្រូវ,
- សម្មាកម្មន្តៈ[80] គឺការធ្វើការងារត្រឹមត្រូវ,
- សម្មាអាជីវៈ[81] គឺការចិញ្ចឹមជីវិតត្រឹមត្រូវ ។

**២-សមាធិសិក្ខា** (Meditation, Mind) គឺការផ្ចង់ចិត្តឲ្យមូលនៅក្នុងអារម្មណ៍តែមួយ ។ សមាធិសិក្ខា មានកត្តា ៣ គឺ ៖

- សម្មាវាយាមៈ គឺការព្យាយាមត្រូវ,
- សម្មាសតិ គឺការតាំងសតិត្រូវ,
- សម្មាសមាធិ គឺការផ្ចង់ចិត្តត្រូវ ។

**៣-បញ្ញាសិក្ខា** (Wisdom) គឺការបណ្តុះលោកិយបញ្ញា (Mundane Wisdom)

---

75 *Visuddhimagga*: The Path of Purification

76 *Sila*: Morality, Virtue

77 *Samādhi, samāpatti*: Meditation, Meditative absorption

78 *Paññāa*: Wisdom

79 Right Speech

80 Right Action

81 Right Livelihood

និង លោកុត្តរបញ្ញា (Supra-mundane Wisdom) ដើម្បីរួចចាកទុក្ខ (មោក្ខធម៌) ។ បញ្ញាសិក្ខា មានកត្តា ២ គឺ ៖

– សម្មាទិដ្ឋិ គឺការយល់ត្រូវ,

– សម្មាសង្កប្បៈ គឺការត្រិះរិះត្រូវ ។

ត្រៃសិក្ខា គឺជាមជ្ឈិមាបដិបទា[82] ដែលជាមាគ៌ាកណ្តាលតែមួយគត់ ដែលព្រះពុទ្ធទ្រង់បានបដិបត្តិរហូតបានសម្រេចសម្មាសម្ពោធិញាណ ។ ផ្លូវកណ្តាលនេះស្ថិតនៅចន្លោះវិធីបដិបត្តិដ៏តឹងតែងហួសហេតុ និង វិធីបដិបត្តិដ៏ធូររលុង ។ ដូច្នេះយើងជាពុទ្ធបរិស័ទ គួរគប្បីនាំគ្នាធ្វើតាមមាគ៌ាដ៏ប្រសើរ ដែលព្រះបរមសាស្តាទ្រង់បានត្រួសត្រាយទុកឲ្យយើង ។

*

“អ្នកទាំងឡាយគប្បីធ្វើ ព្រះតថាគតទាំងឡាយ គ្រាន់តែជាអ្នកប្រាប់ ជនទាំងឡាយមានការពិនិត្យ បើបានដើរទៅហើយ នឹងរួចចាកចំណងរបស់មារបាន” ។[83]

**“You yourselves should make the effort; the Tathagatas (Buddhas) only can show the way. Those who practise the Tranquillity and Insight Meditation are freed from the bond of Mara.”** (Dhammapada 276)

“មិនត្រូវបណ្តោយឲ្យចរិតរបស់អ្នកដទៃបំផ្លាញចិត្តស្ងប់របស់អ្នកឡើយ” ។

**“Don’t let the behavior of others destroy your inner peace.”**
-- Tenzin Gyatso, 14th Dalai Lama (1935-Present)

***

---

[82] Middle Path, Middle Way

[83] ព្រះត្រៃបិដក សៀវភៅលេខ ៥២ ទំព័រទី ៧៨-៧៩ (ធម្មបទគាថា មគ្គវគ្គ)

# ៦. ទ្រឹស្តីកម្មផល

ទ្រឹស្តីកម្មផល ជាមូលដ្ឋានសំខាន់នៅក្នុងព្រះពុទ្ធសាសនា ។ ទ្រឹស្តីកម្មផល ទាក់ទងទៅនឹងហេតុ-ផលនៃបាតុភូតធម្មជាតិ និង ការកើតស្លាប់នៃសត្វលោក ។ នៅក្នុងលទ្ធិព្រាហ្មណ៍ ពួកព្រាហ្មណ៍បរិស័ទជឿថា ព្រះអាទិទេពគឺជាអ្នកបង្កើតអ្វីៗសព្វយ៉ាង ។ ចំណែកនៅក្នុងពុទ្ធសាសនា ពុទ្ធបរិស័ទជឿថា អ្វីៗសព្វយ៉ាងកើតឡើងតាមច្បាប់ធម្មជាតិ ។ តាមច្បាប់ធម្មជាតិ មនុស្ស និង សត្វ ផ្សំឡើងដោយខន្ធ ៥ ឬ បញ្ចក្ខន្ធ ដែលមានន័យថា គំនរទាំង ៥ (Five Aggregates) គឺ ៖

១-រូបក្ខន្ធ (Body Form) គឺរូបដែលផ្សំផ្គុំឡើងដោយធាតុទាំង ៤ គឺ ធាតុដី (បឋវីធាតុ) ធាតុទឹក (អាបោធាតុ) ធាតុភ្លើង (តេជោធាតុ) ហើយនិង ធាតុខ្យល់ (វាយោធាតុ) ។

២-វេទនាខន្ធ (Feeling) គឺការដឹងអារម្មណ៍ជាសុខ ឬជាទុក្ខ ។

៣-សញ្ញាខន្ធ (Perception) គឺធម្មជាតិចំណាំនូវអារម្មណ៍ ។

៤-សង្ខារក្ខន្ធ (Mental Formation) គឺធម្មជាតិតាក់តែងចិត្ត ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ ។

៥-វិញ្ញាណក្ខន្ធ (Consciousness) គឺធម្មជាតិដឹងនូវអារម្មណ៍ ។

រូបកាយមនុស្ស និង សត្វ គ្រាន់តែជាបញ្ចក្ខន្ធប៉ុណ្ណោះ ។ បញ្ចក្ខន្ធ ចែកចេញជា ២ គឺ រូបធម៌ និង នាមធម៌ ។ រូបក្ខន្ធជារូបធម៌ ចំណែកវេទនាខន្ធ, សញ្ញាខន្ធ, សង្ខារក្ខន្ធ និង វិញ្ញាណក្ខន្ធ ជានាមធម៌ ។ ទ្រឹស្តីពុទ្ធសាសនាបានពន្យល់អំពីកំណើតនៃជីវិតថា ដំណាក់កាលដំបូង បញ្ចក្ខន្ធផ្សំគ្នាឲ្យកើតមានជារូបរាងឡើង បន្ទាប់មករូបរាងទាំងនោះក៏រីកចំរើន រួចចាស់ទ្រុឌទ្រោម ហើយចុងក្រោយក៏រលាយបាត់ទៅវិញ (ស្លាប់) ។ ទ្រឹស្តីពុទ្ធសាសនាក៏បានបកស្រាយថា ដំណើរកើតជាថ្មីរបស់មនុស្ស

ឬសត្វ ចាប់ផ្តើមដោយខន្ធទាំង ៥ ផ្សំគ្នានៅក្នុងជីវិតថ្មីម្តងទៀត និង បន្តកំណើតរហូតគ្មានទីបញ្ចប់ ។ ក្នុងទស្សនៈនេះព្រះពុទ្ធទ្រង់បានចាត់ទុកការស្លាប់ថាជាខណៈមួយ ដែលខន្ធទាំង ៥ បែកធ្លាយ ហើយទ្រង់បានចាត់ទុកការកើតថាជាខណៈមួយដែលខន្ធទាំង ៥ ផ្សំផ្គុំជាថ្មីឡើងវិញ ។ ទ្រឹស្តីពុទ្ធសាសនាក៏អះអាងថា ទោះបីខន្ធទាំង ៥ បែកធ្លាយក៏ដោយ ក៏ថាមពលនៃកាយ និង ចិត្ត (physical and mental force) បន្តវត្តមាននៅក្នុងរូបមួយទៀត ឬសភាវៈថ្មី ដែលហៅថា ជីវិតថ្មី (rebirth) ។[84]

ទ្រឹស្តីពុទ្ធសាសនាអះអាងថា ថាមពលនៃជីវិតចាស់គឺជាកម្ម (action) ឬ មូលហេតុ (cause) ដែលបង្កឲ្យកើតជាផលអ្វីមួយ ។ ទ្រឹស្តីនេះក៏បានពន្យល់ដែរថា ជីវិតចាស់ និង ជីវិតថ្មីជាប់ទាក់ទងគ្នាយ៉ាងជិតស្និទ្ធ ។ ក៏ប៉ុន្តែជីវិតចាស់ និង ជីវិតថ្មី មានលំនាំដូចគ្នា និង ខុសគ្នាដោយអន្លើ ។ លំនាំដូចគ្នាគឺនៅត្រង់ជីវិតថ្មីទទួលផលនៃកម្មចាស់ (nature) ដែលជីវិតចាស់បានកសាង ។ រីឯលំនាំដែលខុសគ្នាគឺនៅត្រង់ជីវិតថ្មីទទួលការអប់រំថ្មីៗ (កម្មថ្មី, new actions, urture) ។

ទស្សនៈពុទ្ធនិយមបានពន្យល់ថា វិធីតែមួយគត់ ដែលអាចជួយមនុស្សឲ្យរួចផុតទុក្ខផ្សេងៗបាន គឺការមិនចាប់កំណើតជាថ្មីទៀត ។ ការមិនចាប់កំណើតថ្មីទៀតនេះ ជាគោលបំណងរបស់ព្រះរាជកុមារ សិទ្ធត្ថ ក្នុងការចេញសាងផ្នួស ។ ក្រោយការត្រាស់ដឹង ព្រះពុទ្ធទ្រង់បានសម្តែងថា ដរាបណាផលកម្មមិនទាន់រលត់ ដរាបនោះសត្វលោកនៅតែកើតស្លាប់ៗ ។ បើមិនចង់ឲ្យមានកំណើតថ្មីទៀត ពុទ្ធបរិស័ទ

---

84 "We have seen earlier that a being is nothing but a combination of physical and mental forces or energies. What we call death is the total non-functioning of the physical body. Do all these forces and energies stop altogether with the non-functioning of the body? Buddhism says 'No'. Will, volition, desire, thirst to exist, to continue, to become more and more, is a tremendous force that moves whole lives, whole existences, that even moves the whole world. This is the greatest force, the greatest energy in the world. **According to Buddhism, this force does not stop with the non-functioning of the body, which is death; but it continues manifesting itself in another form, producing re-existence which is called rebirth.**" *Quoted from "What the Buddha Taught" by Dr. Walpola Rahula.*

ត្រូវលុបបំបាត់កម្មឲ្យអស់ជាមុនសិន ។ នៅក្នុងបរិបទនេះ ពាក្យថា កម្ម រាប់បញ្ចូលទាំងកុសលកម្ម និង អកុសលកម្មដែលនាំឲ្យមានវិបាក ។

តើកម្មផលក្នុងពុទ្ធសាសនាមានន័យ និង លក្ខណៈដូចម្ដេចខ្លះ ? ពាក្យថា កម្ម មានន័យថា អំពើដែលបុគ្គលម្នាក់ៗធ្វើដោយកាយ វាចា និង ចិត្ត ដោយមានចេតនាជាដើមចម ។ ពាក្យថា ចេតនា គឺជាគំនិតដែលនាំចិត្តឲ្យភ្ជួកទៅដល់វត្ថុ ឬគោលបំណងអ្វីមួយ ។ ពាក្យថា ផល គឺផ្លែផ្កានៃអំពើ ឬកម្ម មានន័យថាប្រសិនបើកម្មល្អ ពេលនោះផលក៏ល្អ ប្រសិនបើកម្មអាក្រក់ ពេលនោះផលក៏អាក្រក់ដែរ ។ មនុស្សជាអ្នកធ្វើអំពើអ្វីមួយដោយខ្លួនឯង ហើយក៏ត្រូវទទួលផលនៃអំពើនោះដោយខ្លួនឯងដែរ ស្របតាមច្បាប់នៃកម្ម (Law of Karma) ។

ទ្រឹស្តីកម្មផលអះអាងថា មនុស្សមានរូបសម្ផស្សល្អឬអាក្រក់ មានបញ្ញា ឬល្ងិតល្ងង់, មានទ្រព្យសម្បត្តិ ឬក្រីក្រតោកយ៉ាក សុទ្ធតែជាផលនៃអំពើរបស់ពួកគេ ។ អំពើទាំងឡាយនឹងហុចផល នៅពេលណាមួយជាក់ជាមិនខាន គ្រាន់តែក្នុងពេលយូរឬឆាប់ប៉ុណ្ណោះ ។ ឧទាហរណ៍ អំពើខ្លះហុចផលភ្លាមៗក្នុងពេលបច្ចុប្បន្ន, អំពើខ្លះហុចផលក្នុងជាតិខាងមុខបន្ទាប់ពីជាតិបច្ចុប្បន្ន ហើយអំពើខ្លះទៀតហុចផលក្នុងជាតិជាលំដាប់តៗទៅទៀត ។

ក្នុងពុទ្ធសាសនា កម្មដែលមានចេតនា (intention) ជាដើមចម មាន ៣ យ៉ាង គឺ (១) កុសលកម្ម (Meritorious Action), (២) អកុសលកម្ម (Demeritorious Action) និង (៣) អព្យាកតកម្ម (Neutral Action) ។ កុសលកម្ម (កម្ម ស) គឺជាអំពើដែលហុចផលល្អ និង នាំឲ្យមានចិត្តសប្បាយរីករាយ ។ កុសលកម្ម មានកម្មបថ (កុសលកម្មបថ) ១០ ដែលមានកាយកម្ម ៣ (bodily action), វចីកម្ម ៤ (verbal action) និង មនោកម្ម ៣ (mental action) ។

# ៦.១ កុសលកម្ម

កុសលកម្ម គឺជាទង្វើល្អ ឬទង្វើដែលនាំមកនូវផលប្រយោជន៍ ។ ទង្វើល្អតាមផ្លូវកាយ ហៅថា កុសលផ្នែកកាយកម្ម ។ ទង្វើល្អតាមផ្លូវវាចា ហៅថា កុសលផ្នែកវចីកម្ម ។ ទង្វើល្អតាមផ្លូវចិត្ត ហៅថា កុសលផ្នែកមនោកម្ម ។

## ៦.១.១ កុសលផ្នែកកាយកម្ម

កុសលផ្នែកកាយកម្ម គឺជាទង្វើល្អខាងផ្លូវកាយ ដែលមាន ៣ យ៉ាងគឺ ៖

១-ការវៀរចាកការសម្លាប់ជីវិតមនុស្ស និង សត្វ (បាណាតិបាតា វេរមណី),

២-ការវៀរចាកការលួចទ្រព្យសម្បត្តិរបស់អ្នកដទៃ (អទិន្នាទានា វេរមណី),

៣-ការវៀរចាកការប្រព្រឹត្តខុសក្នុងកាម (កាមេសុមិច្ឆាចារា វេរមណី) ។

## ៦.១.២ កុសលផ្នែកវចីកម្ម

កុសលផ្នែកវចីកម្ម គឺជាទង្វើល្អខាងផ្លូវវាចា ដែលមាន ៤ យ៉ាងគឺ ៖

១-ការវៀរចាកការនិយាយភូតភរកុហក (មុសាវាទា វេរមណី),

២-ការវៀរចាកការនិយាយញុះញង់ ស៊កសៀត បំបែកបំបាក់អ្នកដទៃ (បិសុណាវាចា វេរមណី),

៣-ការវៀរចាកការពោលពាក្យអាក្រក់ ទ្រគោះបោះបោក ជេរប្រទេចអ្នកដទៃ (ផរុសវាទ វេរមណី),

៤-ការវៀរចាកការនិយាយផ្តេសផ្តាស សើចលេងរោយរាយឥតប្រយោជន៍ (សម្ផប្បលាបា វេរមណី) ។

## ៦.១.៣ កុសលផ្នែកមនោកម្ម

កុសលផ្នែកមនោកម្ម គឺជាទង្វើល្អខាងផ្លូវចិត្ត ដែលមាន ៣ យ៉ាង គឺ ៖

១-គំនិតមិនរំពៃ សម្លឹងចង់បានទ្រព្យសម្បត្តិរបស់អ្នកដទៃ មកធ្វើជាទ្រព្យ

សម្បត្តិរបស់ខ្លួន (អនភិជ្ឈា, *Anabhijjhā*),

២-គំនិតមិនចងគំនុំ គុំកួន ព្យាបាទ បៀតបៀន ឬប្រទូសរ៉ាយចំពោះអ្នកដទៃ (អព្យាបាទ, *Abyāpādo*),

៣-គំនិតយល់ឃើញត្រូវពិត តាមគន្លងធម៌ ថាមានបាបបុណ្យ គុណទោស (សម្មាទិដ្ឋិ, *Sammaditthi*) ។

អកុសលកម្ម គឺជាអំពើដែលហុចផលអាក្រក់ជាទណ្ឌកម្ម ឬហៅថា **កម្មខ្មៅ** ក៏បាន ។ អកុសលកម្ម មានកម្មបថ ១០ (អកុសលកម្មបថ) ពោលគឺ កាយកម្ម ៣, វចីកម្ម ៤ និង មនោកម្ម ៣ ។

# ៦.២ អកុសលកម្ម

អកុសលកម្ម គឺជាទង្វើអាក្រក់ ឬទង្វើដែលនាំមកនូវទុក្ខទោស ។ ទង្វើអាក្រក់ខាងផ្លូវកាយ ហៅថា អកុសលផ្នែកកាយកម្ម ។ ទង្វើអាក្រក់ខាងផ្លូវវាចា ហៅថា អកុសលផ្នែកវចីកម្ម ។ ទង្វើអាក្រក់ខាងផ្លូវចិត្ត ហៅថា អកុសលផ្នែកមនោកម្ម ។

## ៦.២.១ អកុសលផ្នែកកាយកម្ម

អកុសលផ្នែកកាយកម្ម គឺជាទង្វើអាក្រក់ខាងផ្លូវកាយ ដែលមាន ៣ យ៉ាងគឺ ៖

១-កិរិយាបៀតបៀនជីវិតមនុស្ស និង សត្វ (**បាណាតិបាតា**),

២-កិរិយាគៃបន្លំលួចទ្រព្យសម្បត្តិរបស់អ្នកដទៃ (**អទិន្នាទានា**),

៣-កិរិយាប្រព្រឹត្តខុសឆ្គងក្នុងកាម (**កាមេសុមិច្ឆាចារា**) ។

## ៦.២.២ អកុសលផ្នែកវចីកម្ម

អកុសលផ្នែកវចីកម្ម គឺជាទង្វើអាក្រក់ខាងផ្លូវវាចា ដែលមាន ៤ យ៉ាងគឺ ៖

១-ការនិយាយភូតភរកុហក (មុសាវាទា),

២-ការនិយាយញុះញង់ ស៊កសៀត បំបែកបំបាក់អ្នកដទៃ (បិសុណាវាចា),

៣-ការពោលពាក្យអាក្រក់,ជេរប្រទេចអ្នកដទៃ (ផរុសវាចា),

៤-ការនិយាយផ្តេសផ្តាស សើចលេងឥតប្រយោជន៍ (សម្ផប្បលាបា) ។

## ៦.២.៣ អកុសលផ្នែកមនោកម្ម

អកុសលផ្នែកមនោកម្ម គឺទង្វើអាក្រក់ខាងផ្លូវចិត្ត ដែលមាន ៣ យ៉ាងគឺ ៖

១-គំនិតរំពៃ សម្លឹងចង់បានទ្រព្យសម្បត្តិរបស់អ្នកដទៃ មកធ្វើជាទ្រព្យសម្បត្តិរបស់ខ្លួន (អភិជ្ឈា, *Abhijjhā*),

២-គំនិតចងគំនុំព្យាបាទ ប្រទូសរ៉ាយអ្នកដទៃ (ព្យាបាទោ, *Byāpādo*),

៣-គំនិតយល់ឃើញខុសការពិត ដោយគិតថាគ្មានបាបបុណ្យ គុណទោស (មិច្ឆាទិដ្ឋិ, *Micchāditthi*) ។

## ៦.៣ អព្យាកតកម្ម

អព្យាកតកម្ម (Neutral Action) មានន័យថា អំពើជាអព្យាក្រឹត ឬឧបេក្ខា ។ នៅក្នុងបរិបទនេះ មានតែអំពើរបស់ព្រះអរហន្តប៉ុណ្ណោះ ទើបអាចចាត់ចូលក្នុងអព្យាកតកម្ម ។ និយាយម្យ៉ាងទៀត អំពើរបស់ព្រះអរហន្ត គ្រាន់តែជាកិរិយាប៉ុណ្ណោះ ពោលគឺមិនមែនជាកុសលកម្ម ឬ អកុសលកម្មទេ ។ កិរិយារបស់ព្រះអរហន្តមិននាំឲ្យមានវិបាក ឬកំណើតថ្មីទេ ព្រោះវិបាកគឺជាផលដែលនាំឲ្យមានបដិសន្ធិចិត្ត ។

## ៦.៤ អនន្តរិយកម្ម

ពាក្យថា អនន្តរិយកម្ម(85) គឺជាអំពើបាបដ៏ធ្ងន់ធ្ងរទាំងឡាយ ដែលហុចផលមិនរំលងជាតិទី ២ ។ អនន្តរិយកម្ម មាន ៥ យ៉ាងគឺ ៖

១-ការសម្លាប់ម្តាយ (មាតុឃាត),

[85] *Anantariyakamma* : serious or heinous crimes which bring immediate results.

២-ការសម្លាប់ឪពុក (បិតុឃាត),

៣-ការសម្លាប់ព្រះអរហន្ត (អរហន្តឃាត),

៤-ការបំបែកសង្ឃ (សង្ឃភេទ),

៥-ការបង្ករបួសដល់រាងកាយរបស់ព្រះពុទ្ធ (លោហិតុប្បាទ) ។

នៅក្នុងទ្រឹស្តីកម្មផល ហេតុ និង ផលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងគ្នា ។ ទ្រឹស្តីនេះមានលក្ខណៈស្របនឹងទ្រឹស្តីវិទ្យាសាស្ត្រ ដែលអះអាងថាហេតុ និង ផល ជាប់ទាក់ទងគ្នាជានិច្ច ។ ទស្សនៈពុទ្ធនិយមបង្ហាញឲ្យឃើញថា កម្ម និង ផល ជាប់ទាក់ទងគ្នាជាដរាប លើកលែងតែអហោសិកម្ម[86] ប៉ុណ្ណោះដែលហួសកាលត្រូវហុចផល ។ ដោយសារ ហេតុ និង ផល ជាប់ទាក់ទងគ្នាជិតស្និទ្ធបែបនេះ ទើបព្រះពុទ្ធទ្រង់បានលើកយកទ្រឹស្តី ហេតុនិងផល នេះមកពន្យល់ពុទ្ធបរិស័ទឲ្យស្គាល់បុព្វហេតុនៃការកើតស្លាប់របស់មនុស្សសត្វ ។ ទ្រឹស្តីនេះហៅថា បដិច្ចសមុប្បាទ[87] ។

# ៦.៥ ទ្រឹស្តីបដិច្ចសមុប្បាទ

ទ្រឹស្តីបដិច្ចសមុប្បាទ អះអាងបញ្ជាក់ថាមានការជាប់ទាក់ទងយ៉ាងជិតស្និទ្ធរវាងហេតុ និង ផល ។ អ្វីៗដែលកើតមានឡើង គឺជាផលនៃហេតុខាងដើម ។ ទ្រឹស្តីបដិច្ចសមុប្បាទ បញ្ជាក់ថា "បើនេះមាន, នោះក៏មាន ។ បើនេះគ្មាន, នោះក៏គ្មាន ។ បើនេះរលត់, នោះក៏រលត់" ។[88] ដូច្នេះតាមទ្រឹស្តីពុទ្ធសាសនា គ្មានសភាវៈណាមួយកើតឡើងដាច់តែឯង ដោយគ្មានហេតុបច្ច័យទាក់ទង (ពឹងពាក់) គ្នានោះទេ ។ ចំពោះដំណើរកើតស្លាប់របស់មនុស្ស ទ្រឹស្តីបដិច្ចសមុប្បាទអះអាងថា មានការជាប់

---

[86] *Ahosikamma* : Kamma that is past, expired, or spent and will bear no further phala or fruit.
[87] Dependent Origination, Dependent Arising

[88] “This is, because that is. This is not, because that is not. This ceases to be, because that ceases to be.”

ទាក់ទងគ្នារវាងបុព្វហេតុទាំង ១២ ពោលគឺ ៖

១. អវិជ្ជា (Ignorance) ជាបច្ច័យឲ្យកើតសង្ខារ,

២. សង្ខារ (Formation) ជាបច្ច័យឲ្យកើតវិញ្ញាណ,

៣. វិញ្ញាណ (Consciousness) ជាបច្ច័យឲ្យកើតនាមរូប,

៤. នាមរូប (Mind and Matter) ជាបច្ច័យឲ្យកើតអាយតនៈ,

៥. អាយតនៈ (Sense) ជាបច្ច័យឲ្យកើតផស្សៈ,

៦. ផស្សៈ (Sensory Impingement) ជាបច្ច័យឲ្យកើតវេទនា,

៧. វេទនា (Sensation or Feeling) ជាបច្ច័យឲ្យកើតតណ្ហា,

៨. តណ្ហា (Craving, Thirst, Desire) ជាបច្ច័យឲ្យកើតឧបាទាន,

៩. ឧបាទាន (Attachment) ជាបច្ច័យឲ្យកើតភព,

១០. ភព (Existence) ជាបច្ច័យឲ្យកើតជាតិ,

១១. ជាតិ (Birth) ជាបច្ច័យឲ្យកើតជរា,

១២. ជរា (Old age) ជាបច្ច័យឲ្យកើតមរណៈ ។ មរណៈ នាំឲ្យកើតបរិទេវៈ (Lamentation) គឺការសោកសង្រេង, ទុក្ខទោមនស្ស, លំបាកវេទនា ។ល។

បើមានធាតុណាកើតឡើង ធាតុឯទៀតក៏កើតឡើងបន្តបន្ទាប់ ឧទាហរណ៍ បើអវិជ្ជាកើតឡើង វានឹងនាំឲ្យកើតសង្ខារ ។ សង្ខារនឹងនាំឲ្យកើតវិញ្ញាណ បន្តទៅទៀតហូរហែរហូតដល់នាំឲ្យមានជរា និង មរណៈ ។ ផ្ទុយទៅវិញ បើអវិជ្ជារលត់ សង្ខារក៏រលត់ ។ បើសង្ខាររលត់ វិញ្ញាណក៏រលត់ ហើយធាតុដទៃទៀតក៏រលត់តគ្នាអស់រលីងដែលហៅថា និរោធ ។ ពាក្យថា និរោធ គឺការរលត់អស់នូវឫសគល់នៃកំណើត ។ ទំនាក់ទំនងបែបនេះ ប្រៀបដូចជាច្រវាក់ ប្រទាក់គ្នាជារង្វង់មូលគ្មានចុងដើម ។ រង្វង់ច្រវាក់នេះមានចលនាវិលចុះឡើងគ្មានទីបញ្ចប់ ឬហៅថា សង្សារវដ្ត (*samsara*) ។

***

# ៧. ព្រះត្រៃលក្ខណ៍

ពាក្យ "ត្រៃលក្ខណ៍" មានន័យថា លក្ខណៈ ៣ ។ លក្ខណៈទាំងនោះគឺការប្រែប្រួល (អនិច្ច), ការមិនពេញចិត្ត (ទុក្ខ) និង ការគ្មានអត្តសញ្ញាណ (អនត្ត) ។ ជួនកាលត្រៃលក្ខណ៍ ត្រូវបានហៅថា សាមញ្ញលក្ខណៈ ព្រោះវាកើតឡើងជាធម្មតានៅលើមនុស្ស ឬសត្វគ្រប់រូប, គ្រប់វ័យ និង គ្រប់ពេលវេលា ។ ព្រះពុទ្ធសាសនាលើកយកត្រៃលក្ខណ៍ ទៅពន្យល់សភាពពិត នៃវត្ថុសព្វយ៉ាងនៅលើពិភពលោក និង ចក្រវាឡ ។ ចំណុចសំខាន់នៃត្រៃលក្ខណ៍គឺ វត្ថុសព្វយ៉ាងផ្លាស់ប្តូរគ្រប់ពេល (អនិច្ច) ។ មនុស្ស ឬ សត្វកំពុងរស់នៅក្នុងសភាពមិនពេញចិត្ត (ទុក្ខ) ។ វត្ថុ, រុក្ខជាតិ, សត្វ និង មនុស្សទាំងអស់គ្រាន់តែជារូបរាង ឬ កញ្ចប់នៃធាតុគីមីផ្សំដទៃទៀតជាច្រើនប្រភេទ ។ ដូច្នេះវត្ថុទាំងមានជីវិត និង គ្មានជីវិត គ្មានអត្តសញ្ញាណពិតប្រាកដដែលអាចឲ្យយើងសន្មតថាជាខ្លួនរបស់វាទេ (អនត្តា) ។ និយាយរួម ត្រៃលក្ខណ៍គឺជាគោលធម៌នៅក្នុងពុទ្ធសាសនា ដែលមនុស្សគួរតែសិក្សា និង ពិចារណាគ្រប់ពេលវេលា ដើម្បីជម្រុះអញនិយមចេញពីសន្តានចិត្ត ដូចពាក្យបុរាណថា "ទុក្ខកើតពីអញ អស់អញគឺអស់ទុក្ខ" ។

## ៧.១ អនិច្ច

មុននឹងយើងអាចយល់ទ្រឹស្តី "អនិច្ច" នៅក្នុងទស្សនវិជ្ជាពុទ្ធសាសនា យើងគួរយល់អត្ថន័យរបស់ពាក្យ "អនិច្ច" ជាមុនសិន ។ ពាក្យថា "អនិច្ច"(89) ផ្សំមកពីពាក្យ "អ" ប្រែថា មិន, អត់ និង ពាក្យ "និច្ច" មានន័យថា ទៀងទាត់ ឬ មិនប្រែប្រួល ។ រួមគ្នា ពាក្យ "អនិច្ច" មានន័យថា ការប្រែប្រួល ឬភាពមិនទៀងទាត់ ។ ទ្រឹស្តីវិទ្យាសាស្ត្រ

[89] Impermanence

និង ទ្រឹស្ដីពុទ្ធសាសនាបានយល់ស្របថា អ្វីៗសព្វយ៉ាងនៅលើពិភពលោក និង ក្នុងចក្រវាឡ កំពុងប្រែប្រួល ឥតឈប់ឈរ ។ ក៏ប៉ុន្ដែចំពោះវត្ថុដែលមានទំហំធំ ដូចជាភ្នំ សមុទ្រ ទន្លេ ស្ទឹង ផែនដី ឬ ចក្រវាឡ យើងមើលឃើញពួកវាហាក់ដូចជាគ្មានការប្រែប្រួលសោះ ។ ការពិត វត្ថុទាំងនោះកំពុងប្រែប្រួលគ្រប់វិនាទី ប៉ុន្ដែយើងមិនអាចមើលឃើញច្បាស់ដូចជាខ្សែទឹកហូរទេ ។ វត្ថុដែលមានរូបរាង (ទោះមានជីវិត ឬ អត់ជីវិត) នឹងប្រែទៅជាចាស់ទ្រុឌទ្រោម[90] បាត់រូបរាងដើម រួចក៏រលាយទៅជាវត្ថុធាតុដើម (elements) តាមពេលវេលាយូរ ឬ ឆាប់របស់វា ។ ឧទាហរណ៍ រូបរាងកាយមនុស្សនឹងប្រែផ្លាស់ជាចាស់ជរា មានរោគាព្យាធិ រួចហើយក៏ស្លាប់បាត់បង់ជីវិត ។ ទារកដែលទើបនឹងកើតបានមួយថ្ងៃ វាធំធាត់ពីមួយថ្ងៃទៅមួយថ្ងៃ និង បោះជំហានទៅរកសេចក្ដីស្លាប់គ្រប់វិនាទី ។ យើងបានឃើញថា វត្ថុ រុក្ខជាតិ សត្វ និង មនុស្សទាំងអស់ផ្សំឡើងពីធាតុគីមីផ្សេងៗ ដូចជា ខាបឹន (carbon), អុកស៊ីចិន (oxygen), ហៃដ្រូចិន (hydrogen), ណៃត្រូចិន (nitrogen) ។ល។ នៅពេលរុក្ខជាតិ សត្វ ឬ មនុស្សស្លាប់ រូបកាយទាំងឡាយ នឹងរលាយទៅជាធាតុផ្សំទាំងនោះវិញ ។ នៅក្នុងទ្រឹស្ដីពុទ្ធសាសនា ព្រះពុទ្ធទ្រង់បានសម្ដែងថា អ្វីៗទាំងអស់ក្នុងពិភពលោក ស្ថិតនៅក្រោមច្បាប់សាកលនៃអនិច្ចតាធម៌[91]ពោលគឺមិនទៀងទាត់ ឬប្រែប្រួលជានិច្ច ។ ព្រះពុទ្ធទ្រង់បានត្រាស់ថា ការប្រែប្រួលរបស់មនុស្ស ឬ សត្វ មានមូលហេតុមកពីកម្មផល ។ ដើម្បីឲ្យងាយយល់គំនិតនេះ យើងត្រូវស្គាល់ច្បាស់ថា តើជីវិតយើងជាអ្វី ? ជីវិតគឺជាបញ្ចក្ខន្ធដែលផ្សំឡើងពី **រូបធម៌** និង **នាមធម៌**[92] ។ ខន្ធទាំង ៥ ផ្សំគ្នាបង្កើតបានជារូបរាងកាយ ហើយរូបរាងកាយនេះក៏រីកលូតលាស់ រួចចាស់ទ្រុឌទ្រោម ហើយចុងក្រោយក៏ស្លាប់ ដែលនៅខណៈពេលនោះខន្ធទាំង ៥ នឹងបែកធ្លាយទៅវិញ ។ ទោះបី

---

[90] Decay
[91] Universal Law of Impermanence
[92] Physical and Mental Aggregates

រូបនាមរលាយទៅពិតមែន ប៉ុន្តែថាមពលនៃរូបធម៌ និង នាមធម៌មិនអស់ទៅជាមួយរូបរាងកាយនេះទេ ។ ថាមពលនេះគឺជាបច្ច័យតាក់តែងនូវសង្ខារដទៃ រួចក៏ផ្សំផ្គុំជាថ្មី បង្កើតបានជាជីវិតមួយទៀតហៅថា **កំណើតថ្មី** ។ ព្រះពុទ្ធទ្រង់បានឲ្យឈ្មោះថាមពលនៃរូបធម៌ និង នាមធម៌ ថា កម្ម ។ កម្មគឺជាមូលដ្ឋាននៃការប្រែប្រួល និង វិលកើតស្លាប់ គ្មានទីបញ្ចប់របស់មនុស្សសត្វ ឬហៅថាសង្សារវដ្ត ។

សង្សារវដ្ត មានគ្រឿងវិល (វដ្ត) ៣ គឺ កម្មវដ្ត, កិលេសវដ្ត និង វិបាកវដ្ត ។ កម្មវដ្ត គឺការវិលដោយកម្ម ។ វិបាកវដ្ត គឺការវិលដោយផល ។ កិលេសវដ្ត គឺការវិលដោយកិលេស ។ ទ្រឹស្តីពុទ្ធនិយមអះអាងថា កម្លាំងកម្ម គឺជាអ្នកទទួលខុសត្រូវធ្វើឲ្យមានការវិវឌ្ឍន៍នៃរូបកាយ, ចិត្ត និង បញ្ញារបស់មនុស្ស និង សត្វ ។ មនុស្សប្រែប្រួលពីកុមារតូចដែលមានរូបកាយ ចិត្ត និង បញ្ញាទន់ជ្រាយ ទៅជាមនុស្សធំពេញវ័យដែលមានរូបកាយ ចិត្ត និង បញ្ញារឹងមាំ ។ ឧទាហរណ៍ ពេលវេលាបានធ្វើឲ្យកុមារតូចម្នាក់ ធំធាត់ក្លាយជាមនុស្សចាស់អាយុ ៦០ ឆ្នាំ ។ តាមការពិត មនុស្សចាស់ម្នាក់នេះ មិនមែនជាកុមារតូចកាលពី ៦០ ឆ្នាំមុននោះទេ ហើយក៏មិនមែនជាមនុស្សដទៃដែរ ។ នៅក្នុងន័យដូចគ្នានេះ ប្រសិនបើមនុស្សម្នាក់ស្លាប់នៅទីនេះ រួចទៅកើតក្នុងជាតិថ្មីនៅទីកន្លែងដទៃ ពេលនោះគាត់មិនមែនជាតួខ្លួនមនុស្សដដែល ហើយក៏មិនមែនជាមនុស្សដទៃទៀតដែរ ។[93] ព្រះពុទ្ធទ្រង់បានអះអាងថា កាលណាបញ្ចក្ខន្ធផ្គុំផ្សំគ្នាជារូប ពេលនោះ**ជរា, ព្យាធិ និង មរណៈ** ក៏តាមមកជាមួយដែរ ។ ដូច្នេះ **ជរា, ព្យាធិ និង មរណៈ** គឺជាមរតកមិនប្រែប្រួលរបស់គ្រប់រុក្ខជាតិ, មនុស្ស និង សត្វ ។ សរុបសេចក្តីមក អ្វីៗគ្រប់យ៉ាងដែលធម្មជាតិបង្កើតឡើង តែងប្រែប្រួលឥតឈប់

93 "A child grows up to be a man of sixty. Certainly the man of sixty is not the same as the child of sixty years ago, nor is he another person. Similarly, a person who dies here and is reborn elsewhere is neither the same person, nor another (*na ca so na ca añño*)." *Quoted from "What the Buddha Taught" by Walpola Rahula*

ឈរ ស្របតាមអនិច្ចតាធម៌ ដែលជាច្បាប់ធម្មជាតិ ។

# ៧.២ ទុក្ខ

ទ្រឹស្តីពុទ្ធនិយមបានអះអាងថា ជីវិតក្នុងសង្សារវដ្តគឺជាជីវិតពោរពេញដោយការមិនពេញចិត្ត ។ ការមិនពេញចិត្តនេះហៅថាទុក្ខ ។ មនុស្ស និង សត្វគ្រប់រូបកំពុងរស់នៅជាមួយទុក្ខ ព្រោះពួកគេស្ថិតនៅក្រោមអំណាចនៃកម្ម ។ នៅក្នុងចតុរារិយសច្ច ពាក្យថា ទុក្ខ[94] គឺជាអរិយសច្ចទី ១ ដែលមនុស្សទូទៅមិនសូវស្គាល់ច្បាស់អត្ថន័យពិត ។ ជីវិតរបស់មនុស្សសាមញ្ញពោរពេញដោយសេចក្តីទុក្ខ ចំណែកឯជីវិតរបស់បុគ្គលដែលបានសម្រេចព្រះនិព្វាន គឺជាជីវិតប្រកបដោយបរមសុខ ។ ចំណុចនេះមិនមែនមានន័យថា ជីវិតរបស់មនុស្សសាមញ្ញគ្មានសេចក្តីសុខសោះនោះទេ គ្រាន់តែសេចក្តីសុខរបស់ពួកគេគឺជាសុខខ្លី ឬសេចក្តីសុខក្លែងក្លាយ ។ មនុស្សសាមញ្ញទទួលសេចក្តីសុខក្លែងក្លាយ តាមរយៈចំណីអាហារ, សម្លៀកបំពាក់, ទីជម្រក, ថ្នាំសង្កូវ, មធ្យោបាយធ្វើដំណើរ និង គ្រឿងកំសាន្តដូចជាកុន ល្ខោន របាំ ចម្រៀង ។ល។ វត្ថុទាំងនោះគ្រាន់តែជាគ្រឿងបោកប្រាស់ចិត្ត ដើម្បីបន្លប់ក្តីទុក្ខមួយរយៈប៉ុណ្ណោះ ។ បុរាណាចារ្យពោលថា "បើចង់បានសុខវែង ត្រូវលះបង់សុខខ្លី" ។ សុខខ្លីគឺកាមសុខ រីឯសុខវែងគឺបរមសុខ ដែលជាសុខគ្មានទីបញ្ចប់ ។ ដើម្បីជួបសុខវែង មនុស្សទាំងឡាយត្រូវខំប្រតិបត្តិតាមពុទ្ធវចនៈដោយចម្រើនសីល សមាធិ និង បញ្ញា ។ ពួកគេត្រូវយកត្រៃលក្ខណធម៌ មកពិចារណាថា រូបនេះមិនទៀងទាត់, រូបនេះប្រែប្រួល, រូបនេះពោរពេញទៅដោយទុក្ខ, រូបនេះមិនមែនជារបស់ខ្លួន, រូបនេះគ្មានប្រយោជន៍, រូបនេះគ្មានខ្លឹមសារ ។ ជាទូទៅយើងតែងឧទានពាក្យទាំងនោះជាភាសាបាលីថា "រូបំ អនិច្ចំ ទុក្ខំ អនត្តា" ។

---

[94] Dissatisfaction, unmet needs, suffering

# ៧.៣ អនត្តា

ពាក្យថា អនត្តា[95](non-self) មានន័យដើមថា មិនមែនខ្លួន ។ ឧទាហរណ៍ គ្រប់វត្ថុ, សត្វ និង មនុស្ស គ្មានអ្វីដែលគេអាចចាត់ទុកថាជាខ្លួន (អត្ត, អាត្ម័ន, self) ឬ ជាធាតុដើមពិតប្រាកដរបស់វា ។ ន័យម្យ៉ាងទៀត វត្ថុ, សត្វ និង មនុស្សទាំងអស់ គឺគ្រាន់តែជារូបរាងឬកញ្ចប់ផ្សេងៗនៃធាតុទាំងឡាយ ។ ធាតុទាំងឡាយនោះ គ្រាន់តែជាកញ្ចប់នៃធាតុល្អិតសុខុមដទៃទៀតយ៉ាងច្រើន ។ ការសិក្សាផ្នែកវិទ្យាសាស្ត្របានបង្ហាញឲ្យឃើញថា វត្ថុ, សត្វ និង មនុស្សទាំងអស់គឺជាបន្សំនៃធាតុគីមីដែលកើតឡើងក្នុងធម្មជាតិចំនួន ៩៨ ប្រភេទ ។ ពីដំបូង អ្នកប្រាជ្ញជនជាតិក្រិកសម័យបុរាណបានយល់ថា មនុស្សមិនអាចកាត់បំបែកធាតុគីមីទាំងនោះបានទេ ។ ដូច្នេះទើបពួកគេបានហៅធាតុគីមីទាំងនោះថា អាតូម (atom) ។ ពួកគេក៏បានចាត់ទុកថាអាតូម ជាឯកតា (unit) ឬធាតុចុងក្រោយដែលជាគ្រឿងផ្សំនៃវត្ថុ សត្វ និង មនុស្ស ។ ប៉ុន្តែអ្នកវិទ្យាសាស្ត្របច្ចុប្បន្នបានរកឃើញថា អាតូមផ្សំឡើងពីធាតុល្អិតសុខុម (subatomic particles) ច្រើនប្រភេទទៀត ដែលមនុស្សមិនអាចមើលឃើញដោយភ្នែកទទេ ។

ប្រសិនបើយើងពិចារណាពីជ្រុងជ្រោយនៃរូបសាស្ត្រ យើងឃើញថា វត្ថុ, សត្វ និង មនុស្សផ្សំឡើងពីធាតុទទេ ។ ទ្រឹស្តីពុទ្ធសាសនាក៏អះអាងដែរថា រូបរាងកាយដែលផ្សំឡើងពីបញ្ចក្ខន្ធ[96] ប្រែប្រួលគ្រប់វិនាទី ហើយក៏បែកធ្លាយទៅជាធាតុដើមវិញ ពោលគឺទឹក, ដី, ភ្លើង និង ខ្យល់ ។ ចំណុចនេះស្របនឹងពុទ្ធវចនៈថា ជីវិតមានភាពទទេ សូន្យឥតខ្លឹមសារ ។ គួរកត់សម្គាល់ថា ធាតុទទេ គឺជាអត្ថន័យទីមួយ

---

95 Emptiness, Selflessness

96 រូប, វេទនា, សញ្ញា, សង្ខារ , វិញ្ញាណ [The Five Aggregates]

នៃពាក្យថា សុញ្ញតា ឬភាពសូន្យ ។

អត្ត ឬខ្លួន ដែលមនុស្សគ្រប់គ្នាស្រឡាញ់លើសអ្វីៗទាំងអស់ គ្រាន់តែជាស្រមោលបោកប្រាស់ភ្នែកមនុស្សប៉ុណ្ណោះ ។ តាមការពិត មនុស្សមិនអាចមើលឃើញ ឬប៉ះពាល់ អត្ត ឬខ្លួន ទេ ។ បើយើងពិនិត្យមើល អត្ត នេះដោយមំសចក្ខុ (ភ្នែក) នោះយើងជឿថាមាន អត្ត ពិតមែន ។ ប៉ុន្តែប្រសិនបើយើងពិនិត្យមើល អត្ត នោះដោយបញ្ញាចក្ខុ (ការវិភាគ) នោះយើងមិនអាចរកឃើញ អត្ត ថាកំពុងស្ថិតនៅទីណាឡើយ ។ អត្ត គ្រាន់តែជាបណ្តុំនៃបញ្ចក្ខន្ធប៉ុណ្ណោះ ។

ដើម្បីងាយយល់អំពីទ្រឹស្តីអនត្តានេះ ព្រះពុទ្ធទ្រង់បានលើកយកផ្ទះមួយខ្នងមកធ្វើជាឧទាហរណ៍ ។ ព្រះពុទ្ធទ្រង់បានសួរសាវកថា តើអ្វីទៅជាផ្ទះពិតប្រាកដ ? ចូរអ្នកចង្អុលទៅមើល ? អ្នកអាចចង្អុលបានតែជញ្ជាំង ដំបូល ទ្វារ បង្អួច ។ល។ ប៉ុន្តែឯណាទៅជាផ្ទះពិតប្រាកដនោះ ? ការពិតគឺគ្មានតួផ្ទះពិតប្រាកដទេ ។ ពាក្យថា ផ្ទះ គឺគ្រាន់តែជាសម្មតិនាមមួយតាងឲ្យបណ្តុំ (Whole, Totality) នៃគ្រឿងផ្សំរបស់ផ្ទះប៉ុណ្ណោះ ។ ព្រះពុទ្ធទ្រង់បានត្រាស់សួរទៀតថា តើអ្វីទៅជាអត្តពិតប្រាកដ ដែលអ្នករាល់គ្នាស្រឡាញ់ដ៏លើសលប់នោះ? តើវាជារាងកាយរបស់អ្នកឬ? តើវាជាអារម្មណ៍របស់អ្នកឬ? តើវាជាចិត្តរបស់អ្នកឬ? តើវាជាព្រលឹងនៃអ្នកឬ? សាសនាខ្លះបានអះអាងថា អត្ត មានពិតប្រាកដមែន? ប្រសិនបើដូច្នោះមែន តើព្រលឹងនៃបុគ្គលម្នាក់កំពុងនៅកន្លែងណា? តើពួកគេពិតជាធ្លាប់បានជួបប្រទះវាមែនឬ? យោងតាមទ្រឹស្តីពុទ្ធនិយម អត្ត គ្មានវត្តមាន (Not exist) ទេ ។ វាគ្រាន់តែជាការសន្មតតែប៉ុណ្ណោះ ។ ដូច្នេះ ទើបពាក្យថា "អនត្តា" មានន័យថា មិនមានខ្លួន (non-selfl) ឬអត្តសញ្ញាណដែលជាធាតុផ្សំដើមពិតប្រាកដ ។

នៅក្នុងពុទ្ធសម័យ ពួកព្រាហ្មណ៍ និង មនុស្សច្រើននាក់ បានជឿថាមានអាត្ម័នពិតប្រាកដ ចំណែកព្រះពុទ្ធទ្រង់អះអាងថាគ្មានអាត្ម័ន ឬអត្ត ឬព្រលឹងទេ ។

ដូច្នេះហើយទើបមានអាចារ្យព្រាហ្មណ៍ម្នាក់ឈ្មោះ អគ្គិវេស្សនៈ (Aggivessana) បានចូលមកសួរដេញដោល តស៊ូមតិជាមួយនឹងព្រះពុទ្ធ ។ អាចារ្យព្រាហ្មណ៍នោះបានចាប់ផ្តើមដោយពោលសម្តីអួតថា "ខ្ញុំហ៊ានអះអាងដោយគ្មានស្ទាក់ស្ទើរក្នុងចិត្តថា រូបកាយរបស់ខ្ញុំ គឺជារបស់ខ្ញុំ ។ វេទនា សញ្ញា សង្ខារ វិញ្ញាណ របស់ខ្ញុំគឺជារបស់ខ្ញុំ" ។ ព្រះពុទ្ធទ្រង់បានឆ្លើយតបថា "ប្រសិនបើអ្នកអួតអាងដូច្នេះមែន តថាគតសុំឲ្យអ្នកបកស្រាយបញ្ហាមួយ ។ ឧទាហរណ៍ តើស្តេច បសេនទិ នៃនគរកោសល (King Pasenadi of Kosala) ឬស្តេច អជាតសត្តុ នៃនគរ មគធៈ (Ajattasattu of Magadha) គឺជាស្តេចផែនដីនៃនគររបស់ព្រះអង្គមែនទេ? តើស្តេចទាំងនោះមានអំណាចអាចសម្លាប់នរណាម្នាក់ដែលសមនឹងស្លាប់ឬទេ? តើស្តេចទាំងនោះមានអំណាចអាចដាក់ទណ្ឌកម្មនរណាម្នាក់ ដែលសមទទួលទណ្ឌកម្មឬទេ? តើស្តេចទាំងនោះមានអំណាចអាចនិរទេសនរណាម្នាក់ ដែលសមនឹងនិរទេសឬទេ? អាចារ្យ អគ្គិវេស្សនៈ បានឆ្លើយវិញថា ស្តេចបសេនទិ ឬ អជាតសត្តុ ត្រូវតែមានអំណាចអាចសម្រេចកិច្ចការទាំងនោះពិតមែន ។ ព្រះពុទ្ធទ្រង់បានបន្តសួរថា បើដូច្នេះមែន តើអ្នកយល់យ៉ាងណាដែរ ចំពោះការអះអាងថា រាងកាយនេះជារបស់ខ្ញុំ? តើអ្នកអាចអះអាងបានទេថា អ្នកមានអំណាចលើរាងកាយរបស់អ្នក? តើអ្នកអាចបញ្ជារាងកាយរបស់អ្នកឲ្យក្លាយទៅជាយ៉ាងនេះ ឬយ៉ាងនោះបានឬទេ? នៅពេលអ្នកពោលអះអាងថា វេទនា សញ្ញា សង្ខារ និង វិញ្ញាណ គឺជារបស់អ្នក តើអ្នកអាចបញ្ជាវាបានឬទេ ? ប្រសិនបើអ្នកមិនអាចបញ្ជាវាបានទេ ហេតុអ្វីបានជាអ្នកអួតអាងថា អ្នកគឺជាម្ចាស់លើខ្លួនរបស់អ្នក? ព្រះពុទ្ធទ្រង់បានបកស្រាយថា អត្ត ដែលផ្សំឡើងពីបញ្ចក្ខន្ធ មិនមែនជាតួខ្លួនពិតទេ (Real Self) ។ បុគ្គលគ្រប់រូបគ្មានអំណាចគ្រប់គ្រងលើខ្លួនរបស់គាត់ឡើយ ។ ដូច្នេះខ្លួនគាត់មិនមែនជាកម្មសិទ្ធិរបស់គាត់ទេ ។

សព្វថ្ងៃ មនុស្សភាគច្រើនកំពុងត្រូវមហិច្ឆតាដឹកច្រមុះ ឲ្យវង្វេងវង្វាន់ភ័ន្តច្រឡំ

ថា លោកិយនេះមានអញ, លោកិយនេះមិនប្រែប្រួល, លោកិយនេះមិនមានទុក្ខ ។ ដោយសារមិច្ឆាទិដ្ឋិនេះ ពួកគេកំពុងប្រកាន់អញនិយមជាប់ក្នុងចិត្ត ព្រោះពួកគេមិនស្គាល់អនត្តាធម៌ ។ ពួកគេប្រកាន់ថាលោកិយមិនប្រែប្រួល ដោយសារពួកគេមិនស្គាល់អនិច្ចតាធម៌ ។ ពួកគេប្រកាន់ថាលោកិយមិនមានទុក្ខ ដោយសារពួកគេមិនស្គាល់ទុក្ខតាធម៌ ។ នេះជាមូលហេតុនាំឲ្យកើតមានភាពវឹកវរ ចលាចលនៅក្នុងសង្គម ។ ទីបំផុត ក៏កើតមានសង្គ្រាមលោក បំផ្លិចបំផ្លាញជីវិតមនុស្ស បង្កឲ្យមានសោកនាដកម្មគួរឲ្យសង្វេគ ។ ដូច្នេះ ដើម្បីចៀសវាងកុំឲ្យក្លាយជាទាសករនៃតណ្ហា មនុស្សគ្រប់រូបគួរពិចារណាត្រៃលក្ខណធម៌ ឲ្យបានល្អិតល្អន់ ។ ជាពិសេស យើងត្រូវពិចារណាថា នៅពេលយើងកើតមក យើងមានតែដៃទទេប៉ុណ្ណោះ ។ ដូច្នេះ មុននឹងយើងស្លាប់ទៅវិញ យើងគួរបន្សល់ទុកអ្វីមួយ ដែលជាប្រយោជន៍សម្រាប់មនុស្សលោក ។ ប្រសិនបើមិនអាចបន្សល់អ្វីជាប្រយោជន៍ សម្រាប់មនុស្សជំនាន់ក្រោយទេ សូមមេត្តាកុំបន្សល់កាកសំណល់ និង បំផ្លាញបរិស្ថាន ហើយទុកឲ្យមនុស្សជំនាន់ក្រោយជាអ្នកទទួលខុសត្រូវ កើបសម្អាតសម្រាមរបស់យើង ។

*

"ភាពល្ងង់ខ្លៅជាឫស និង ដើមនៃទង្វើអាក្រក់ទាំងអស់ ។"

**"Ignorance, the root and stem of all evil."**

-- Plato (428 BC - 348 BC)

"អនាគតរបស់អ្នកអាស្រ័យលើអ្វីៗដែលអ្នកធ្វើនៅពេលបច្ចុប្បន្ន ។"

**"The future depends on what you do today."**

-- Mahatma Gandhi (1869-1948)

***

# ៨. សំសារៈ

ទ្រឹស្តីកម្មផលអះអាងថា ការវិលកើតស្លាប់របស់មនុស្ស និង សត្វជាប់ទាក់ទងយ៉ាងជិតស្និទ្ធិជាមួយកម្ម និង ផល ។ រីឯពាក្យថា សំសារៈ គឺជាដំណើរអន្ទោលទៅមក ឬដំណើរអន្ទោលកើតស្លាប់ជានិច្ច ។ រុក្ខជាតិ, មនុស្ស និង សត្វទាំងអស់ស្ថិតនៅក្នុងសំណាញ់ **បដិច្ចសមុប្បាទធម៌** ដែលបង្ហាញទំនាក់ទំនងរវាងហេតុ និង ផលដូចរង្វង់ច្រវាក់ ។ អ្វីៗទាំងអស់នៅលើពិភពលោកមានការជាប់ទាក់ទងគ្នា និង ពឹងពាក់គ្នាទៅវិញទៅមក[97] ជាចាំបាច់ ។ រង្វង់ច្រវាក់នៃការកើត, ស្លាប់, កើតថ្មីនោះបន្តវិលចុះឡើង ហៅថា សង្សារវដ្ត[98] ដែលមានចែងផងដែរនៅក្នុងគម្ពីរវេទតាំងពីមុនពុទ្ធសម័យម្ល៉េះ ។

## ៨.១ ជីវិតទាំង ៣ ជាតិ

ទ្រឹស្តីពុទ្ធនិយម បានអះអាងដូចទ្រឹស្តីវេទនិយមដែរថា ជីវិតរបស់មនុស្ស និង សត្វ ជាប់ទាក់ទងតាំងពីអតីតជាតិ រហូតមកដល់បច្ចុប្បន្នជាតិ និង ទៅអនាគតជាតិ ។ អតីតជាតិ (Former Life) មានន័យថាជីវិតមនុស្ស ឬជីវិតសត្វនៅក្នុងពេលកន្លងផុតទៅឬជាតិមុន ។ បច្ចុប្បន្នជាតិ (Present Life) មានន័យថាជីវិតមនុស្ស ឬជីវិតសត្វនៅក្នុងពេលកំពុងរស់នៅសព្វថ្ងៃ ។ អនាគតជាតិ (Future Life) មានន័យថា ជីវិតមនុស្ស ឬជីវិតសត្វនៅក្នុងពេលអនាគត បន្ទាប់ពីជីវិតសព្វថ្ងៃនេះរលត់ផុតទៅ ។ ទ្រឹស្តីសំសារៈក៏បានអះអាងផងដែរថា អតីតជាតិជាប់ទាក់ទងមកដល់បច្ចុប្បន្នជាតិ ហើយបច្ចុប្បន្នជាតិជាប់ទាក់ទងទៅដល់អនាគតជាតិ ។ ទំនងដូចគ្នានេះ បុព្វហេតុនៃជាតិទាំង ៣ ជាបុព្វហេតុទាំង ១២ នៅក្នុងទ្រឹស្តីបដិច្ចសមុប្បាទ ។

---

[97] Interrelated and interdependent actions
[98] An ever revolving wheel (birth-death-rebirth)

# អតីតជាតិ

(១) **អវិជ្ជា** (Ignorance) នាំឲ្យកើតសង្ខារ,

(២) **សង្ខារ** (Formations) នាំឲ្យកើតវិញ្ញាណ ។

# បច្ចុប្បន្នជាតិ

(៣) **វិញ្ញាណ** (Consciousness) នាំឲ្យកើតនាមរូប,

(៤) **នាមរូប** (Psycho-Physicalty) នាំឲ្យកើតអាយតនៈ,

(៥) **អាយតនៈ** (Sense) នាំឲ្យកើតផស្សៈ,

(៦) **ផស្សៈ** (Sensory Impingement) នាំឲ្យកើតវេទនា,

(៧) **វេទនា** (Sensation) នាំឲ្យកើតតណ្ហា,

(៨) **តណ្ហា** (Craving, Thirst, Desire) នាំឲ្យកើតឧបាទាន,

(៩) **ឧបាទាន** (Attachement) នាំឲ្យកើតភព,

(១០) **ភព** (Existence) នាំឲ្យកើតជាតិ ។

# អនាគតជាតិ

(១១) **ជាតិ** (Birth) នាំឲ្យកើតជរា មរណៈ,

(១២) **ជរា, មរណៈ** (Old age, death) នាំឲ្យមានជីវិតថ្មី (Rebirth)។

# ៨.២ កម្ម

ពាក្យថា "កម្ម" មានន័យយ៉ាងងាយថា អំពើ ។ នៅក្នុងពុទ្ធសាសនា ពាក្យថា "កម្ម" សំដៅលើ "កម្ម" ដែលមាន ចេតនាជាមូលដ្ឋាន ។ បើគ្មានបំណង ឬចេតនាទេ ក៏គ្មាន "កម្ម" ដែរ ។ ច្បាប់នៃកម្មចែងថា ដើមឈើដែលមានលក្ខណៈផ្សេងគ្នា អាស្រ័យមកពីគ្រាប់ពូជនៃដើមឈើនោះៗ ដែលមានធម្មជាតិផ្សេងគ្នា ។ ក្នុងន័យដូចគ្នា មនុស្សមានឧបនិស្ស័យជោគជតាផ្សេងពីគ្នា ក៏ព្រោះកម្មរបស់ខ្លួនដែលបាន

ធ្វើទុក្ខក្នុងអតីតជាតិខ្លះ ក្នុងបច្ចុប្បន្នជាតិខ្លះ ។ បើបុគ្គលម្នាក់ប្រព្រឹត្តកុសលកម្ម ដោយកាយ, វាចា ឬចិត្ត ពេលនោះបុគ្គលនោះនឹងមានសោមនស្សរីករាយជាក់ជាប្រាកដដូចស្រមោលអន្ទោលតាមប្រាណ ។[99] ផ្ទុយទៅវិញ ប្រសិនបើបុគ្គលម្នាក់ប្រព្រឹត្តអកុសលកម្មដោយកាយ, វាចា ឬចិត្ត ពេលនោះបុគ្គលនោះនឹងជួបសេចក្តីទុក្ខជាក់ជាប្រាកដ ប្រៀបដូចជាកង់រទេះវិលតាមជើងសត្វដែលអូសរទេះ ។[100] ព្រះពុទ្ធទ្រង់បានដាស់តឿនឲ្យបរិស័ទទាំងឡាយយកចិត្តទុកដាក់លើចិត្ត ព្រោះចិត្តគឺជានាយសារថី ជាអ្នកបញ្ជារាងកាយឲ្យធ្វើសកម្មភាពគ្រប់យ៉ាង ដូចពាក្យថា "ធម៌ទាំងឡាយមានចិត្តជាប្រធាន" ។[101]

ទោះបីអតីតជាតិ និង បច្ចុប្បន្នជាតិ មានទំនាក់ទំនងគ្នាក៏ដោយ ក៏អតីតជាតិ និង បច្ចុប្បន្នជាតិ មិនដូចគ្នាទាំងស្រុងទេ ។ ចំណុចដូចគ្នាខ្លះៗនោះគឺនៅត្រង់ បច្ចុប្បន្នជាតិជាផលនៃកម្មពីអតីតជាតិ ។ ចំណុចមិនដូចគ្នាខ្លះៗនោះគឺនៅត្រង់ នៅក្នុងបច្ចុប្បន្នជាតិ មនុស្សទទួលបានការអប់រំថ្មីបន្ថែមទៀត ។ ចំណុចសំខាន់គឺនៅត្រង់ នៅក្នុងបច្ចុប្បន្នជាតិ មនុស្សមានឱកាសកែច្នៃជីវិតរបស់ខ្លួនឲ្យបានចម្រើនរុងរឿងសម្រាប់បច្ចុប្បន្ន និង អនាគតជាតិ ។ សក្ខីភាពជាក់ស្តែងមួយគឺ ព្រះពុទ្ធទ្រង់បានបំពេញបរមត្ថបារមីធម៌ច្រើនជាតិរហូតដល់ជាតិចុងក្រោយ ដែលព្រះអង្គទ្រង់បានត្រាស់ដឹងនូវសម្មាសម្ពោធិញាណ ។

ការបានកើតជាមនុស្សគឺចាត់ទុកថាជាសំណាងល្អមួយ ហើយការមានរូបកាយពេញលក្ខណៈក៏រាប់ថាជាសំណាងល្អមួយទៀត ។ លើសពីនោះទៀត ការមាន

---

[99] If a man speaks or acts with a pure mind, then joy follows him as his own shadow.

[100] If a man speaks or acts with an impure mind, sufferings follow him as the wheel of the cart follows the beast that draws the cart.

[101] គម្ពីរព្រះត្រៃបិដក សៀវភៅលេខ ៥២ ទំព័រទី ២១ (ធម្មបទគាថា) [All experiences (or mental states) are preceded by mind they have mind as their master they are produced by mind.]

ខួរក្បាលល្អដែលអាចឲ្យយើងចេះពិចារណារកហេតុផល គឺពិតជាសំណាងខ្ពស់បំផុត ។ វាមិនមែនជាការសំខាន់ទេដែលបានកើតជាមនុស្សនៅក្នុងវណ្ណៈទាប ឬខ្ពស់នោះ ការសំខាន់គឺមនុស្សត្រូវខំស្វែងរកចំណេះដឹងទូទៅ និង បន្តអប់រំចិត្តរបស់ខ្លួនឲ្យបរិសុទ្ធផូរផង់ ប្រកបដោយមេត្តា ករុណា មុទិតា និង ឧបេក្ខា ។ ព្រះពុទ្ធទ្រង់ពុំបានចាត់ទុកវណ្ណៈ (caste system) ជាចំណុចសំខាន់ឡើយ ព្រោះព្រះអង្គទ្រង់ឈ្វេងយល់[102]ថា ការប្រកាន់មាំលើរឿងវណ្ណៈ គឺជាដើមចមនៃអំពើអយុត្តិធម៌ និងជាឧបសគ្គចម្បងដែលនាំឲ្យមនុស្សខ្វះចិត្តករុណា ។ ព្រះពុទ្ធទ្រង់បានបង្រៀនឲ្យមនុស្សទូន្មានចិត្តគ្រប់វិនាទី ។ ប្រសិនបើមនុស្សម្នាក់ៗស្គាល់ចិត្តរបស់ខ្លួនច្បាស់ ស្គាល់បដិច្ចសមុប្បាទ ស្គាល់ត្រៃលក្ខណ៍ និង ស្គាល់ច្បាស់ថាអ្វីៗទាំងអស់គឺជាសុញ្ញតា ពេលនោះពួកគេនឹងគ្មានការប្រកាន់វណ្ណៈ គ្មានការជិះជាន់ គ្មានការកេងប្រវ័ញ្ច និង គ្មានអំពើអយុត្តិធម៌ក្នុងសង្គមឡើយ ។

ទោះបីមនុស្សមានកាយសម្បទាខុសប្លែកពីសត្វក៏ដោយ ប្រសិនបើមនុស្សគ្មានវិចារណញ្ញាណទេ មនុស្សក៏មិនខុសគ្នាពីសត្វតិរច្ឆានដែរ ។ មនុស្សប្រើប្រាស់បញ្ញាសម្រាប់ពិចារណាឲ្យដឹងថា តើអំពើណាជាអំពើល្អ, អាក្រក់, បាប, បុណ្យ,គុណ ឬទោស ។ រីឯពួកសត្វ វាគ្មានប្រាជ្ញា ឬធម្មសញ្ញាសម្រាប់ពិចារណាទេ ។ មនុស្សដែលគ្មានវិចារណញ្ញាណ គ្មានអ្វីខុសប្លែកពីសត្វទេ ព្រោះថា "ការឃ្លានអាហារ, ការងងុយដេក, ការភ័យខ្លាច និង ការរួមសង្វាស ហេតុទាំង ៤ នេះ មនុស្ស និង សត្វមានដូចគ្នា ។ ធម្មសញ្ញា គឺប្រាជ្ញាយល់ខុស-ត្រូវ, ល្អ-អាក្រក់ ធ្វើមនុស្សឲ្យប្លែកពីសត្វ ។ មនុស្សដែលគ្មានគុណធម៌មិនខុសអ្វីពីសត្វឡើយ" ។[103]

---

102 រំពឹងគិតយល់ដោយប្រាជ្ញាដ៏ភ្លឺថ្លា។

103 ពាក្យស្លោកសំស្ក្រឹត ស្រង់ចេញពីសៀវភៅ "ស្រីហិតោបទេស" (*Hitopadesha*)។

# ៨.៣ មនុស្ស ៤ ពួក

ទ្រឹស្តីពុទ្ធសាសនាបានបែងចែកមនុស្សទូទៅជា ៤ ពួក ពោលគឺ ៖

១. មនុស្សទេវោ គឺជាមនុស្សដែលមានរូបកាយជាមនុស្ស, ចិត្តជាទេវតា និង មានសីលធម៌ខ្ពង់ខ្ពស់ ។

២. មនុស្សមនុស្សោ គឺជាមនុស្សដែលមានរូបកាយជាមនុស្ស, មានចិត្តជាមនុស្ស និង មានមនុស្សធម៌ ។

៣. មនុស្សបេតោ គឺជាមនុស្សដែលមានរូបកាយជាមនុស្សធម្មតា ប៉ុន្តែមានចិត្តជាប្រេត ។

៤. មនុស្សតិរច្ឆានោ គឺជាមនុស្សដែលមានរូបកាយជាមនុស្ស ប៉ុន្តែមានចិត្តកាចសាហាវ ឃោរឃៅដូចសត្វតិរច្ឆាន ។

វណ្ណៈរបស់មនុស្សគ្មានគុណតម្លៃបន្តិចសោះ ប្រសិនបើមនុស្សម្នាក់នោះប្រព្រឹត្តអំពើណាមួយដោយគ្មានការពិចារណា ។ មនុស្សមកពីវណ្ណៈ[104]ណាក៏ដោយ ឬមានឋានៈជាអ្វីក៏ដោយ (ស្តេច, មន្ត្រី ឬរាស្ត្រសាមញ្ញ) នឹងត្រូវបានចាត់ចូលក្នុងជំពូកមនុស្សបេតោ ឬ មនុស្សតិរច្ឆានោ ប្រសិនបើក្នុងពេលបច្ចុប្បន្ន ពួកគេប្រព្រឹត្តអំពើអាក្រក់, សាងបាបកម្ម, កាចសាហាវយង់ឃ្នង ។ ប៉ុន្តែប្រសិនបើពួកគេប្រព្រឹត្តអំពើល្អ, សាងកុសលធម៌, សាងបារមីធម៌, បំពេញទសពិធរាជធម៌ នោះពួកគេនឹងត្រូវបានចាត់ចូលក្នុងជំពូកមនុស្សមនុស្សោ ឬមនុស្សទេវោ ។

ទ្រឹស្តីពុទ្ធនិយមបានអះអាងថា អំពើរបស់មនុស្សក្នុងពេលបច្ចុប្បន្ននឹងនាំឲ្យមានវិបាកនៅអនាគតជាតិ ដូចខាងក្រោម ៖

– មនុស្សទេវោ នឹងកើតជាទេវតា,

---

[104] ព្រាហ្មណ៍, ក្សត្រ, វេស្សៈ, សូទ្រ ។

– មនុស្សមនុស្សោ នឹងកើតជាមនុស្ស,
– មនុស្សបេតោ នឹងកើតជាប្រេត,
– មនុស្សតិរច្ឆានោ នឹងកើតជាសត្វតិរច្ឆាន ។

មនុស្ស ឬ សត្វសុទ្ធតែមានចិត្តជាអ្នកបញ្ជា ឬដឹកនាំ ។ ចិត្តបញ្ជាមនុស្សឲ្យប្រព្រឹត្តអំពើអបាយមុខផ្សេងៗ ។ មានពាក្យស្លោកមួយថា មនុស្សពិបាកអប់រំទូន្មានចិត្តរបស់ខ្លួនណាស់ ។ ការពិតចិត្តមានសភាពស្អាតផូរផង់ពីកំណើត ប៉ុន្តែប្រសិនបើឧបក្កិលេស (imperfection) ចូលទៅរុំព័ទ្ធចិត្ត ពេលនោះចិត្តនឹងបញ្ជាមនុស្សឲ្យប្រព្រឹត្តនូវអកុសលកម្មផ្សេងៗ ។ ហេតុនេះ ទើបពុទ្ធសាសនិកជនខិតខំហាត់ពត់លត់ដំចិត្ត ខិតខំជម្រះមន្ទិលសៅហ្មង ខិតខំប្រព្រឹត្តនូវកុសលកម្ម ដើម្បីកសាងខ្លួនឲ្យបានកើតជាមនុស្ស ឬជាទេវតានៅអនាគតជាតិ ។ ពុទ្ធបរិស័ទជឿថា ដើម្បីអប់រំចិត្តឲ្យស្អាតបរិសុទ្ធ ពួកគេត្រូវខំធ្វើបុណ្យ ឬបុញ្ញកម្ម ។ តើបុណ្យគឺជាអ្វី? តើអ្វីជា តួបុណ្យ ? តើធ្វើបុណ្យដើម្បីអ្វី ?

*

"ឫសគល់នៃទុក្ខគឺឧបាទាន" ។

**"The root of suffering is attachment."**

-- The Buddha

"ខ្ញុំចូលចិត្តសាសនាដែលបង្រៀនអំពីសេរីភាព, សមភាព និង ភាតរភាព" ។

**"I like the religion that teaches liberty, equality and fraternity."**

-- Dr. B. R. Ambedkar (1891-1951)

***

# ៩. បុណ្យ

ពាក្យថា "បុណ្យ" ឬ "បុញ្ញ" មានន័យថា គុណជាតិជាគ្រឿងជម្រះសន្តានចិត្ត កុសល អំពើល្អ ឬសេចក្តីសុខ ។ ការធ្វើបុណ្យ គឺការធ្វើសេចក្តីល្អខាងផ្លូវកាយ វាចា និង ចិត្តឲ្យកើតមានដោយកិច្ច និង ទំនងផ្សេងៗ ។[105] ចំណុចសំខាន់នៃការធ្វើបុណ្យ គឺការសំអាតចិត្តឲ្យស្អាតបរិសុទ្ធផូរផង់ ប្រាសចាកអកុសលធម៌ ដែលមាន លោភៈ[106] ទោសៈ[107] និង មោហៈ[108] ជាអកុសលមូល ឬជាឫសគល់ពិតនៃអកុសលធម៌ ។ ដូច្នេះហើយបានជាពុទ្ធបរិស័ទខំប្រឹងធ្វើបុណ្យ ដើម្បីជម្រះអកុសលធម៌ចេញពីសន្តានចិត្ត ។ បុណ្យមានចេតនាជាតួ ។ ការកសាងកុសលកម្មផ្សេងៗ សុទ្ធតែសម្រេចដោយចិត្ត និង មានចិត្តជាប្រភពផ្តួចផ្តើម ។ ជាដំបូងបុណ្យ ត្រូវកើតឡើងក្នុងចិត្ត រួចកើតឡើងក្នុងវាចា និង សកម្មភាពខាងរាងកាយ ។ បុណ្យដែលកើតឡើងក្នុងចិត្ត ហៅថា មនោកម្ម ។ បុណ្យដែលកើតឡើងក្នុងផ្លូវកាយ ហៅថា កាយកម្ម ។ រីឯបុណ្យដែលកើតឡើងក្នុងផ្លូវវាចា ហៅថា វចីកម្ម ។

បុណ្យ មានហេតុ ឬ លក្ខណៈ ៣ យ៉ាងគឺ ៖

១. បសាទៈ  គឺមានចិត្តជ្រះថ្លា,

២. សំវេគៈ  គឺមានចិត្តសង្វេគតក់ស្លុត,

៣. តេសុចរិតា  គឺមានចិត្តស្អាតបរិសុទ្ធដោយកាយ, វាចា, ចិត្ត ។

---

[105] វចនានុក្រមខ្មែរ ១៩៦៩

[106] ការលោភលន់

[107] ការខឹងក្រេវក្រោធ

[108] ការវង្វេង

# ៩.១ បសាទៈ

ទ្រឹស្តីពុទ្ធសាសនាអះអាងថា ប្រសិនបើមនុស្សម្នាក់មានចិត្តរីករាយជ្រះថ្លា ចំពោះកុសលធម៌ ពេលនោះគាត់នឹងលះបង់ចិត្តកំណាញ់ (មច្ឆរិយៈ) បរិច្ចាគទ្រព្យសម្បត្តិទៅជាទានដើម្បីជាប្រយោជន៍ដល់បុគ្គលដែលគួរទទួល និង ជាប្រយោជន៍ដល់សង្គមជាតិ ។ ទង្វើនេះគឺជាហេតុនាំឲ្យកើតបុណ្យ ។

# ៩.២ សំវេគៈ

ទ្រឹស្តីពុទ្ធសាសនាអះអាងថា មនុស្សដែលមិនប្រមាទ គឺជាមនុស្សដែលចេះពិចារណាឃើញថា ជីវិតមនុស្ស និង ជីវិតសត្វ ជាសភាវៈមិនទៀងទាត់ ។មនុស្សត្រូវពិចារណាជានិច្ចថា សេចក្តីស្លាប់នឹងកើតមានដល់ខ្លួនគ្រប់ពេលវេលា ។ ពួកគេគួរតែនឹកអាណិតមនុស្សសត្វដែលកំពុងរងទុក្ខលំបាកវេទនា ព្រោះថា ទង្វើនេះក៏ជាហេតុមួយនាំឲ្យកើតបុណ្យផងដែរ ។ លើសពីនោះទៀត ពួកគេគួរតែធ្វើអំពើល្អដល់មនុស្ស និង សត្វទូទៅឲ្យបានច្រើនតាមអាចធ្វើបាន ។

# ៩.៣ តេសុចរិតា

ទ្រឹស្តីពុទ្ធនិយមបានអះអាងថា កាយ វាចា និង ចិត្ត ជាប្រធាននៃបុណ្យ ។ សេចក្តីបរិសុទ្ធខាងផ្លូវកាយ ផ្លូវវាចា និង ផ្លូវចិត្ត ជាហេតុឲ្យកើតបុណ្យ ។រីឯបុញ្ញកម្មដោយសេចក្តីបរិសុទ្ធទាំងកាយ វាចា និង ចិត្ត នាំឲ្យបានអានិសង្សច្រើន ។ ដើម្បីឲ្យបុណ្យកើតឡើងបាន គឺត្រូវឆ្លងកាត់ដំណាក់កាល ៣ គឺ ៖

១. បុញ្ញហេតុ គឺហេតុរបស់បុណ្យ,

២. បុញ្ញកិរិយា គឺកិរិយាជាបុណ្យ,

៣. បុញ្ញផល គឺផលរបស់បុណ្យ ។

# ៩.៤ បុញ្ញហេតុ

ទ្រឹស្តីពុទ្ធនិយមអះអាងថា ចិត្តគឺជាប្រភពរបស់បុណ្យ ។ ចិត្តដែលប្រកបដោយអលោភៈ អទោសៈ និង អមោហៈជាកុសលមូលនៃបុណ្យ ។ ដើម្បីលះបង់សេចក្តីលោភលន់ (លោភៈ) មនុស្សត្រូវបរិច្ចាគទ្រព្យសម្បត្តិដើម្បីធ្វើទាន, ដើម្បីលះបង់សេចក្តីក្រេវក្រោធ (ទោសៈ) មនុស្សត្រូវរក្សាសីល ត្រូវចេះសន្តោស និង ឲ្យអភ័យដល់មនុស្ស ឬសត្វដែលបានធ្វើខុសចំពោះខ្លួន ។ ដើម្បីលះបង់សេចក្តីវង្វេង (មោហៈ) មនុស្សត្រូវចំរើនភាវនាដើម្បីអប់រំចិត្តឲ្យស្អាតផូរផង់ ។ ទង្វើទាំងនេះគឺជាហេតុរបស់បុណ្យ ឬ បុញ្ញហេតុ ។

# ៩.៥ បុញ្ញកិរិយា

ពាក្យថា បុញ្ញកិរិយា គឺការធ្វើបុណ្យ ឬអំពើដែលជាបុណ្យ ។ រីឯពាក្យថា បុញ្ញកិរិយាវត្ថុ មានន័យថា ទីតាំង ឬទីកើតនៃបុណ្យ ឬកន្លែងដែលនាំឲ្យកើតជាបុណ្យជាកុសល ។ បុញ្ញកិរិយាវត្ថុមាន ១០ យ៉ាង គឺ ៖

១. ទានមយៈ គឺបុណ្យកើតមានព្រោះការឲ្យទាន,

២. សីលមយៈ គឺបុណ្យកើតមានព្រោះការរក្សាសីល,

៣. ភាវនាមយៈ គឺបុណ្យកើតមានព្រោះការចម្រើនភាវនា,

៤. អបចាយនមយៈ គឺបុណ្យកើតមានព្រោះការគោរពកោតក្រែង ឱនលំទោនជឿស្តាប់បុគ្គលដែលគួរគោរព,

៥. វេយ្យាវច្ចមយៈ គឺបុណ្យកើតមានព្រោះការខ្នះខ្នែងខ្វល់ខ្វាយចាត់កិច្ចការបុណ្យ ឬបម្រើក្នុងការធ្វើបុណ្យ,

៦. ធម្មទេសនាមយៈ គឺបុណ្យកើតមានព្រោះការសម្តែងធម្មទេសនាត្រឹមត្រូវតាមពុទ្ធវចនៈ,

៧. ធម្មស្សវនមយៈ គឺបុណ្យកើតព្រោះការស្តាប់យល់អត្ថន័យធម្មទេសនា,

៨. បត្តិទានមយៈ គឺបុណ្យកើតមានព្រោះការឧទ្ទិសបុណ្យដល់អ្នកដទៃ,

៩. បត្តានុមោទនាមយៈ គឺបុណ្យកើតមានព្រោះការត្រេកអរទទួលយកចំណែកបុណ្យដែលគេឧទ្ទិសមកខ្លួន,

១០. ទិដ្ឋុជុកម្មមយៈ គឺបុណ្យកើតមានព្រោះការយល់ឃើញត្រឹមត្រូវតាមផ្លូវពិត ឬធ្វើប្រាជ្ញាជាសម្មាទិដ្ឋិឲ្យកើតមានក្នុងសន្តានចិត្ត ។

# ៩.៦ បុញ្ញផល

ពាក្យថា បុញ្ញផល គឺជាផលរបស់បុណ្យដែលមនុស្សខំប្រឹងសន្សំទុក ។ ការសន្សំបុណ្យ នឹងនាំមកនូវសេចក្តីសុខត្រជាក់ត្រជុំ ។ បុញ្ញសម្បទា ប្រែថា ការដល់ព្រម ឬការបរិបូណ៌ដោយបុណ្យ ដែលមាន ៥ យ៉ាងគឺ ៖

១. ញាតិសម្បទា គឺបរិបូណ៌ដោយញាតិ,

២. អារោគ្យសម្បទា គឺបរិបូណ៌ដោយសុខភាព,

៣. ភោគសម្បទា គឺបរិបូណ៌ដោយទ្រព្យសម្បត្តិ,

៤. សីលសម្បទា គឺបរិបូណ៌ដោយសីល,

៥. ទិដ្ឋិសម្បទា គឺបរិបូណ៌ដោយសម្មាទិដ្ឋិ ។

# ៩.៧ ការធ្វើបុណ្យ និង ការលាងបាប

ពាក្យថា "ការធ្វើបុណ្យ" និង "ការលាងបាប" មានន័យខុសគ្នាទាំងស្រុង ។ ការធ្វើបុណ្យ គឺការធ្វើសេចក្តីល្អខាងផ្លូវកាយ, វាចា និង ចិត្តឲ្យកើតមានដោយកិច្ចល្អផ្សេងៗ ។ ការធ្វើបុណ្យមិនមែនមានន័យថាការយកកុសលកម្មទៅទូទាត់ជាមួយអកុសលកម្ម ដើម្បីឲ្យរួចគ្នាដូចជាការយកប្រាក់ទៅសងបំណុលនោះឡើយ ។ អំពើល្អ និង អំពើអាក្រក់មិនអាចលុបលាង ឬ សងគ្នាបានទេ ។ ពុទ្ធបរិស័ទខំធ្វើបុណ្យ ឬ

កុសលកម្មដើម្បីបំភ្លេចអកុសលកម្មកុំឲ្យកើតមានក្នុងចិត្ត ។ ទ្រឹស្ដីពុទ្ធនិយមអះអាងថា បុណ្យជាកុសលចិត្ត ហើយកុសលចិត្តនាំឲ្យមានសេចក្ដីសុខ ។ ដូច្នេះ ទើបពុទ្ធបរិស័ទនាំគ្នាធ្វើបុណ្យ ព្រោះពួកគាត់ប្រាថ្នាចង់បានសេចក្ដីសុខ ។ ប្រសិនបើបុគ្គលធ្វើអំពើល្អច្រើន ពេលនោះគាត់នឹងទទួលបានផលល្អច្រើន ។ ផ្ទុយទៅវិញ បើគាត់ធ្វើអំពើអាក្រក់ច្រើន ពេលនោះគាត់នឹងទទួលបានផលអាក្រក់ច្រើនដែរ ។

តើពាក្យថា "ការលាងបាប" មានអត្ថន័យយ៉ាងណា ? ពាក្យថា "បាប" មានអត្ថន័យថា អំពើលាមក, អំពើអាក្រក់ ឬអំពើពុំប្រសើរ ។ នៅក្នុងទស្សនៈរបស់ព្រះពុទ្ធសាសនា ពាក្យថា "បាប" សំដៅទៅដល់អំពើខាងផ្លូវកាយ, វាចា និង ចិត្ត ប្រកបដោយលោភៈ, ទោសៈ និង មោហៈ ។ ពាក្យថា "លាង" មានអត្ថន័យថា ជម្រះ, សម្អាតដោយវត្ថុរាវមានទឹកជាដើម ។ ដូច្នេះពាក្យថា "ការលាងបាប" គឺជាការលាងជម្រះបាបឲ្យអស់ពីរូបកាយ ឬសម្បកក្រៅ ។ សូមបញ្ជាក់ថា នៅក្នុងទ្រឹស្ដីពុទ្ធនិយមគ្មានពាក្យថា "ការលាងបាប" ដូចជាក្នុងសាសនាផ្សេងៗទេ ។

ទស្សនៈរបស់គ្រិស្ដសាសនា ដែលយកគម្ពីរបរិសុទ្ធ (Bible) ជាគោល[109] បានអះអាងថា ពីដំបូងគ្មានអំពើបាបនៅលើផែនដីទេ ។ បន្ទាប់ពីព្រះអាទិទេព (ព្រះយេហូវ៉ា) បានបង្កើតអ្វីៗគ្រប់យ៉ាងរួចហើយ ព្រះក៏បានបង្កើតអាដាំ និង នាងអេវ៉ាដែលជាមនុស្សប្រុសស្រីពីរនាក់ដំបូង ឲ្យរស់នៅដោយរីករាយជាអមតៈនៅក្នុងសួនអេដែន ។ ព្រះបានហាមពួកគេកុំឲ្យបរិភោគផ្លែឈើពី "ដើមដឹងខុសត្រូវ" ព្រោះថា "ដ្បិតនៅថ្ងៃណាដែលឯងស៊ី នោះនឹងត្រូវស្លាប់ជាមិនខាន" ។[110] ក្រោយមកសាតាំង (Satan) ដែលជាទេវតាមានអំណាចខ្លាំងលើសគេ នៅលើស្ថានសួគ៌មានចិត្តច្រណែននឹងព្រះយេហូវ៉ា ក៏បានចុះមកផែនដីរួចក្លែងខ្លួនជាសត្វពស់ដើម្បីអន្ទង

---

109 Christianity

110 គម្ពីរបរិសុទ្ធ សៀវភៅលោកុប្បត្តិ ជំពូក ២ ខ ១៧ (Genesis 2:17)

នាងអេវ៉ា ឲ្យបរិភោគផ្លែពីដើមដឹងខុសត្រូវ ។ បន្ទាប់មកនាងអេវ៉ាក៏ប្រគល់ផ្លែឈើនោះឲ្យអាដាំបរិភោគដែរ ។ នេះជាអំពើបាបដែលមនុស្សទាំងពីរនាក់ បានធ្វើចំពោះព្រះយេហូវ៉ា (Jehovah) ព្រោះពួកគេមិនធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះអង្គ ។ គ្រិស្តបរិស័ទបន្តជឿថា មនុស្សទាំងអស់ទទួលរងបាបនោះ ជាប់រហូតមកដល់បច្ចុប្បន្ន ។ ដើម្បីលាងជម្រះបាបនោះ ព្រះយេហូវ៉ាបានបញ្ជូនព្រះយេស៊ូ ដែលជាបុត្រាតែមួយអង្គគត់របស់ទ្រង់ ឲ្យចុះមកផែនដីដើម្បីកើតជាកូនមនុស្ស និង ឲ្យពួកគេឆ្កាងទ្រង់ជាថ្លៃលោះបាបរបស់មនុស្ស ។ ដូច្នេះទើបគ្រិស្តបរិស័ទមានជំនឿថា មរណភាពរបស់ព្រះយេស៊ូ គឺជាថ្លៃលោះបាប (Redemption) ។ ដើម្បីរួចបាបមនុស្សត្រូវទទួលយកព្រះយេស៊ូ ធ្វើជាព្រះអង្គសង្គ្រោះ[111] ទើបនៅពេលពួកគេស្លាប់ ព្រលឹងរបស់ពួកគេនឹងទៅកាន់ស្ថានសួគ៌ ។ ដោយសារគ្រិស្តបរិស័ទប្រើពាក្យថា "លាងបាប" ដើម្បីជម្រះអំពើបាបទាំងឡាយ ដែលពួកគេបានប្រព្រឹត្ត ទើបពួកគេត្រូវមុជទឹកលាងបាប (Baptism) ។ បន្ទាប់ពីពិធីបុណ្យជ្រមុជទឹក បាបជនទាំងនោះនឹងក្លាយជាបរិសុទ្ធជន ព្រោះពួកគេជឿថា ព្រះយេស៊ូបានទទួលយកអំពើបាបជំនួសពួកគេ ។ គំនិតនេះផ្ទុយនឹងទស្សនៈពុទ្ធនិយម ដែលអះអាងថា បុគ្គលធ្វើកម្មណានឹងទទួលផលខ្លួនឯង ដូចពាក្យថា "សក់អ្នកណា ក្បាលអ្នកនោះ" ។

ជាសត្យានុម័ត នរណាលូកភ្លើង អ្នកហ្នឹងរលាកភ្លើង មិនមែនយើងយកដៃលូកភ្លើង ស្រាប់តែអ្នកដទៃរលាកដៃនោះទេ ។ តាមច្បាប់ធម្មជាតិរឿងនេះមិនអាចកើតឡើងទាល់តែសោះ (Impossible) ។ ដូច្នេះពុទ្ធបរិស័ទមិនត្រូវច្រឡំពាក្យថា ការធ្វើបុណ្យ ជាមួយនឹងពាក្យថា ការលាងបាបទេ ។ ទ្រឹស្តីពុទ្ធសាសនាអះអាងថា បុគ្គលណាធ្វើបុណ្យ បុគ្គលនោះនឹងទទួលផលនៃបុណ្យ ឬ អានិសង្សនៃបុណ្យ ឬ ផលានិសង្ស ។ អានិសង្ស (*Anisamsa*, Benefits) គឺជាគុណប្រយោជន៍ ឬ សេចក្តី

[111] Christ, Messiah, Savior

សុខ-ចម្រើន ដែលបានមកពីការប្រព្រឹត្តល្អ ។ ផ្លែផ្កានៃបុញ្ញកម្ម (ការធ្វើបុណ្យ) គឺជាចិត្តត្រេកអរទាំងមុនពេលធ្វើ, កំពុងធ្វើ និង ពេលបានធ្វើបុណ្យរួច ។ ដូច្នេះ យើងឃើញច្បាស់ថា គោលបំណងរបស់អ្នកធ្វើបុណ្យ គឺការមានចិត្តអំណរ ឬអារម្មណ៍សប្បាយរីករាយ ។

# ៩.៨ អានិសង្សបុណ្យ

ទ្រឹស្តីពុទ្ធសាសនាអះអាងបញ្ជាក់ថា អានិសង្ស ឬផលនៃបុណ្យមាន ៥ យ៉ាង គឺ ៖

១. មានប្រាជ្ញាភ្លឺថ្លា (តិក្ខបញ្ញាវិសាទោ),

២. មានពណ៌សម្បុរល្អ (សុវណ្ណតា),

៣. មានរូបល្អ (សុរូបតា),

៤. មានសណ្ឋានទ្រង់ទ្រាយល្អ (សុសណ្ឋានា),

៥. ទៅកើតជាស្តេចចក្រពត្តិ (ចក្កវត្តិរាជាហោតិ) ។

ជាទូទៅ យើងធ្លាប់ឮពុទ្ធបរិស័ទនិយាយតៗគ្នាថា "ធ្វើបុណ្យបានបុណ្យ" ។ មតិនេះអាចមានន័យម្យ៉ាងទៀតថា ការធ្វើបុណ្យពិតជានាំមកនូវផលានិសង្ស ។ ដូច្នេះហើយ ទើបយើងឃើញពុទ្ធបរិស័ទនាំគ្នាធ្វើបុណ្យផ្សេងៗ ដូចជា កឋិនទាន បុណ្យផ្កាប្រាក់ ការសាងសង់ព្រះវិហារ កុដិ សាលាឆាន់ ឬបង្កន់អនាម័យ ។ អ្នកខ្លះបានជួយកសាងផ្លូវថ្នល់ ស្ពាន សាលារៀន មន្ទីរពេទ្យ ជីកអណ្តូង ឬ ស្រះទឹក ។ រីឯអ្នកខ្លះទៀតក៏ចំណាយពេលវេលា ឬប្រាក់កាសជួយឧបត្ថម្ភ ដល់ការផ្សព្វផ្សាយពុទ្ធសាសនា តាមរយៈការសម្តែងធម្មទេសនា ឬការចងក្រងក្បួនច្បាប់ព្រះពុទ្ធសាសនា ឬការបោះពុម្ពផ្សាយសម្រាប់ចែកចាយជាធម្មទាន ។ល។ កុសលកម្មទាំងនេះសុទ្ធតែទទួលអានិសង្សតាមកម្លាំងនៃការកសាង ឬកម្លាំងបុណ្យ ។

យើងបានឃើញហើយថា អានិសង្សមានច្រើនសណ្ឋានណាស់ ។ នៅទី

នេះ ខ្ញុំបាទសូមលើកយកតែអានិសង្ស ២ យ៉ាង មកអធិប្បាយ ពោលគឺ អានិសង្ស សាធារណៈ និង អានិសង្សសីល ។

## ៩.៨.១ អានិសង្សសាធារណៈ

ជាទូទៅ មនុស្សគ្រប់រូបរមែងប្រាថ្នាចង់បានសេចក្តីសុខ ទាំងខាងផ្លូវកាយ និង ផ្លូវចិត្ត ។ ចំណុចនេះហើយទើបយើងតែងឮភិក្ខុ ឬអាចារ្យឲ្យពរអ្នកធ្វើបុណ្យទាំងឡាយ ឲ្យបានប្រកបដោយពុទ្ធពរ ៤ ប្រការ គឺ ៖

១. អាយុ គឺរស់នៅមានអាយុយឺនយូរ,

២. វណ្ណៈ គឺឆវីវណ្ណ ពណ៌ស្បែកស្រស់ល្អ,

៣. សុខៈ គឺសេចក្តីសុខកាយសប្បាយចិត្ត,

៤. ពលៈ គឺមានកម្លាំងកាយ ។

ពុទ្ធពរទាំង ៤ ប្រការអាចកើតឡើងបានលុះត្រាតែមានបច្ច័យ ៤ ឬ ចតុប្បច្ច័យ ជាគ្រឿងប្រកប ។ បច្ច័យ ៤ នោះគឺ ៖

១. ចីវរ គឺត្រូវមានគ្រឿងស្លៀកដណ្តប់,

២. បិណ្ឌបាត គឺត្រូវមានចំណីអាហារបរិភោគ,

៣. សេនាសន គឺត្រូវមានលំនៅស្នាក់អាស្រ័យ,

៤. គិលានភេសជ្ជៈ គឺត្រូវមានថ្នាំរំងាប់ជំងឺ ឬរម្ងាប់រោគ ។

ទ្រឹស្តីពុទ្ធសាសនាអះអាងបញ្ជាក់ថា អ្នកធ្វើទាន (ទាយក) និង អ្នកទទួលទាន (បដិគ្គាហកៈ) នឹងទទួលបានអានិសង្សនៅបច្ចុប្បន្នជាតិ និង អនាគតជាតិ ។ ទាយកដែលឲ្យបច្ច័យណាមួយ ដោយចិត្តត្រេកអរ ដើម្បីបំពេញសេចក្តីត្រូវការរបស់បដិគ្គាហកៈ ទាយកនោះនឹងទទួលបានអានិសង្សច្រើន ។រីឯអ្នកទទួលទានក៏ទទួលបានពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ និង ពលៈ ដូចគ្នាដែរ ។

## ៩.៨.២ អានិសង្សសីល

ទ្រឹស្តីពុទ្ធនិយមអះអាងថា សីល ជាធម្មចរិយា ឬជាគុណជាតិដ៏ប្រពៃមួយ សម្រាប់ឲ្យអ្នករក្សាសីលមានចិត្តស្ងប់ សម្រាប់ត្រៀមខ្លួនចម្រើនសមាធិកម្មដ្ឋាន[112] ឬ វិបស្សនាកម្មដ្ឋាន[113] ដែលនឹងអាចនាំឲ្យសម្រេចលោកុត្តរបញ្ញា[114] ។

## ៩.៨.៣ សីល ៤ យ៉ាង

សីល ដែលមានន័យថា ការកាន់ចរិយាល្អ ឬការសង្រួម មាន ៤ យ៉ាងគឺ ៖

១. និច្ចសីល (សីល ៥ ឬបញ្ចសីល)

២. ឧបោសថសីល (សីល ៨)

៣. ទសសីល (សីល ១០)

៤. ចតុប្បារិសុទ្ធិសីល ឬសីល ៤ សម្រាប់ភិក្ខុសង្ឃ ។

## ៩.៨.៤ និច្ចសីល

និច្ចសីល គឺជាសីលដែលមនុស្សគ្រប់រូប អាចរក្សាបានរៀងរាល់ថ្ងៃ ដោយឥតមានកំណត់ថ្ងៃនេះ ឬថ្ងៃនោះ ។ និច្ចសីល គឺជាសីលដែលមនុស្សគ្រប់រូបអាចទទួលសមាទានតែម្តងក្នុងថ្ងៃណាមួយ ហើយអាចតាំងនៅជានិច្ច វៀរលែងតែអ្នកសមាទាននោះប្រព្រឹត្តកន្លងអង្គរបស់សីល ។ អង្គនៃនិច្ចសីលមានសិក្ខាបទ ៥ គឺ ៖

១. វៀរចាកការសម្លាប់ជីវិតមនុស្ស ឬសត្វ (បាណាតិបាតា វេរមណី),

២. វៀរចាកការលួចទ្រព្យសម្បត្តិអ្នកដទៃ (អទិន្នាទានា វេរមណី),

៣. វៀរចាកការប្រព្រឹត្តខុសឆ្គងក្នុងផ្លូវកាម (កាមេសុមិច្ឆាចារា វេរមណី),

---

[112] Concentration; a state of meditative consciousness; meditative absorption or trance; one-pointedness of mind; unification of mind.

[113] Insight into the true nature of reality: impermanence, suffering or unsatisfactoriness, and the realization of non-self.

[114] *Lokuttara paññā*: supra-mundane wisdom. *Lokiya paññā*: mundane wisdom

៤. វៀរចាកការភូតកុហក (មុសាវាទា វេរមណី),

៥. វៀរចាកការសេពសុរា និងទឹកមេរ័យដែលជាមូលហេតុនៃសេចក្តីប្រមាទ (សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី) ។

## ៩.៨.៥ ឧបោសថសីល

ឧបោសថសីល ឬសីលឧបោសថ ជាសីលសម្រាប់រក្សាដើម្បីជម្រះចិត្ត ។ ក្នុងលទ្ធិពុទ្ធសាសនា ឧបោសថសីល សំដៅ អដ្ឋង្គិកសីល ដែលមានអង្គ ៨ គឺ ៖

១. វៀរចាកការសម្លាប់ជីវិតមនុស្ស និង សត្វ (បាណាតិបាតា វេរមណី) ។

២. វៀរចាកការលួចទ្រព្យសម្បត្តិអ្នកដទៃ (អទិន្នាទានា វេរមណី) ។

៣. វៀរចាកការសេពមេថុនធម្ម[115] (អព្រហ្មចរិយា វេរមណី) ។

៤. វៀរចាកការនិយាយពាក្យមិនពិត (មុសាវាទា វេរមណី) ។

៥. វៀរចាកការសេពសុរា និង ទឹកមេរ័យ ដែលជាមូលហេតុនៃសេចក្តីប្រមាទ (សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី) ។

៦. វៀរចាកការបរិភោគអាហារ ចាប់ពីថ្ងៃត្រង់ទៅដល់ថ្ងៃរះ (វិកាលភោជនា វេរមណី) ។

៧. វៀរចាកការច្រៀងរាំ, ដេញដំប្រគំកូត តូរ្យតន្ត្រីដោយខ្លួនឯង, ការមើលការស្តាប់អ្នកដទៃ និង ការទ្រទ្រង់ប្រដាប់តាក់តែង ស្អិតស្អាងរាងកាយដោយផ្កាកំរងគ្រឿងក្រអូប ឬគ្រឿងលាបផ្សេងៗ (នច្ចគីតវាទិតវិសូកទស្សន មាលាគន្ធវិលេបន ធារណមណ្ឌនវិភូសនដ្ឋានា វេរមណី) ។

---

115 មេថុន (Mithuna) (បា.) (សំ. មៃថុន Maithuna) : គូ, គូនៃបុរស និង ស្ត្រី, ឬការរួមសំវាស ។ មេថុនកម្ម, មេថុនធម្ម, មេថុនសេវនៈ មេថុនសេវនកិច្ច, មេថុនសំវាស : ការរួមសំវាស, ការរួមបវេណី ។ មិថុនរាសី (Mithuna) : គូបុរសនិងស្ត្រី, មនុស្សប្រុស និង មនុស្សស្រីជាប្តីប្រពន្ធ ។

៨. វៀរចាកការដេក, អង្គុយលើសេនាសនៈខ្ពស់ និង សេនាសនៈដ៏ប្រសើរ (ឧច្ចាសយនមហាសយនា វេរមណី) ។

## ៩.៨.៦ ទសសីល

ទសសីល មានសិក្ខាបទ ១០ សម្រាប់សាមណេរ,សាមណេរី, សីលវន្ត និង សីលវន្តី រក្សាឲ្យបានត្រឹមត្រូវ ។ ទសសីលទាំង ១០ គឺ ៖

១. វៀរចាកការសម្លាប់សត្វមានជីវិត (បាណាតិបាតា វេរមណី) ។

២. វៀរចាកការលួចទ្រព្យសម្បត្តិអ្នកដទៃ (អទិន្នាទានា វេរមណី) ។

៣. វៀរចាកការសេពមេថុនធម្ម (អព្រហ្មចរិយា វេរមណី) ។

៤. វៀរចាកការនិយាយភូតកុហក (មុសាវាទា វេរមណី) ។

៥. វៀរចាកការសេពសុរា និង ទឹកមេរ័យ ដែលជាមូលហេតុនៃសេចក្តីប្រមាទ (សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី) ។

៦. វៀរចាកការបរិភោគអាហារ ចាប់ពីថ្ងៃជ្រេទៅដល់ថ្ងៃរះ (វិកាលភោជនា វេរមណី) ។

៧. វៀរចាកការច្រៀងរាំ ការដេញដំប្រគំកូត និង ការទស្សនាល្បែងរបាំផ្សេងៗ (នច្ចគីតវាទិតវិសូកទស្សនា វេរមណី) ។

៨. វៀរចាកការទ្រង់ប្រដាប់ និង ការតាក់តែងរាងកាយដោយផ្កា គ្រឿងក្រអូប ឬគ្រឿងលាបផ្សេងៗ (មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណី) ។

៩. វៀរចាកការដេក ឬអង្គុយលើសេនាសនៈខ្ពស់ និង ទីសេនាសនៈដ៏ប្រសើរ (ឧច្ចាសយនមហាសយនា វេរមណី) ។

១០. វៀរចាកការទទួលកាន់យកមាសប្រាក់ដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យទទួលកាន់យកឬត្រេកអរចំពោះមាសប្រាក់ (ជាតរូបរជតប្បដិគ្គហណា វេរមណី) ។

## ៩.៨.៧ ចតុប្បារិសុទ្ធិសីល

ចតុប្បារិសុទ្ធិសីល គឺសេចក្តីបរិសុទ្ធិ ៤ យ៉ាងសម្រាប់ភិក្ខុក្នុងព្រះពុទ្ធសាសនារក្សាយ៉ាងខ្ជាប់ខ្ជួន ។

១. បាតិមោក្ខសំវរៈ គឺការសង្រួមតាមសិក្ខាបទក្នុងបាតិមោក្ខ[116] ដោយមិនមានប្រព្រឹត្តល្មើសកន្លងពុទ្ធប្បញ្ញត្តិ ឬដោយប្រព្រឹត្តត្រឹមត្រូវតាមពុទ្ធានុញ្ញាត ។

២. ឥន្ទ្រិយសំវរៈ គឺការសង្រួមឥន្ទ្រិយទាំង ៦ គឺភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និង ចិត្ត ។

៣. អាជីវបារិសុទ្ធិ គឺការចិញ្ចឹមជីវិតតាមគន្លងនៃសេចក្តីបរិសុទ្ធ មានការវៀរចាកការប្រចុបប្រចែងគ្រហស្ថជាដើម ។

៤. បច្ចយសន្និស្សិត គឺការពិចារណាសិនហើយទើបបរិភោគបច្ច័យ ៤ គឺចីវរ, បិណ្ឌបាត, សេនាសនៈ និង គិលានភេសជ្ជៈ ។

## ៩.៨.៨ ប្រភេទរបស់សីល

ប្រសិនបើគិតតាមប្រភេទនៃអ្នកប្រតិបត្តិ សីលត្រូវបានគេបែងចែកជា ២ ប្រភេទ គឺ អាគារិកសីល និង អនាគារិកសីល ។

១. អាគារិកសីល គឺជាសីលសម្រាប់មនុស្សនៅតាមគេហដ្ឋានរក្សា ។ ពាក្យថា អាគារិកសីល រាប់បញ្ចូលទាំងនិច្ចសីល និង ឧបោសថសីល សម្រាប់ឧបាសក និង ឧបាសិកា សមាទាន និង រក្សា ។

២. អនាគារិកសីល គឺជាសីលសម្រាប់សាមណេរ, សាមណេរី, ភិក្ខុ និង ភិក្ខុនីរក្សាឲ្យបានខ្ជាប់ខ្ជួន ។ អនាគារិកសីល រាប់បញ្ចូលទាំងទសសីល (សីល ១០) និង

---

116 បាដិមោក្ខ ឬ បាតិមោក្ខ (*pāṭimokkha*) : (សំ. ប្រាតិមោក្ស *Prātimokṣa*) ឈ្មោះបាលីពុទ្ធប្បញ្ញត្តិដែលជាសិក្ខាបទមួយៗសម្រាប់ឲ្យភិក្ខុសូត្រក្នុងទីប្រជុំសង្ឃរាល់កន្លះខែ ។

ចតុប្បារិសុទ្ធិសីល ។

សីលទាំង ២ ប្រភេទនេះ មានសិក្ខាបទដែលត្រូវសិក្សា ត្រូវកាន់ តិចច្រើន តឹងធូរ ទាបខ្ពស់ខុសៗគ្នាជាលំដាប់ តាមថ្នាក់ទាបខ្ពស់ ហើយផលានិសង្ស ក៏បាន តិចច្រើន ទៅតាម ថ្នាក់ទាបខ្ពស់នោះៗ ។ និច្ចសីល ជាថ្នាក់ទី ១ ទាប, ឧបោសថសីល ជាថ្នាក់ទី ២ កណ្តាល, ទសសីល ជាថ្នាក់ទី ៣ កណ្តាល, ចតុប្បារិសុទ្ធិសីល ជាថ្នាក់ទី ៤ ខ្ពស់បំផុត ។ សីល ៤ ថ្នាក់នេះ ត្រូវមានសទ្ធា[117]ជាមូលដ្ឋាន ហើយសម្រេចដោយសទ្ធា ។ ហេតុនេះអ្នកកាន់សីល លុះត្រាតែជឿលើពុទ្ធប្បញ្ញត្តិ ដែលព្រះពុទ្ធទ្រង់បញ្ញត្តចំពោះសិក្ខាបទនោះ ទើបអាចញ៉ាំងសីលឲ្យបរិសុទ្ធបាន ។

## ៩.៨.៩ អានិសង្សសីល

បុគ្គលដែលបានរក្សាសីលបរិសុទ្ធ នឹងមានគុណធម៌ប្រពៃ ហើយនឹងទទួលបានផលប្រយោជន៍ ៥ យ៉ាង គឺ ៖

១-បាននូវគំនរទ្រព្យច្រើន មានសេចក្តីមិនប្រមាទជាហេតុ ។[118]

២-កិត្តិសព្ទដ៏ពីរោះ តែងផ្សាយទៅសព្វទិស ។

៣-ពេលចូលទៅក្នុងសង្គមមនុស្ស ពួកគេនឹងគ្មានការអៀនអន់ ។

៤-រមែងមិនវង្វេងមុនពេលធ្វើមរណកាល ។

---

[117] សទ្ធា (*saddhā*) (បា.) (សំ. ស្រទ្ធា, śraddhā) : (faith, confidence, trust) ជំនឿ ការជឿបុណ្យ ការជឿបាប ការជឿកម្ម ការជឿផល ការដាក់ចិត្តជឿលើសេចក្តីបង្រៀនណាមួយ បន្ទាប់ពីបានពិចារណាហេតុផលប្រកបដោយបញ្ញា ។ ["Wide opened is the door of the Deathless to all who have ears to hear let them send forth faith [saddhā] to meet it." Mahavagga, I, 5,11 Vinaya Texts, T.W. Rhys Davids, Motilal Banarsidass, Delhi 1996, p.88] ។

[118] គម្ពីរព្រះត្រៃបិដក សៀវភៅលេខ ១៩ ទំព័រទី ១៧៨ (បាជិកវគ្គ)

៥-លុះបែកធ្លាយរាងកាយទៅ នឹងបានទៅកើតក្នុងសុគតិភព ។

ក្នុងគម្ពីរវិសុទ្ធិមគ្គ(119) មានសេចក្ដីថ្លែងថា **សីល**(120)បរិសុទ្ធ ជាបច្ច័យឲ្យកើត **អវិប្បដិសារៈ**(121) ឬការគ្មានចិត្តក្ដៅក្រហាយស្ដាយក្រោយ ។ **អវិប្បដិសារៈ** កើតឡើង គឺជាបច្ច័យឲ្យកើត **បាមោជ្ជ**(122) ឬសេចក្ដីរីករាយ ។ **បាមោជ្ជ** កើតឡើង គឺជាបច្ច័យឲ្យកើត **បីតិ** ឬសេចក្ដីឆ្អែតចិត្ត ។ **បីតិ** កើតឡើង ជាបច្ច័យឲ្យកើត **បស្សទ្ធិ** ឬសេចក្ដីស្ងប់កាយស្ងប់ចិត្ត ។ **បស្សទ្ធិ** កើតឡើង ជាបច្ច័យឲ្យកើត **សុខៈ** ឬសេចក្ដីស្រួលកាយ និង ចិត្ត ។ **សុខៈ**កើតឡើង ជាបច្ច័យឲ្យកើត **សមាធិ** ឬការតម្កល់ចិត្តឲ្យនឹងធឹង ។ **សមាធិ** កើតឡើង ជាបច្ច័យឲ្យកើត **យថាភូតញ្ញាណទស្សនៈ** ឬបញ្ញាដឹងច្បាស់នូវធម៌តាមពិត ។ **យថាភូតញ្ញាណទស្សនៈ** កើតឡើង ជាបច្ច័យឲ្យកើត **និព្វិទា** ឬ សេចក្ដីនឿយណាយ ។ **និព្វិទា**កើតឡើង គឺជាបច្ច័យឲ្យកើត**វិរាគៈ** ឬ ការប្រាសចាកតម្រេក ។ **វិរាគៈ** កើតឡើងជាបច្ច័យឲ្យកើត **វិមុត្តិ** ឬការរួចចាកកិលេស ។ **វិមុត្តិ** កើតឡើង ជាបច្ច័យឲ្យកើត **វិមុត្តិញ្ញាណទស្សនៈ** ឬបញ្ញាដឹងច្បាស់ថា រួចផុតស្រឡះចាក **កិលេស**។(123)

---

119 *Visuddhimagga* : "The Path of Purification" by Buddhaghosa

120 សីល (*sila*, virtue) : វិរតិចេតនាដែលវៀរចាកអំពើអាក្រក់, ការកាន់ឬប្រព្រឹត្តល្អដោយកាយវាចា [behavioral discipline, morality, virtue, ethics]។

121 *Avippatisāra* : non-remorse. [វិប្បដិសារៈ គឺសេចក្ដីក្ដៅក្រហាយចិត្ត, សេចក្ដីនឹកស្ដាយក្រោយ, សេចក្ដីនឹកតូចចិត្តព្រោះដឹងខ្លួនថាខុស] ។

122 បាមោជ្ជ (បាលី), ប្រាមោទ្យ (សំស្ក្រឹត) : សេចក្ដីរីករាយ, សេចក្ដីពេញចិត្តខ្លាំង [*Pāmojja, prāmodya,* delight, gladness] ។

123 "Such *virtues* lead to *non-remorse* in the mind, to *gladdening,* to *happiness,* to *tranquillity,* to *joy,* to *repetition,* to *development,* to *cultivation,* to *embellishment,* to the *requisite* [for concentration], to the *equipment* [of concentration], to *fulfilment,* to complete *dispassion,* to

ព្រះពុទ្ធទ្រង់បានសម្តែងថា "ចេតនាជាតួសីល ឬជាប្រភពដើមនៃសីល" ។ ធម៌ទាំងឡាយមានចិត្តជាប្រធាន ។ អ្នករក្សានិច្ចសីល មិនចាំបាច់សមាទាន(124)ពីបុគ្គលដទៃទេ គ្រាន់តែតាំងចិត្តជាអ្នករក្សាគ្រប់សិក្ខាបទទាំង ៥ ដោយខ្លួនឯង ក៏បានជាសីលពិតប្រាកដ ។ ការសមាទានសីលពីបុគ្គលដទៃ គ្រាន់តែជាការពោលប្រាប់មហាជនថា គាត់បានរក្សាសិក្ខាបទណាមួយ ដើម្បីឲ្យមនុស្សទាំងឡាយជួយជាសាក្សីប៉ុណ្ណោះ ។ ការសំខាន់គឺការប្រតិបត្តិសិក្ខាបទទាំងនោះដោយខ្លួនឯង ។ ដូចពុទ្ធោវាទថា "ខ្លួនទីពឹងខ្លួន ចិត្តគឺជាម្ចាស់លើខ្លួន ដូច្នេះត្រូវជម្រះចិត្តឲ្យបរិសុទ្ធដោយខ្លួនឯង" ។ ព្រះពុទ្ធ ឬ ភិក្ខុសង្ឃមិនអាចជួយជម្រះចិត្តរបស់បុគ្គលណាមួយឲ្យបរិសុទ្ធបានទេ ។ បុគ្គលម្នាក់ៗត្រូវធ្វើសមាធិ តម្កល់ចិត្តឲ្យស្អាតផូរផង់ ព្រោះចិត្តជាតួសីល ជាតួបុណ្យ ជាតួបាប ។ អ្នកបរិបូណ៌ដោយសីល រមែងមានការត្រជាក់ចិត្តជាថ្នាក់ៗឡើងទៅ ។ អានិសង្សនៃសីលគឺ "សីលមានប្រយោជន៍ឲ្យកើតសំវរៈ ។ ការសង្រួម មិននាំឲ្យមាន វិប្បដិសារៈ (ក្តៅក្រហាយចិត្ត) ។ ការមិនមានវិប្បដិសារៈ នាំឲ្យកើត បាមោជ្ជ (ចិត្តរីករាយ) ។ បាមោជ្ជ នាំឲ្យកើត បីតិ (ចិត្តដែលឆ្អែត មិនខ្វល់ចង់បានទៀត) ។ បីតិ នាំឲ្យកើត បស្សទ្ធិ (ចិត្តដែលស្ងប់) ។ បស្សទ្ធិ នាំឲ្យកើតសុខៈ (ចិត្តដែលស្រួល) ។ សុខៈ នាំឲ្យកើត សមាធិ (ការតម្កល់ចិត្តមាំក្នុងកុសលធម៌) ។ សមាធិ នាំឲ្យកើត យថាភូតញ្ញាណទស្សនៈ (ការដឹងសភាវធម៌តាមសេចក្តីពិត) ។ យថាភូតញ្ញាណទស្សនៈ នាំឲ្យកើត និព្វិទា (ការនឿយណាយក្នុងសង្ខារ) ។ និព្វិទា នាំឲ្យកើត វិរាគៈ (ការប្រាសចាកតម្រេក) ។ វិរាគៈ នាំឲ្យកើតវិមុត្តិ (ការរួចចាក

---

*fading away,* to *cessation,* to *peace,* to *direct-knowledge,* to *enlightenment,* to *Nibbana*." (Path of Purification, page 48)

124 សមាទាន : ការកាន់ដោយប្រពៃ, ការទទួលកាន់តាម, ការបញ្ចេញវាចាប្តេជ្ញាទទួលកាន់តាម ។

កិលេស) ។ វិមុត្តិ នាំឲ្យកើត វិមុត្តិញ្ញាណទស្សនៈ (ការដឹងច្បាស់ថាមានវិមុត្តិ) ។ វិមុត្តិញ្ញាណទស្សនៈ នាំឲ្យកើត អនុបាទាបរិនិព្វាន (ការឈប់ប្រកាន់មាំ) ៉ ។

ទ្រឹស្តីពុទ្ធនិយមអះអាងថា សត្វទាំងឡាយបានសុគតិព្រោះសីល, បានភោគព្រោះសីល, បានរំលត់ទុក្ខព្រោះសីល ។ ហេតុនេះពុទ្ធបរិស័ទគប្បីរក្សាសីលជម្រះចិត្តឲ្យបរិសុទ្ធផូរផង់ជាអចិន្ត្រៃយ៍ ព្រោះការរក្សាសីល គឺជាសីលសិក្ខានៅក្នុងត្រៃសិក្ខា[125] ដែលជាមជ្ឈិមាបដិបទា[126] អាចជួយឲ្យសម្រេចព្រះនិព្វាន ។

*

៉ការមានវិន័យតឹងតែងចំពោះខ្លួនឯង
នាំឲ្យមនុស្សអាចសម្រេចស្ទើរគ្រប់កិច្ចការ៉ ។

**“With self-discipline most anything is possible.”**

-- Theodore Roosevelt,

26th U.S. President (1858-1919)

៉កុំរស់នៅក្នុងអតីតកាល, កុំស្រមើស្រមៃទៅអនាគត
ត្រូវផ្ចង់ចិត្តនៅក្នុងពេលបច្ចុប្បន្ន៉ ។[127]

**“Do not dwell in the past, do not dream of the future, concentrate the mind on the present moment.”**

--Buddha (Dhammapada 348)

***

---

[125] The threefold Training
[126] Middle Way
[127] ព្រះត្រៃបិដក សៀវភៅលេខ ៥២ ទំព័រទី ៩៥ (គាថាធម្មបទ តណ្ហាវគ្គ ៣៤៨)

# ១០. ខ្លួនទីពឹងខ្លួន

ទ្រឹស្ដីពុទ្ធសាសនាអះអាងថា វាសនាមនុស្សស្ថិតនៅក្នុងកណ្ដាប់ដៃរបស់មនុស្ស ។ មនុស្សជាអ្នកច្នៃវាសនារបស់ខ្លួន មិនមែនព្រះព្រហ្ម ឬ ទេវតាជាអ្នកច្នៃវាសនាមនុស្សទេ ។ ទ្រឹស្ដីនេះក៏អះអាងថា គ្មានបុគ្គលណាចាំប្រទានរង្វាន់ល្អ ឬដាក់បណ្ដាសាមនុស្សទេ ។ សេចក្ដីសុខ ឬទុក្ខ សុទ្ធតែជាផលដែលកើតចេញមកពីកម្ម (អំពើ) របស់មនុស្ស ។ បុគ្គលដែលគិតថាមានទេវតាចាំប្រទានរង្វាន់, ចាំដាក់បណ្ដាសា ឬគូសក្រយៅដៅវាសនា មិនមែនជាបុគ្គលមានសម្មាទិដ្ឋិ[128]ឡើយ ។ តាមរយៈពុទ្ធប្បវត្តិ យើងដឹងថាព្រះពុទ្ធគឺជាមនុស្សសុទ្ធសាធ ហើយទ្រង់បានបញ្ជាក់ថា មនុស្សគ្រប់រូបអាចសម្រេចពុទ្ធភាពបាន ។ ប៉ុន្តែ បុគ្គលខ្លះពោលយ៉ាងអស់សង្ឃឹមថា "វាសនាមនុស្សស្រេចលើព្រហ្មលិខិត ស្រេចលើទេវតាចារគូថ" ។ បុគ្គលដែលពោលវាចាបែបនេះ គឺជាមនុស្សខ្វះសេចក្ដីក្លាហាន និង បន្ថោកអត្តភាពរបស់ខ្លួន ហើយរមែងជួបប្រទះទុក្ខសោកច្រើនក្នុងជីវិត ។ នៅពេលជួបប្រទះបញ្ហាស្មុគ្រស្មាញ ពួកគេទាល់គំនិត, គិតមិនចេញ, មិនចេះដោះស្រាយបញ្ហាទាំងនោះ ក៏សម្លឹងមើលមេឃ មើលផ្កាយ ហើយឧទានយ៉ាងអស់សង្ឃឹមថា "ជាតិនេះអភ័ព្វណាស់! ស្ដាល់តែទុក្ខ! ព្រហ្មលិខិតឥតមេត្តា ទេវតាឥតប្រណី!" ។ ទោះបីពួកគេខំប្រឹងស្រែកឲ្យបែកផែនដីក៏ឥតអំពើដែរ ព្រោះគ្មានព្រះព្រហ្ម ឬទេវតាណាចុះពីស្ថានលើមកជួយដោះស្រាយបញ្ហារបស់មនុស្សទេ ។ ប្រសិនបើមានទេវតាមែន ក៏មានតែក្នុងរឿងព្រេងនិទានប៉ុណ្ណោះ ។

ទ្រឹស្ដីពុទ្ធនិយមអះអាងថា មនុស្សសាងកម្មអ្វីនឹងទទួលផលនៃកម្មនោះ ។ ទ្រឹស្ដីនោះក៏អះអាងផងដែរថា អ្វីៗដែលមនុស្សមានក្នុងជាតិនេះគឺជាផលនៃកម្ម

---

[128] Right Understanding

ដែលមនុស្សបានសាងពីអតីតជាតិផង និង សាងនៅក្នុងបច្ចុប្បន្នជាតិនេះផង ។ ដូច្នេះព្រះពុទ្ធទ្រង់សំដែងថា "អត្តាហិ អត្តនោ នាថោ" "ខ្លួនទីពឹងខ្លួន" ។ គ្មានទេវតា, ឥន្ទ, ព្រហ្ម ឬអាទិទេពណាដែលមនុស្សគួរនឹងយកមកធ្វើជាទីពឹងទេ ។ ព្រះពុទ្ធទ្រង់បានបណ្ដុះកម្លាំងចិត្តសាវករបស់ព្រះអង្គឲ្យពឹងលើខ្លួនឯង ដើម្បីសម្រេចបំណងរបស់ខ្លួន ។ ព្រះពុទ្ធទ្រង់បានត្រាស់ថា "អ្នកទាំងឡាយ ចូរយកខ្លួនជាកោះពឹងខ្លួនឯង, ចូរយកខ្លួនជាទីពឹង ចូរកុំយកអ្នកដទៃមកធ្វើជាទីពឹងខ្លួនឡើយ" ។

វិរិយភាព, ខន្តី, គោលបំណងដ៏ជាក់លាក់ និង ការតស៊ូពុះពារ គឺជាកត្តាសំខាន់ជួយមនុស្សដែលស្វែងរកវិជ្ជា និង ទ្រព្យសម្បត្តិឲ្យសម្រេចគោលបំណងរបស់ខ្លួន ។ ឧទាហរណ៍ សុភាសិតមួយដែលយើងធ្លាប់ឮគ្រប់ពេលគឺ "ចេះមកពីរៀន មានមកពីរក" មានន័យថា ទាំងចំណេះវិជ្ជា និង ទ្រព្យសម្បត្តិកើតមកពីការខំប្រឹងរបស់បុគ្គលគ្រប់រូប មិនមែនបានមកពីការបន់ស្រន់ទេវតា ឥន្ទ ព្រហ្ម ឬអាទិទេពទេ ។ លុះត្រាតែមនុស្សព្យាយាមរៀនសូត្រ ទើបមនុស្សមានចំណេះវិជ្ជា ។ លុះត្រាតែមនុស្សប្រឹងប្រែងរកទ្រព្យសម្បត្តិ ទើបមនុស្សមានភោគទ្រព្យ ។ ដូចពាក្យស្លោកនៅក្នុងគម្ពីរ ស្រីហិតោបទេស(129) ថា "ម្រឹគទាំងឡាយមិនបោលចូលមាត់សីហៈដេកលក់ឡើយ" ។ យ៉ាងណាមិញ ទ្រព្យសម្បត្តិក៏មិនដែលចូលមករកបុគ្គល ដែលបណ្ដោយឲ្យភាពខ្ជិលច្រអូសគ្របសង្កត់ដែរ ។ បណ្ឌិតចាត់ទុកការព្យាយាមជាទ្រព្យដ៏ប្រសើររបស់មនុស្សគ្រប់រូប ។ បញ្ញាកើតពីវិជ្ជា វិជ្ជានាំឲ្យមានវិន័យ វិន័យនាំឲ្យមានសេចក្ដីថ្លៃថ្នូរ សេចក្ដីថ្លៃថ្នូរនាំឲ្យមានទ្រព្យសម្បត្តិ ទ្រព្យសម្បត្តិនាំឲ្យមានធម៌ ធម៌ដឹកនាំឲ្យបានសេចក្ដីសុខ ។ មនុស្សគ្មានវិជ្ជាគឺជាមនុស្សគ្មានប្រាជ្ញា គ្មានទ្រព្យសម្បត្តិ គ្មានកិត្តិយស និង គ្មានសេចក្ដីថ្លៃថ្នូរ ។ បុគ្គលគ្មានបញ្ញា គ្មានវិរយភាព គ្មានខន្តី គ្មានគោលបំណងពិតប្រាកដ និង គ្មានការតស៊ូដើម្បីស្វែងរកវិជ្ជា និង ទ្រព្យ

---

[129] Hitopadesha

សម្បត្តិទេ ។ ដូចជាកាព្យបុរាណថា "មនុស្សល្ងង់មិនផ្ទើលភ្នាក់ ដូចក្អែកខ្វាក់ទាំងសងខាង មានរូបគ្មានអ្វីអាង សាងថោកទាបកើតមកខ្ចៅ" ។ ទន្ទឹមនឹងនោះ យើងក៏គួរពិចារណាពុទ្ធវចនៈថា "ដោយសេចក្តីព្យាយាម មនុស្សអាចឆ្លងផុតពីទុក្ខទោសគ្រប់យ៉ាងបាន" ។[130]

នៅក្នុងបញ្ញានិទ្ទេសរបស់ពុទ្ធសាសនា បញ្ញាមានច្រើនយ៉ាង ប៉ុន្តែដោយសង្ខេប បញ្ញាមានតែ ២ យ៉ាងប៉ុណ្ណោះ គឺ លោកិយបញ្ញា និង លោកុត្តរបញ្ញា ។

# ១០.១ លោកិយបញ្ញា

លោកិយបញ្ញា មានន័យថាការចេះដឹង ការយល់ស្គាល់ដំណើរវិវឌ្ឍន៍នៃស្ថានការណ៍ និង ព្រឹត្តិការណ៍ផ្សេងៗនៅលើពិភពលោក ។ បើមនុស្សមិនអើពើ មិនយល់កិច្ចការ ឬគ្មានវិជ្ជាខាងផ្លូវលោកទេ មនុស្សមិនអាចរស់នៅក្នុងលោកនេះប្រកបដោយសេចក្តីសុខ-ចម្រើនឡើយ ។ លោកិយបញ្ញា ជួយឲ្យមនុស្សឆ្លាតវៃក្នុងការធ្វើការងារ ចេះប្រកបមុខរបរតាមសម្មាអាជីវៈ ស្គាល់កាលៈទេសៈ និង ស្គាល់ចំណូលចិត្តរបស់មនុស្សក្នុងសម័យសម្ភារនិយម (Materialism) ។

# ១០.២ លោកុត្តរបញ្ញា

លោកុត្តរបញ្ញា មានន័យថា បញ្ញាដែលនាំសត្វឲ្យឆ្លងផុតលោកទាំង៣ គឺ កាមលោក រូបលោក និង អរូបលោក ។ បើនិយាយឲ្យងាយយល់ លោកុត្តរបញ្ញា គឺ ការយល់ដឹងអំពីអរិយសច្ច ។ លោកុត្តរធម៌ រាប់បញ្ចូលទាំងសម្មាទិដ្ឋិ (ការយល់ត្រូវ) និង សម្មាសង្កប្បៈ (ការត្រិះរិះត្រូវ) ។ សម្មាទិដ្ឋិ និង សម្មាសង្កប្បៈ ជាបញ្ញាសិក្ខា ដែលជាផ្លូវតែមួយគត់នាំមនុស្សឲ្យឆ្លងពីលោកិយសុខ ឆ្ពោះរកបរមសុខ ។

---

130 "វីរិយេន ទុក្ខមច្ចេតិ"

**បញ្ញា** គឺជាអាវុធដ៏ប្រសើរសម្រាប់កាប់ឆ្ការកិលេសតណ្ហា ។ បុគ្គលដែលមានបញ្ញាអាចពិចារណាឃើញទោសរបស់ខ្លួនឯង និង មិនថ្កោលទោសអ្នកដទៃ ។ បុគ្គលដែលមានបញ្ញា ត្រិះរិះដឹងច្បាស់ថា គាត់គឺជាទាសករនៃកិលេសតណ្ហា ។ លើសពីនោះទៀត បញ្ញា គឺជាបារមីធម៌មួយក្នុងចំណោមបារមីធម៌[131]ទាំង ១០ ឬទសបារមី ដែលព្រះពុទ្ធទ្រង់បានបំពេញច្រើនជាតិ ហើយបានសម្រេចព្រះនិព្វាន ។

ជាសរុប បុគ្គលម្នាក់ៗ ត្រូវប្រើបញ្ញារបស់ខ្លួន ដោយវីរិយភាព និង ខន្តី ដើម្បីកែច្នៃជីវិតខ្លួនឲ្យបានសេចក្តីសុខ-ចម្រើន ។ មនុស្សមិនត្រូវពឹងអ្នកដទៃ, មិនត្រូវធ្វើជាស្រមោល ឬអាយ៉ងរបស់អ្នកដទៃ, មិនត្រូវពឹងលើព្រេងវាសនា, មិនត្រូវមើលងាយខ្លួនឯង និង មិនត្រូវពឹងទេវតា ឥន្ទ ព្រហ្ម ឬអាទិទេពទេ ។ ទោះជាក្នុងការស្វែងរកវិជ្ជា, ការស្វែងរកទ្រព្យសម្បត្តិ ឬការស្វែងរកធម៌ មនុស្សគ្រប់រូបត្រូវរំលឹកគ្រប់ពេលនូវពុទ្ធវចនៈថា "ខ្លួនទីពឹងខ្លួន"[132] ដើម្បីដាស់សតិរបស់ខ្លួន ។

*

"ការបន់ស្រន់ជាទង្វើឥតប្រយោជន៍ និង ជាភាពកម្សោយ" ។

**"Prayer is a confession of one's own unworthiness and weakness."**

--Mahatma Gandhi (1869-1948)

***

---

[131] Perfection

[132] "អត្តាហិ អត្តនោ នាថោ"

# ១១. ទសបារមី

បារមី[133] គឺជាចរិយាដ៏លើសលន់, សុក្រឹត, ឥតខ្ចោះ ឬ គុណជាតិដែលមនុស្សគួរបំពេញ ។ ន័យម្យ៉ាងទៀត បារមីគឺជាការកសាងកម្លាំងចិត្តឲ្យពេញលេញដិតជាប់ក្នុងចិត្តឥតចន្លោះ ឬការកសាងកម្លាំងចិត្តយ៉ាងសុក្រឹតឥតខ្ចោះ[134] ។ នៅក្នុងទ្រឹស្តីពុទ្ធសាសនាមហាយាន បារមីមានចំនួន ៦ ចំណែកទ្រឹស្តីនៃពុទ្ធសាសនាក្នុងនិកាយថេរវាទ បារមីមានចំនួន ១០ ប្រការ ឬហៅថា ទសបារមី ពោលគឺ ៖

១. ទានបារមី[135] គឺការផ្តល់គ្រឿងវត្ថុសម្រាប់ទ្រទ្រង់ជីវិតដល់បុគ្គលដែលគួរទទួលមានជនក្រីក្រ ក្មេងកំព្រាជាដើម ដោយមិនរំពឹងសម្លឹងចង់បានវត្ថុឬគ្រឿងតបស្នង (អានិសង្ស) ។ ការបរិច្ចាគដោយចង់បានមកវិញនូវការតបស្នង គឺជាការធ្វើវិនិយោគ បានន័យថាជាការបោកប្រាស់ចិត្តខ្លួនឯង ។ ការបរិច្ចាគរបៀបនេះនឹងនាំឲ្យអ្នកធ្វើទានមានចិត្តជាប់ជំពាក់ជាមួយអានិសង្ស ។ តាមពិត ការធ្វើទានគឺជាការបង្ហាត់ចិត្តឲ្យលះបង់កំណាញ់[136] ឬការធ្វើចិត្តសប្បុរសឲ្យកើតក្នុងសន្តាន ។

២. សីលបារមី[137] គឺការបំពេញគុណធម៌ ឬការចម្រើនកុសលធម៌ក្នុងការវៀរចាកអកុសលកម្មតាមផ្លូវកាយ វាចា និង ចិត្ត ។

៣. នេក្ខម្មបារមី[138] គឺការចេញបួសព្រោះយល់ឃើញថា កាមសុខមិនមែនជាសុខពិតប្រាកដ ។

---

133 *Pāramī*, *Pāramitā*, perfection, completeness
134 Perfect
135 *Dāna*, generosity, charity, giving alms
136 Let go of impermanent things.
137 *Sīla*, right conduct, morality, moral discipline, virtue, precept
138 *Nekkhamma*, renunciation

៤. បញ្ញាបារមី[139] គឺការបំពេញគុណធម៌ដើម្បីឃើញច្បាស់នូវសច្ចធម៌ ។

៥. វីរិយបារមី[140] គឺការតាំងចិត្តព្យាយាមធ្វើកិច្ចការមួយ ដែលខ្លួនដាក់ចិត្តធ្វើចាប់តាំងពីដើមទីរហូតដល់សម្រេច ។

៦. ខន្តិបារមី[141] គឺការតាំងចិត្តអត់ធន់, ខន្តី, ឲ្យអភ័យដល់សត្វ ឬ មនុស្សដែលធ្វើខុសចំពោះខ្លួន ។

៧. សច្ចបារមី[142] គឺការតាំងចិត្តស្វែងយល់ថាអ្វីជាការពិត, ការកាន់ពាក្យពិតត្រង់, ការនិយាយពាក្យពិត ។

៨. អធិដ្ឋានបារមី[143] គឺឆន្ទៈមោះមុត ប្តេជ្ញាធ្វើអ្វីៗឲ្យបានសម្រេចតាមផែនការ ។

៩. មេត្តាបារមី[144] គឺការបណ្តុះសេចក្តីស្រឡាញ់ចំពោះរុក្ខជាតិ, សត្វ និង មនុស្សគ្រប់គ្នា ដោយមិនលំអៀង (ឆន្ទាគតិ) ។

១០. ឧបេក្ខាបារមី[145] គឺការតាំងចិត្តជាកណ្តាល ពោលគឺ ការធ្វើអារម្មណ៍ព្រងើយចំពោះការស្រឡាញ់ ឬការស្អប់ចំពោះវត្ថុ, រុក្ខជាតិ, សត្វ និង មនុស្ស ។ មនុស្សដែលមានឧបេក្ខាចិត្ត រមែងគ្មានអារម្មណ៍ឈឺចាប់, ខឹងសម្បារ, អំនួត, គុំកួន, សងសឹក ឬស្រឡាញ់ឡើយ ។ ពួកគេនឹងមើលឃើញវត្ថុ, រុក្ខជាតិ, សត្វ, និង មនុស្សនៅក្នុងសភាវៈពិត ។[146]

បារមី ១០ ប្រការនេះ ជាបារមីដែលព្រះពោធិសត្វគ្រប់ព្រះអង្គ បំពេញឲ្យ

139 *Paññā*, *Prajñā*, wisdom
140 *Viriya*, diligence, effort, energy, enthusiasm
141 *Khanti*, *Kshanti*, patience, forebearance, forgiveness
142 *Sacca*, reality, truth
143 *Adhitthāna*, self-determination
144 *Mettā*, kindness
145 *Upekkhā*, equanimity
146 See things as they are, not according to our mental states.

បានត្រាស់ជាព្រះសព្វញ្ញុពុទ្ធ ។ បារមីចែកចេញជា ៣ ថ្នាក់ គឺថ្នាក់ដំបូង ហៅថា បារមី, ថ្នាក់កណ្តាល ហៅថា ឧបបារមី និង ថ្នាក់កំពូលហៅថា បរមត្ថបារមី ។ សព្វថ្ងៃ ពុទ្ធសាសនិកជនមួយចំនួន មិនយល់ច្បាស់នូវអត្ថន័យនៃពាក្យបារមី ពួកគាត់ច្រឡំថា បារមី គឺជាឫទ្ធានុភាព ។ ជំនឿបែបនេះជាហេតុបណ្តាលឲ្យពួកគាត់ចាញ់បោកមនុស្សរកស៊ីបញ្ចូលរូបអ្នកតា, បង់បត់, កន្សែងក្រហម ។ល។ ឧទាហរណ៍ ពួកគ្រូបោកមួយចំនួនពោលកុហកអួតអាងថា ពួកគេមានទសបារមីអ្នកតាភ្នំគូលែន, យាយចេកយាយចម, យាយម៉ៅ ឬព្រះអង្គដងកើ (មុខព្រះបរមរាជវាំង) មកសណ្ឋិតចូលរូបគេ ដែលអាចឲ្យគេទស្សន៍ទាយជោគជតារាសីរបស់មនុស្ស ។ ដោយខ្វះការត្រិះរិះ ពុទ្ធបរិស័ទមួយចំនួននោះ ក៏នាំគ្នាជឿល្បិចកលបោកប្រាស់របស់ពួកគ្រូបោកដែលនាំឲ្យពួកគេបង់ខាតទាំងពេលវេលា និង ប្រាក់កាស ។

ព្រះពុទ្ធទ្រង់បានទទូន្មានបរិស័ទថា មុននឹងជឿអ្វីមួយ បុគ្គលត្រូវពិចារណាមើលហេតុ និង ផលសិន ។ ជំនឿឥតហេតុផល គឺជាអំពើដ៏ល្ងង់ខ្លៅបំផុត ។ សូមយើងសាកល្បងពិចារណាមើល ប្រសិនបើព្រះអង្គដងកើបានបំពេញទសបារមីពិតមែន ម្ល៉េះសមព្រះអង្គដងកើនោះ បានសម្រេចព្រះនិព្វានដូចព្រះពុទ្ធទៅហើយ ។ ប្រសិនបើពុទ្ធបរិស័ទចេះតែនាំគ្នាជឿលើអ្នកតា, ព្រះព្រហ្ម ឬព្រាយបិសាច តើធ្វើដូចម្តេចទើបពួកគាត់នឹងសម្រេចព្រះនិព្វាន? សូមលោកអ្នកពិចារណានូវអបិយជំនឿទាំងនេះឲ្យបានល្អិតល្អន់ ដោយលើកយកបញ្ហាបារមីធ្វើជាគោល ។ ជំនឿឥតហេតុផលនឹងនាំឲ្យលោកអ្នកបង់ខាតលាភ ខាតប្រយោជន៍ឥតអំពើ ។ បុរាណាចារ្យបានពោលថា "ភូតនៅហោ ចោរនៅជាង" និង ពាក្យស្លោកថា "ជាងដែកស៊ីហែកនឹងដៃ ជាងកន្ត្រៃសក់កន្ត្រើង" ។

***

# ១២. កតញ្ញូកតវេទី

ពាក្យថា "កតញ្ញូកតវេទី" ផ្សំមកពីពាក្យ "កតញ្ញូ" និង "កតវេទី" ។ ពាក្យថា "កតញ្ញូ" មានន័យថា អ្នកដឹងឧបការគុណដែលអ្នកឯទៀតបានធ្វើដល់ខ្លួន ។ ពាក្យថា "កតវេទី" មានន័យថា ការដែលបានតប ឬដែលគិតតែនឹងតបស្នងសងគុណដល់អ្នកមានគុណ ។ ដូច្នេះ ពាក្យថា "កតញ្ញូកតវេទី" មានន័យថា អ្នកដឹងឧបការគុណ ហើយបានតបគុណចំពោះបុគ្គលដែលបានធ្វើអំពើល្អចំពោះខ្លួន ។ ចំណែកឯពាក្យថា "កតញ្ញុតា" មានន័យថា សេចក្តីដឹងឧបការគុណ ដែលអ្នកដទៃបានធ្វើដល់ខ្លួន ។ កតញ្ញុតាធម៌ គឺជាឫសគល់នៃកុសលធម៌ទាំងពួង ព្រោះថានៅពេលបុគ្គលម្នាក់មានកតញ្ញុតាធម៌ បុគ្គលនោះតែងមានចិត្តល្អប្រពៃ មានវាចាផ្អែមពីរោះ និងប្រព្រឹត្តអំពើជាកុសលចំពោះមនុស្សដទៃ ។

ការអនុវត្តន៍កតញ្ញុតាធម៌ឲ្យកើតជាប្រយោជន៍ ចាប់ផ្តើមពីសាច់ញាតិជិតស្និទ្ធបំផុតជាមុនសិន ។ មនុស្សគ្រប់រូបគួរតបស្នងចំពោះអំពើល្អ ដែលមាតាបិតារបស់ខ្លួនបានធ្វើចំពោះខ្លួន ។ បុត្រាបុត្រីគួរចាប់ផ្តើមជួយទំនុកបម្រុងឪពុកម្តាយដោយផ្តល់ចំណីអាហារមានជីវជាតិគ្រប់គ្រាន់ ផ្គត់ផ្គង់សម្លៀកបំពាក់ ទីជម្រក និងថ្នាំសង្កូវសម្រាប់ព្យាបាលជំងឺឲ្យពួកគាត់តាមលទ្ធភាព ។ ការគោរពប្រណិប័តន៍លើកតម្កើងមាតាបិតាខ្លួនឲ្យរស់នៅប្រកបដោយគុណធម៌ និង កិត្តិយស គឺជាកតញ្ញូកតវេទី ដ៏សំខាន់មុនការវន្ទាប្រណិប័តន៍ភិក្ខុសង្ឃ ឬបូជាព្រះពុទ្ធបដិមា ។ ជាទូទៅជនជាតិខ្មែរតែងប្រើពាក្យ "ព្រះរស់" សំដៅទៅឪពុកម្តាយ ដែលកំពុងមានជីវិត ។ ចំណែកពាក្យថា "ព្រះរស់" នៅក្នុងសាសនាដទៃ គឺជាការប្រៀបធៀបទៅនឹងពាក្យថា "ព្រះអាទិទេព" ដែលបរិស័ទនៃសាសនាទាំងនោះអួតអាងថា ព្រះអាទិទេពរបស់ពួកគេបានបង្កើតផ្ទៃមេឃ ផែនដី និង អ្វីៗគ្រប់យ៉ាងនៅលើផែនដី ហើយព្រះនោះ

កំពុងរស់នៅស្ថានសួគ៌សព្វថ្ងៃ ។

តាមច្បាប់ធម្មជាតិ មនុស្ស សត្វ និង រុក្ខជាតិដែលមានវត្តមានសព្វថ្ងៃនេះ សុទ្ធតែមានមេបារបស់ខ្លួន ។ ចំណុចនេះមានន័យថា គ្មានព្រះអាទិទេពណាជាអ្នកជប់បង្កើតពួកវាឲ្យមានរូបរាងនោះទេ ។ និយាយដោយឡែក មនុស្សទាំងអស់សុទ្ធតែមានឪពុកម្តាយ ដែលបានបង្កើត និង ចិញ្ចឹមបីបាច់ពួកគេ ។ ដូច្នេះពួកកូនចៅទាំងអស់គួរស្រឡាញ់, គោរព និង បូជាឪពុកម្តាយរបស់ខ្លួន ។ ពួកគេមិនគួរនឹងចំណាយពេលវេលា ទ្រព្យសម្បត្តិ និង កម្លាំងកាយទៅលើការបូជាអាទិទេពណាមួយឡើយ ។

បុរាណាចារ្យខ្មែរ តែងប្រៀបធៀបគុណូបការៈរបស់ឪពុកម្តាយ ទៅនឹងទំហំផែនដី ទំហំមហាសមុទ្រ ឬទម្ងន់ភ្នំហិមពាន្ត(147) ។ លើសពីនោះទៀត បុរាណាចារ្យខ្មែរ បានតាក់តែងកំណាព្យកាព្យឃ្លោង ដើម្បីរំលឹកកូនចៅឲ្យចងចាំអំពើល្អរបស់ឪពុកម្តាយ ដូចពាក្យកាព្យថា "ម៉ែឪមានគុណ គុណមានទម្ងន់ ធ្ងន់ដូចប្រឹថពី គ្មានអ្វីនឹងសង គុណលោកទាំងទ្វី មាសប៉ុនគិរី ថ្លៃពុំស្មើហោង" ។ ឪពុកម្តាយតែងគិតគូរអំពីសេចក្តីសុខចម្រើនរបស់កូនចៅជានិច្ច ។ ក្រៅពីផ្គត់ផ្គង់កូនចៅឲ្យមានអាហារបរិភោគ សម្លៀកបំពាក់ ទីជម្រក និង ថ្នាំសង្កូវគ្រប់គ្រាន់ ឪពុកម្តាយថែមទាំងបង្រៀនបុត្រធីតាឲ្យមានចំណេះដឹងមូលដ្ឋានផងដែរ ។ ពេលបុត្រធីតាចូលដល់វ័យត្រូវមានគូស្រករ ឪពុកម្តាយរៀបពិធីមង្គលការឲ្យកូនសាងគ្រួសារថ្មី ។ ដោយសារឪពុកម្តាយមានគុណូបការៈច្រើនយ៉ាងនេះ ទើបពេលខ្លះជនជាតិខ្មែរប្រើពាក្យថា "អ្នកមានគុណ" ជំនួសពាក្យថា "ឪពុកម្តាយ" ។ ព្រះពុទ្ធទ្រង់ក៏បានហៅមាតាបិតាថា ព្រះព្រហ្ម ព្រះបុព្វទេវា ព្រះបុព្វាចារ្យ និង ព្រះអាហុនេយ្យៈ ដែរ ។

---

147 Himalaya

# ១២.១ ព្រះព្រហ្ម

នៅក្នុងទ្រឹស្តីពុទ្ធសាសនា ឪពុកម្តាយត្រូវបានប្រៀបប្រដូចទៅនឹង "ព្រះព្រហ្ម" ព្រោះលោកទាំងពីរមានព្រហ្មវិហារធម៌[148]លើបុត្រធីតា ។ ព្រហ្មវិហារធម៌មាន ៤ គឺ មេត្តា[149] ករុណា[150] មុទិតា[151] និង ឧបេក្ខា[152] ។ មេត្តា មានន័យថា ឪពុកម្តាយស្រឡាញ់កូនទាំងអស់គ្នា ។ ករុណា មានន័យថា ឪពុកម្តាយអាណិតកូនគ្រប់គ្នា ។ មុទិតា មានន័យថា ឪពុកម្តាយត្រេកអរពេលឃើញកូនមានសេចក្តីសុខចម្រើន ។ ឧបេក្ខា មានន័យថា លោកទាំងពីរព្យាយាមតាំងចិត្តស្ងប់ ស្មោះស្មើនៅកណ្តាល ឬ អព្យាក្រិត្យ មិនលំអៀងទៅរកកូនណាមួយ ។

# ១២.២ ព្រះបុព្វទេវា

ព្រះពុទ្ធទ្រង់បានហៅ មាតាបិតា ថា "ព្រះបុព្វទេវា" ព្រោះឪពុកម្តាយគឺជាទេវតាខាងដើម ។ លោកទាំងពីរ គឺជាអ្នកថែរក្សាជីវិតកូនៗមុនទេវតាទាំងឡាយ ។ មាតាបិតាបានថែទាំបុត្រធីតា ចាប់តាំងពីពេលមាតាមានគភ៌ រហូតដល់ពេលកូនកើត ។ ពេលម្តាយដឹងថាគាត់មានគភ៌ គាត់តែងប្រុងប្រយ័ត្នក្នុងការបរិភោគនំចំណីក្នុងការប្រើឥរិយាបថទាំង ៤ ព្រោះខ្លាចកូនក្នុងផ្ទៃមានបញ្ហាផ្សេងៗ ។ ពេលកូនប្រសូតចាកមាតុទរ មាតាបិតាទាំងទ្វេ បានផ្លាស់វេនគ្នា ថែរក្សាកូនរៀងរាល់យប់ថ្ងៃដោយគ្មានខ្លាចនឿយហត់ ឬត្អូញត្អែរបន្តិចសោះ ។

---

148 *Brahmavihāras* : sublime attitudes ប្រែតាមអត្ថានុរូប "លំនៅរបស់ព្រះព្រហ្ម" "abodes of brahma" ។

149 Benevolence

150 Compassion

151 Sympathy

152 Equanimity

# ១២.៣ ព្រះបុព្វាចារ្យ

ព្រះពុទ្ធទ្រង់បានហៅមាតាបិតាថា "ព្រះបុព្វាចារ្យ" ព្រោះឪពុកម្ដាយ គឺជាគ្រូដើមរបស់កូន ។ បុត្រធីតាទទួលការបង្ហាត់បង្រៀនយ៉ាងច្រើនពីមាតាបិតា ។ ឧទាហរណ៍ការរៀននិយាយភាសាជាតិ ការរៀនដេក ដើរ ឈរ អង្គុយ ឬកិរិយាមារយាទផ្សេងៗ ។ ជាពិសេស មាតាបិតាបានបង្រៀនកូនឲ្យស្គាល់អំពើបាប បុណ្យ គុណ ទោស ខុស ត្រូវ អាក្រក់ ល្អគ្រប់យ៉ាង ។ បន្ទាប់មកមាតាបិតាបាននាំកូនទៅរៀនសូធ្យនៅតាមវត្តអារាម ឬសាលារៀនដើម្បីឲ្យកូនមានចំណេះដឹង និង វិជ្ជាជីវៈសម្រាប់ចិញ្ចឹមជីវិត ។ ដោយសារគ្រូបង្រៀនទាំងឡាយ រាប់ទាំងព្រះពុទ្ធផងដែរ បានជួយផ្ដល់ចំណេះវិជ្ជាផ្សេងៗដល់កូននៅពេលក្រោយ ទើបគ្រូបង្រៀនទាំងនោះមានឈ្មោះថា "បច្ឆាចារ្យ" ឬ គ្រូចុងក្រោយ ។

# ១២.៤ ព្រះអាហុនេយ្យៈ

ព្រះពុទ្ធទ្រង់បានហៅមាតាបិតាថា "ព្រះអាហុនេយ្យៈ"[153] ព្រោះឪពុកម្ដាយ គឺជាបុគ្គល ដែលបុត្រធីតាគួរយកទេយ្យវត្ថុទៅបូជា ។ ពាក្យថា "អាហុនេយ្យបុគ្គល" នៅក្នុងពុទ្ធសាសនា សំដៅយកអរិយបុគ្គល ៤ ពួកមានព្រះសោតាបន្ន, ព្រះសកទាគាមី, ព្រះអនាគាមី និង ព្រះអរហន្ត ។ នៅក្នុងទ្រឹស្តីពុទ្ធសាសនានៃនិកាយថេរវាទ ព្រះអរិយបុគ្គលទាំង ៤ ពួកនេះគឺជាស្រែបុណ្យ[154]ដ៏ប្រសើរ ។ ពុទ្ធបរិស័ទធ្លាប់បានឮថា ប្រសិនបើពួកគាត់ធ្វើបុណ្យ ដាក់ទានជាមួយអាហុនេយ្យបុគ្គលណាមួយ ពេលនោះពួកគាត់នឹងទទួលបានអានិសង្ស[155]ច្រើន ។ រីឯមាតាបិតា ក៏មាន

---

[153] *Āhuneyya*: sacrificial, worthy of offerings or of sacrifice, venerable, adorable, worshipful.

[154] បុញ្ញក្ខេត្ត

[155] ផលនៃកុសល, ផលបុណ្យ, គុណប្រយោជន៍ ឬសេចក្ដីសុខចម្រើនដែលបានអំពីការប្រព្រឹត្តល្អ ។

ឈ្មោះថាជា "ព្រះអាហុនេយ្យបុគ្គល" នៃបុត្រធីតាទាំងឡាយដែរ ព្រោះមាតាបិតាគឺជាបុគ្គលសមនឹងទទួលគ្រឿងបូជារបស់បុត្រធីតា ។ ចំណុចនេះទើបមាតាបិតាមានឋានៈស្មើនឹង ព្រះអរិយបុគ្គល និង មានឈ្មោះថាជា "ព្រះអរហន្ត" របស់បុត្រធីតា ។ ការធ្វើបុណ្យជាមួយមាតាបិតាដូចគ្នានឹង "ការធ្វើបុណ្យជាមួយព្រះអរហន្ត" ដែរ ។ ដូច្នេះមាតាបិតា ជាព្រះអរហន្តនៅក្នុងផ្ទះ ។ ការបូជាដោយទេយ្យវត្ថុដល់ព្រះអរហន្តក្នុងផ្ទះ និង ព្រះអរហន្តខាងក្រៅ (ភិក្ខុសង្ឃ) បានផលានិសង្សស្មើគ្នា ។ ក៏ប៉ុន្តែចំពោះព្រះអរហន្តក្នុងផ្ទះ កូនចៅងាយបូជាជាងព្រោះពួកគាត់រស់នៅក្នុងផ្ទះជាមួយកូនៗ ។ អ្នកប្រាជ្ញខាងពុទ្ធសាសនានៃនិកាយថេរវាទ បានសង្ខេបគុណរបស់មាតាបិតាថា (១) អនន្តគុណ គឺមានគុណរាប់មិនបាន, (២) អនេកគុណ គឺមានគុណច្រើនលើសលុប, (៣) អសមគុណ គឺមានគុណគ្មានអ្វីប្រៀបបាន និង (៤) អប្បមាណគុណ គឺមានគុណប្រមាណមិនបាន ។ ចំណែកព្រះពុទ្ធទ្រង់បានបែងចែកគុណមាតាបិតាជា ៣ គឺ (១) អដ្ឋិគុណ គឺគុណឆ្អឹងធាតុទាំង ៤ ដែលលោកបានបង្កើតរូបកូន, (២) វិសេសគុណ គឺគុណដ៏វិសេសប្រសើរលើសអស់គុណទាំងឡាយក្នុងលោក, (៣) គុណូបការគុណ គឺគុណបីបាច់ថែរក្សា ថ្នាក់ថ្នមកូន ឲ្យរស់រានមានជីវិត ។ សរុបសេចក្តីមក ចំណុចដែលបានរៀបរាប់មកខាងលើ គឺជាកញ្ចក់ឆ្លុះបញ្ចាំងមួយ ដើម្បីឲ្យកូនចៅមើលឃើញអំពើល្អរបស់មាតាបិតាចំពោះបុត្រធីតា ។ មាតាបិតា គឺជាព្រះរស់, ជាព្រះកន្លោង, ជាព្រះអរហន្ត ឬជាទេវតាក្នុងផ្ទះ ដែលបុត្រធីតាគួរគោរពប្រណិប័តន៍ ដោយកាយ វាចា និង ចិត្ត ។

# ១២.៥ ត្រៃបណាម

ការគោរពមាតាបិតាទាំងពីរ ដោយកាយ វាចា និង ចិត្ត ដោយស្មោះស្ម័គ្រ ហៅថា ត្រៃបណាម ។ ត្រៃបណាម មាន ៣ គឺ ៖

១. កាយបណាម គឺការគោរពប្រណិប័តន៍ តាមផ្លូវកាយដូចជាការលើកដៃ

សំពះឪពុកម្តាយ ទាំងពេលជួប និង ពេលលា ។

២. វចីបណាម គឺការប្រើសម្តីទន់ភ្លន់ផ្អែមល្ហែម ក្នុងការសន្ទនាឆ្លើយឆ្លងទៅកាន់ឪពុកម្តាយ ។

៣. មនោបណាម គឺការតាំងចិត្តនឹកឃើញគ្រប់ពេលវេលានូវគុណូបការៈរបស់ឪពុកម្តាយ ។

បុត្រធីតាមួយចំនួនយល់ច្រឡំអត្ថន័យរបស់ពាក្យ "បុណ្យ" ដោយពួកគាត់បែរជាយកចិត្តទុកដាក់គោរពបូជាបុគ្គល ឬវត្ថុដែលមិនគួរនឹងគោរពទៅវិញ ។ កូនចៅខ្លះ មិនត្រឹមតែមិនយកចិត្តទុកដាក់ថែទាំមាតាបិតាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឆ្លៀតកេងចំណេញ ឬនាំទុក្ខព្រួយដល់ឪពុកម្តាយថែមទៀត ។ អ្នកប្រាជ្ញខ្មែរបន្តអប់រំកូនចៅ ដោយបានតាក់តែងពាក្យពេចន៍ទូន្មាន ជាកាព្យឃ្លោង ដើម្បីងាយចងចាំ ។ ខ្ញុំសូមដកស្រង់យកចំណុចខ្លះៗនៅក្នុងកំណាព្យ "ច្បាប់គោរពមាតាបិតា"[156] របស់កវី អ៊ូរ ចុង[157] ដើម្បីធ្វើជាមេរៀនសម្រាប់កូនចៅទាំងឡាយត្រិះរិះពិចារណា ។

# ១២.៦ ច្បាប់គោរពមាតាបិតា

| | | |
|---|---|---|
| ម្យ៉ាងទៀតធ្វើបុណ្យ | ច្រើនតែចោលគុណ | គ្មានគិតរិះរេ |
| បោលទៅតែវត្ត | ម្តាយអត់ទទេ | ព្រោះជឿតាមគេ |
| | រកបុណ្យខាងក្រៅ ។ | |
| ដើមបុណ្យលើផ្ទះ | ខ្លួនកើតទាន់ព្រះ | កន្លោងគង់នៅ |
| បានត្រីត្រកាល | ក្បាលឲ្យម៉ែឪ | កណ្តាលនាំទៅ |
| | យកបុណ្យឯវត្ត ។ | |

[156] បោះពុម្ពថ្ងៃទី ៧ មីនា ១៩៥៥

[157] បណ្ឌិត អ៊ូរ ចុង (កូនរបស់អ្នកកិរម្យេភាសាអ៊ូ ហៅង៉ុយ) បានស្លាប់នៅឆ្នាំ ១៩៥៥

កណ្តាលសុទ្ធឆ្ងាញ់ សាច់ពោះពងខ្លាញ់ ឆ្អែញលោកចុកមាត់
ម៉ែឪជរា ទន្តាបាក់ហ្មត់ ទុកក្បាលឲ្យគាត់
ក្បាលសុទ្ធតែឆ្អឹង ។

នេះហៅបុណ្យខុស ទាំងស្រីទាំងប្រុស ខ្ញុំប្រាប់កុំខឹង
ម៉ែឪនៅរស់ ចូរអស់លោកប្រឹង ឆ្អែញគាត់នៅរឹង
បានឆ្ងាញ់ពិសា ។

ខ្លះជឿបុណ្យខ្លាំង យួរម្ហូបទាំងឆ្នាំង យកទៅវត្តវ៉ា
ម៉ែឪអត់ឃ្លាន ចង់បានណាស់ណ៎ា ភ្លយសួរកូនថា
មានសល់ឬទេ ។

ព្រឹកឡើងឃ្លានបាយ ញ័រពោះញើសខ្វាយ ឃើញសម្លគេ
កូនឆ្លើយរឹងថ្កាន មិនមានសល់ទេ ខ្ញុំស្លគ្រាន់តែ
ទៅវត្តទេឪ ។

ឪពុកសួរថា បើដួសកាលណា ចែកឪខ្លះទៅ
កូនខ្លះឆ្លើយប្រាប់ ថាបាបណាស់ឪ គេថាមិនត្រូវ
ឪស៊ីមុនលោក ។

ម៉ែឪចាស់ ៗ ព្រឹកឡើងឃ្លានណាស់ គួរឲ្យវិយោគ
ឪទារពិសា កូនថាមុនលោក ពុំបានបរិភោគ
គេឲ្យបាបផង ។

នេះបុណ្យផ្កាប់មុខ ឬបុណ្យចោលស្រុក ព្រោះដើរផ្លូវឆ្គង
បុណ្យមិនត្រកាល វិសាលឡើយហោង ព្រោះដើរកន្លង
ឲ្យម៉ែឪអត់ ។

ពួកជនឃ្លានពាន មិនចេះធ្វើទាន ច្រើនធ្វើទានក្បត់

សទ្ធាមិនជ្រៅ ជ្រុលទៅតែវត្ត ឲ្យព្រះដើមអត់
ស្រេកឃ្លានពេកក្រៃ ។
នេះឯងខុសណាស់ មកពីមិនច្បាស់ ច្បាប់ធម៌វិន័យ
បានជាប្រព្រឹត្ត គំនិតព្រៃផ្សៃ បន្ថោកតម្លៃ
នៃអ្នកមានគុណ ។
យល់ខុសស្រឡះ ព្រោះមិនស្គាល់ព្រះ មិនច្បាស់ដើមគុណ
អ្នកប្រាជ្ញបុរាណ ថាបានធ្វើបុណ្យ ត្រូវថ្វាយព្រះមុន
សឹមថ្វាយព្រះសង្ឃ ។
រៀបចង្ហាន់ព្រះ បូជាសំពះ មើលព្រះឲ្យត្រង់
ប្រាជ្ញប្រាប់ជាបែប សង្ខេបតម្រង់ វេរភត្តថ្វាយសង្ឃ
ត្រូវថ្វាយព្រះមុន ។
គឺជូនភោជនា មាតាបិតា បូជាតបគុណ
សឹមថ្វាយព្រះសង្ឃ ទ្រទ្រង់សីលបុណ្យ ព្រោះម្ដាយមានគុណ
រកអ្វីស្មើគ្មាន ។
ត្រូវធ្វើបុណ្យខ្មើត ម៉ែឪស៊ីកើត កំពុងស្រេកឃ្លាន
ម៉ែឪរស់នៅ កូនត្រូវធ្វើទាន បំបាត់ក្ដីឃ្លាន
ហៅធ្វើបុណ្យខ្មើត ។
ហៅបុណ្យខែភ្លឺ កុំចាំគាត់ឈឺ បរិភោគលែងកើត
ជូនគាត់កាលជា ហៅថាបុណ្យខ្មើត គាត់បរិភោគកើត
បានជាងរនោច ។
លុះបាត់ជីវិត បុណ្យខែងងឹត ដូចថ្ងៃ១០រោច
កូនចៅទាំងឡាយ យកបាយឲ្យខ្មោច ម៉ែឥតប្រយោជន៍

ខ្មោចណាចេះស៊ី ។
កត្តិកមាសា ចេញខ្យល់រងា ត្រជាក់ពេញទី
មិនគិតរកភួយ បាន ១ ឬ ២ ទាំងមិនសាមគ្គី
រកពូកជូនគាត់ ។
ត្រូវរករបស់ ជាស្នបទាន់រស់ ដណ្តប់ជូនគាត់
កុំចាំដាច់ខ្យល់ ទើបខ្វល់គ្រប់មាត់ រកស្នបរុំគាត់
ដណ្តប់ឲ្យឧស ។
ឲ្យភ្លើងត្រេកអរ ទទួលអំណរ មិនដឹងត្រូវខុស
ម្តេចមិនខ្វល់ខ្វាយ ជូនម្តាយកាលរស់ ម្តេចចាំខ្យល់អស់
ទើបធ្វើឧឡារ ។
កាលគាត់រស់នៅ ព្រឹកល្ងាចក្តួលក្តៅ ស្រេកឃ្លានអស្ចារ្យ
មិនគិតជូនគាត់ ឲ្យអត់អាហារ ឲ្យតែធ្វើការ
ចាំផ្ទះឲ្យគេ ។
ចំណីត្រីសាច់ ចង់ស្ទើរប្រកាច់ អត់ជូនគាត់ទេ
ដល់ឈើផ្តេតៗ ម្ទេតៗទើបរេ ដេកជុះទើបគេ
ជូននំចំណី ។
ទាំងជិតទាំងឆ្ងាយ មូលមកសួរម្តាយ ទាំងប្រុសទាំងស្រី
ទុរេននំប៉័ង សម្រាំងថ្មីៗ ម្តាយឈើលែងស្តី
រឹងថ្គាមស្ងួតក ។
កូនហៅអីម៉ែ ! ម៉ែស្គាល់ខ្ញុំទេ ? បានចំណីល្អ
ម្តាយពោលខ្សាវៗ គ្រាវៗ ឆ្លើយត ថាអឺឯងមក៍
ម៉ែអរណាស់ណ៎ា ។

កាលម៉ែមិនឈឺ មិនមានជម្ងឺ នោះកូនរាល់គ្នា
មិនអាណិតម៉ែ លុះម៉ែជរា ទើបកូនរាល់គ្នា
មករុញបញ្ចូល ។

ឱម៉ែស្លាប់បាត់ ទើបកូនច្រវាត់ ប្រាប់ញាតិត្រកូល
ឃោសនាធនធាន ព្រៀងលានឲ្យចូល មកជុំប្រមូល
ធ្វើបុណ្យឲ្យខ្មោច ។

ខែផល្គុនចេត្រ ថ្ងៃក្តៅក្រឡេត ឆ្ងាយទឹកហិនហោច
ម៉ែឱចាស់ៗ ក្តៅណាស់អណោច មិនរកទឹកស្រោច
ឪពុកម្តាយសោះ ។

មិនមានថ្នមថ្នាក់ មិនដងទឹកដាក់ ពាងដោយសង្គ្រោះ
ដល់ពេលគាត់ស្លាប់ នោះស្រាប់តែស្មោះ អប់ទឹកក្អមនោះ
ហៅលើកចំអាស ។

ម៉ែឱរស់នៅ មិននាំគ្នាទៅ ធ្វើការប្រវាស់
ដាក់វេនក្រោយមុន តបគុណគាត់ចាស់ ស្លាប់ហើយធ្វើណាស់
ដណ្តើមគ្នាដុស ។

តាមរយៈពាក្យពេចន៍អប់រំនេះ បុត្រធីតាគួរពិចារណាបណ្តាអំពើល្អរបស់មាតាបិតា ។ កូនចៅគួរកាន់កតញ្ញូកតវេទិតាធម៌ចំពោះមាតាបិតាដែលបានចិញ្ចឹមបីបាច់ថែរក្សា និង ផ្តល់ជម្រកសុខសាន្តដល់កូនចៅតាំងពីពេលកូនចាប់បដិសន្ធិរហូតដល់ពេលកូនចម្រើនវ័យវឌ្ឍនាការ ។

***

# ១៣. ត្រៃសរណគមន៍

បរិស័ទនៃសាសនាផ្សេងៗបានចោទសួរពុទ្ធបរិស័ទថា "ព្រះពុទ្ធទ្រង់ត្រាស់ថា ខ្លួនទីពឹងខ្លួន ចុះហេតុអ្វីបានជាពុទ្ធសាសនិកជននាំគ្នាទីពឹងលើព្រះរតនត្រ័យ គឺ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ?" ។ ចំពោះសំណួរនេះ យើងសូមជំរាបថា ពុទ្ធបរិស័ទពិតជាបានលើកតម្កើងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាព្រះរតនត្រ័យ[158] ជាវត្ថុដ៏មានតម្លៃបំផុតក្នុងព្រះពុទ្ធសាសនា ព្រមទាំងបានយកព្រះរតនត្រ័យជាទីពឹងពាក់ ដើម្បីសេចក្ដីសុខ-ចម្រើន សេចក្ដីសង្ឃឹមកក់ក្ដៅក្នុងជីវិតរបស់ពួកគាត់ប្រាកដមែន ។ ខ្ញុំសូមជម្រាបថា មនុស្សត្រូវការជាចំបាច់នូវវត្ថុ ២ យ៉ាង ដើម្បីអាចរស់នៅលើពិភពលោកនេះបាន ពោលគឺ "គ្រឿងទីពឹងរបស់រូបកាយ" និង "គ្រឿងទីពឹងរបស់ចិត្ត" ។

១- គ្រឿងទីពឹងរបស់រូបកាយមានដូចជាសម្ភារៈផ្សេងៗដើម្បីចិញ្ចឹម និងការពាររូបកាយរបស់ខ្លួន ។ សម្ភារៈទាំងនោះមានដូចជា គ្រឿងឧបភោគបរិភោគ, សម្លៀកបំពាក់, ថ្នាំព្យាបាលរោគ, ទីដេកអង្គុយ ឬ ប្រាក់កាសជាដើម ។ នៅក្នុងព្រះពុទ្ធសាសនាផ្នែកខាងព្រះវិន័យ (វិន័យបិដក) គ្រឿងវត្ថុសម្រាប់ទីពឹងរបៀបនេះ មានឈ្មោះថា បច្ច័យ ។

២- គ្រឿងទីពឹងរបស់ចិត្តមានដូចជា សាសនា, ប្រាជ្ញា, មនោគមវិជ្ជា, ទស្សនវិជ្ជាជាដើម ។ ទស្សនវិជ្ជា គឺជាវិជ្ជាកើតឡើងដោយទស្សនៈ (ការពិចារណា) ឬ ជាវិទ្យាសាស្ត្រដែលចែងអំពីគោលការណ៍សំខាន់ៗ និង បុព្វហេតុផ្សេងៗ ឬ អំពីជីវិតមនុស្ស សត្វ និង បរិស្ថាន ។ មនុស្សប្រើទស្សនវិជ្ជា ដើម្បីពិចារណារកហេតុផល និង ស្វែងរកការពិតនៃបាតុភូតធម្មជាតិ ។ នៅក្នុងព្រះពុទ្ធសាសនា គ្រឿងទីពឹងប្រភេទនេះមានឈ្មោះថា សរណៈ ។

---

158 The Triple Gem

នៅលើពិភពលោក មនុស្សនៅតាមទំបន់ផ្សេងៗ បានជ្រើសរើសយកគោលគំនិត, វត្ថុ, សត្វ, មនុស្ស ឬ អាទិទេពខុសៗគ្នាមកធ្វើជាសរណៈរបស់ខ្លួន ។ ឧទាហរណ៍ ជនជាតិឥណ្ឌាបានជ្រើសរើសព្រះព្រហ្ម, ព្រះសិវៈ និង ព្រះវិស្ណុ មកធ្វើជាសរណៈ ។ ជនជាតិខ្មែរមួយចំនួនក៏ធ្លាប់បានជ្រើសយកអ្នកតា, ដុំថ្ម, ភ្នំ, ដើមឈើ, ទន្លេ ឬ សមុទ្រ ធ្វើជាសរណៈរបស់ពួកគេ ។ ប្រវត្តិសាស្ត្របានបង្ហាញឲ្យឃើញថា នៅសតវត្សទី ២០ មនុស្សមួយចំហៀងផែនដី បានជ្រើសយកមនោគមវិជ្ជារបស់បក្សកុម្មុយនិស្តនិយម មកធ្វើជាសរណៈ របស់ពួកគេដែរ ។

ការជ្រើសយកអ្វីមួយមកធ្វើជាទីពឹង ហៅថា សរណគមន៍ ។ សរណគមន៍នីមួយៗតែងផ្តល់ផលល្អ និង ផលអាក្រក់រៀងៗខ្លួន ។ ប្រសិនបើយើងជ្រើសយកសរណគមន៍ខុស យើងនឹងខូចផលប្រយោជន៍, ខាតពេលវេលា និង ខូចសតិបញ្ញាស្មារតី ។ ផ្ទុយទៅវិញ ប្រសិនបើយើងជ្រើសយកសរណគមន៍ត្រូវ យើងនឹងទទួលបានសេចក្តីសុខ-ចម្រើន និង កើនសតិ បញ្ញា ស្មារតី ។

នៅក្នុងព្រះពុទ្ធសាសនា ពុទ្ធបរិស័ទបានជ្រើសយកព្រះពុទ្ធ ព្រះធម៌ និង ព្រះសង្ឃ ធ្វើជាសរណគមន៍ ឬហៅថា ត្រៃសរណគមន៍ ។ ពិសេសជាងនេះទៀត ពុទ្ធបរិស័ទ បានលើកតម្កើង ត្រៃសរណគមន៍ នេះថាជា ព្រះរតនត្រៃ ពោលគឺ ព្រះពុទ្ធរតនៈ, ព្រះធម្មរតនៈ និង ព្រះសង្ឃរតនៈ ។ ពុទ្ធបរិស័ទបានជ្រើសរើសយកព្រះរតនត្រៃជាទីពឹង ព្រោះព្រះរតនត្រៃជាវត្ថុដ៏ប្រសើរប្រពៃថ្លៃថ្លា និង មានគុណប្រយោជន៍សំខាន់បំផុតក្នុងព្រះពុទ្ធសាសនា ។

# ១៣.១ ព្រះពុទ្ធ

ព្រះពុទ្ធជាព្រះបរមសាស្តា ទ្រង់មានព្រះទ័យប្រកបដោយព្រះវិសុទ្ធគុណ ព្រះបញ្ញាគុណ និង ព្រះករុណាគុណ ។ ទ្រង់បានបង្ហាត់បង្រៀនសត្វលោកអំពីច្បាប់ធម្មជាតិ (The law of nature) ពោលគឺ ព្រះធម៌ (dharma) ឬ ធម្មៈ (dhamma) ។

ទោះបីព្រះពុទ្ធទ្រង់បានបរិនិព្វានជាង ២៥០០ ឆ្នាំកន្លងទៅហើយក្តី ក៏មនុស្សរាប់រយលាននាក់នៅលើពិភព នៅតែនាំគ្នាបន្តរំលឹកនឹកដល់ព្រះបញ្ញាគុណ, ព្រះវិសុទ្ធិគុណ និង ព្រះករុណាគុណរបស់ទ្រង់ដែរ ។ គួរកត់សម្គាល់ថា គ្រប់សាសនានៅលើពិភពលោក សុទ្ធតែមានវត្ថុតំណាងឲ្យមេដឹកនាំ ឬអាទិទេពនៃសាសនារបស់ពួកគេ ។ ទោះបីព្រះពុទ្ធទ្រង់បានហាមប្រាមពុទ្ធបរិស័ទ កុំឲ្យកសាងរូបតំណាងរបស់ទ្រង់ក៏ដោយ ក៏ពុទ្ធបរិស័ទនៅតែនាំគ្នាកសាងរូបតំណាងរបស់ព្រះអង្គ ធ្វើជានិមិត្តរូបសម្រាប់គោរពបូជា និង រំលឹកនឹកដល់វត្តមានរបស់ទ្រង់ដែរ ។ ឧទាហរណ៍នៃរូបតំណាងនានានៅក្នុងព្រះពុទ្ធសាសនាមានដូចជា រូបកងចក្រដែលមានកាំ ៨ តំណាងឲ្យធម្មចក្កប្បវត្តនសូត្រ, រូបសេះគ្មានអ្នកជិះ, រូបព្រះបាទទាំងគូ (ស្នាមព្រះពុទ្ធបាទ) ជាដើម ។ ក្រោយមក ពុទ្ធបរិស័ទដែលបានទទួលឥទ្ធិពលរបស់ទស្សនវិជ្ជាក្រិច បាននាំគ្នាកសាងព្រះពុទ្ធរូបតាមរចនាបទក្រិច នៅក្នុងរាជាណាចក្រគន្ធារៈ (Gandhāra) ដែលនៅក្នុងប្រទេសអាហ្វហ្គានីស្ថាន (Afghanistan) សព្វថ្ងៃ ។

## ១៣.១.១ បូជាព្រះពុទ្ធបដិមា

បរិស័ទនៃពាហិរសាសនា (សាសនាផ្សេងពីព្រះពុទ្ធសាសនា) បានចោទសួរពុទ្ធបរិស័ទថា ហេតុអ្វីពុទ្ធសាសនិកជនគោរពបូជាព្រះពុទ្ធបដិមា បើព្រះពុទ្ធទ្រង់បានបរិនិព្វានយូរអង្វែងទៅហើយនោះ? ពុទ្ធបរិស័ទឆ្លើយតបថា ការគោរពបូជាព្រះពុទ្ធបដិមាសព្វថ្ងៃនេះ មិនមែនជាការគោរពបូជាថ្វាយបង្គំដុំឥដ្ឋ ដុំថ្ម ឬ វត្ថុធាតុខាងក្រៅនោះទេ ។ ពុទ្ធបរិស័ទសម្លឹងមើលព្រះពុទ្ធរូប ដ៏មានព្រះភ័ក្ត្រញញឹមបំព្រងដោយបង្អោនកាយ វាចា ចិត្តទៅកាន់ផ្នែកខាងក្នុង ។ ពុទ្ធបរិស័ទគិតថា ព្រះពុទ្ធទ្រង់គឺជាព្រះអរហន្តដ៏ប្រសើរ ទ្រង់បានត្រាស់ដឹងសម្មាសម្ពោធិញ្ញាណ ហើយទ្រង់បានបង្រៀនច្បាប់ធម្មជាតិ (ពុទ្ធធម៌) ទៅដល់មនុស្សនៅលើពិភពលោក ។ ការគោរព

ព្រះពុទ្ធរូបសព្វថ្ងៃនេះ គឺជាកិរិយាថ្វាយបង្គំ (នមស្ការ) ចំពោះព្រះបញ្ញាគុណ ព្រះវិសុទ្ធគុណ និង ព្រះករុណាគុណរបស់ព្រះអង្គតែប៉ុណ្ណោះ ។

លើសពីនោះទៀត ពុទ្ធបរិស័ទនមស្ការព្រះពុទ្ធបដិមា មិនមែនដើម្បីសុំសេចក្តីអនុគ្រោះពីព្រះអាទិទេពទេ គឺគ្រាន់តែជាការគោរពអ្វីៗដែលជារូបតំណាងព្រះពុទ្ធប៉ុណ្ណោះ ។ នៅក្នុងព្រះពុទ្ធសាសនា គ្មានការសម្លាប់សត្វដូចជា ចៀម ពពែ គោ ក្របី សេះ ដំរី សម្រាប់បូជាព្រះអាទិទេពដើម្បីសុំសេចក្តីសុខចម្រើនទេ ។ ការបូជាគ្រឿងសក្ការៈដូចជាទៀន ធូប ផ្កា ភ្ញី ចំពោះព្រះពុទ្ធបដិមា គឺជាការបូជាគុណមេត្តា និង ករុណា របស់ព្រះពុទ្ធ ។ កិច្ចពិធីនេះ ត្រូវបានរៀបចំឡើងហាក់បីដូចជាការបូជាចំពោះព្រះពុទ្ធកាលពីពេលព្រះអង្គទ្រង់គង់ជាធរមាន ។ ពុទ្ធបរិស័ទយកព្រះអង្គធ្វើជាគំរូ ជាគតិប្រចាំចិត្ត និង ប្រតិបត្តិតាមធម្មវិន័យរបស់ព្រះអង្គ ដើម្បីទទួលបានប្រយោជន៍ ៣ យ៉ាង គឺ (១) ទិដ្ឋធម្មិកត្ថប្រយោជន៍ ឬប្រយោជន៍បច្ចុប្បន្ន (២) សម្បរាយិកត្ថប្រយោជន៍ ឬប្រយោជន៍បរលោក និង (៣) បរមត្ថប្រយោជន៍ ឬប្រយោជន៍ព្រះនិព្វាន ។

គួរកត់សម្គាល់ថា ព្រះពុទ្ធទ្រង់មិនបានប្រាថ្នាគ្រឿងសក្ការៈបូជាទាំងឡាយនោះទេ ។ គោលបំណងចម្បងរបស់ទ្រង់គឺចង់ឲ្យពុទ្ធបរិស័ទប្រតិបត្តិតាមធម៌វិន័យឲ្យបានត្រឹមត្រូវតាមគន្លងធម៌ ។ នោះគឺជាវិធីដែលអាចជួយឲ្យមនុស្សរួចចាកទុក្ខគ្រប់ប្រការ ។ ព្រះពុទ្ធបានសម្តែងថា "បូជាទាំងឡាយនេះមានពីរយ៉ាង ។ បូជាពីរយ៉ាង តើដូចម្តេច ។ គឺអាមិសបូជា១ ធម្មបូជា១ ។ ... បូជាទាំងឡាយមានពីរយ៉ាងនេះឯង ។ ... បណ្តាបូជាពីរយ៉ាងនេះ ធម្មបូជានុះប្រសើរជាងគេ" ។[159] ធម្មបូជាក្នុង

[159] ព្រះត្រៃបិដក សៀវភៅលេខ ៤០ ទំព័រទី ២១០ (សុត្តន្តបិដក អង្គុត្តរនិកាយ ទុកនិបាត)

បរិបទនេះ មានន័យថា បដិបត្តិបូជា ប៉ុន្តែគេនិយមប្រើបដិបត្តិបូជាជាងធម្មបូជា ព្រោះបដិបត្តិបូជាស្តាប់ទៅពីរោះ ហើយងាយយល់ន័យ ។

## ១៣.១.២ អាមិសបូជា

អាមិសបូជា គឺជាការបូជាដោយប្រើគ្រឿងសក្ការៈដូចជាទៀន ធូប ផ្កា ភ្លើ ។ ពាក្យថា អាមិស មានអត្ថន័យច្រើនយ៉ាងនៅក្នុងបរិបទខុសៗគ្នា ឧទាហរណ៍ នៅក្នុង ពាក្យ អាមិសសុខ ពាក្យ អាមិស មានន័យថា វត្ថុដែលជាគ្រឿងទាក់ចិត្ត ឬ ជាគ្រឿង ជន្លជន្លេញចិត្ត ។ ដូច្នេះពាក្យ អាមិសសុខ មានន័យថា សេចក្តីសុខដែលមានតណ្ហា ជាគ្រឿងទាក់ចិត្ត ឬហៅម្យ៉ាងទៀតថា លោកិយសុខ ឬ កាមសុខ ក៏បាន ។

នៅក្នុងព្រះវិន័យបិដក ពាក្យ អាមិស មានន័យថា បច្ច័យ ។ ពាក្យថា បច្ច័យ គឺជាគ្រឿងអាស្រ័យរបស់សត្វលោក ឬ គ្រឿងទ្រទ្រង់ជីវិតរបស់សព្វសត្វ ឲ្យប្រព្រឹត្ត ទៅបានក្នុងលោក ។ បច្ច័យមាន ៤ យ៉ាង ឬហៅថា ចតុប្បច្ច័យ គឺ (១) ចីវរប្បច្ច័យ គឺត្រៃចីវរ ឬសម្លៀកបំពាក់, (២) បិណ្ឌបាតប្បច្ច័យ គឺចង្ហាន់បិណ្ឌបាត ឬ ភោជនាហារ, (៣) សេនាសនប្បច្ច័យ គឺទីជម្រកអាស្រ័យ ដូចជា កុដិ សាលា វិហារ ផ្ទះសម្បែង ភូមិគ្រឹះ ឬ វិមាន និង (៤) គិលានភេសជ្ជប្បច្ច័យ គឺថ្នាំសម្រាប់ព្យាបាល រោគផ្សេងៗ ដូចជាថ្នាំលាប ថ្នាំលេប ថ្នាំផឹក ឬថ្នាំចាក់ ។ ដូច្នេះ ពាក្យថាអាមិសទាន មានន័យថា ការឲ្យ ការជូន ការប្រគេន ឬ ការថ្វាយ បច្ច័យ ៤ នេះ ។ ជាការពិត បច្ច័យ ៤ មានសារៈសំខាន់ចំពោះជីវិត ក៏ប៉ុន្តែព្រះពុទ្ធទ្រង់បានសម្តែងថា "សព្វទានំ ធម្មទានំ ជិនាតិ" ប្រែថា "ធម្មទានឈ្នះអស់ទានទាំងពួង" ។ ចំណុចនេះឆ្លុះបញ្ចាំងឲ្យ ឃើញថា ទោះបីមនុស្សបំពេញគ្រប់សេចក្តីត្រូវការខាងរាងកាយ ក៏មនុស្សនៅតែខ្វះ ខាតសេចក្តីត្រូវការខាងផ្លូវចិត្តដែរ ។ ចំណុចសំខាន់គឺនៅត្រង់ការចេះអប់រំចិត្តឲ្យ យល់ព្រមទទួលស្គាល់ការពិត រីករាយចំពោះអ្វីដែលមាន និង លះចោលគំនិតដែល

នឹងនាំទុក្ខដាក់ខ្លួន ។ ដើម្បីសម្រេចគោលដៅនេះ មនុស្សគ្រប់រូបត្រូវចំណាយវេលាព្យាយាមហ្វឹកហាត់ចិត្តតាមរយៈបដិបត្តិបូជា ។

## ១៣.១.៣ បដិបត្តិបូជា

ពាក្យថា បដិបត្តិបូជា នៅទីនេះមានន័យថា ការអនុវត្តយ៉ាងត្រឹមត្រូវតាមធម៌វិន័យរបស់ព្រះពុទ្ធ ។ ព្រះពុទ្ធទ្រង់បានសម្តែងថា "អ្នកណាបូជាព្រះអង្គដោយបដិបត្តិបូជា ឬ ប្រតិបត្តិត្រឹមត្រូវតាមធម៌វិន័យ អ្នកនោះឈ្មោះថា គោរពបូជាតថាគតដោយការបូជាដ៏ប្រសើរលើស" ។ ទ្រង់បានត្រាស់ចំពោះភិក្ខុវក្កលិ ដែលចង់ជួបថ្វាយបង្គំព្រះអង្គដោយផ្ទាល់ថា "មានប្រយោជន៍អ្វីដោយកាយសម្អុយ ដែលអ្នកឃើញហើយនេះ ។ ...បុគ្គលណាមួយឃើញធម៌ បុគ្គលនោះឈ្មោះថាឃើញតថាគត បុគ្គលណាឃើញតថាគត បុគ្គលនោះឈ្មោះថាឃើញធម៌"។[160] ដូច្នេះអ្នកអានគួរវិភាគពិចារណាពុទ្ធវចនៈ និង ប្រតិបត្តិតាមយ៉ាងសុក្រឹត ដើម្បីទទួលបានប្រយោជន៍ ៣ យ៉ាង គឺ ប្រយោជន៍បច្ចុប្បន្ន, ប្រយោជន៍បរលោក និង ប្រយោជន៍ព្រះនិព្វាន ។

## ១៣.២ ព្រះធម៌

នៅក្នុងទ្រឹស្តីពុទ្ធនិយម ព្រះធម៌គឺជាច្បាប់ធម្មជាតិ ដែលព្រះពុទ្ធទ្រង់បានត្រាស់ដឹង ។ ព្រះធម៌នៅទីនេះគឺសំដៅទៅដល់ធម្មចក្កប្បវត្តនសូត្រ ដែលព្រះអង្គទ្រង់បានសម្តែងនៅឯសួន ឥសិបតនមិគទាយវ័ន (Isipatana) សព្វថ្ងៃនៅទីក្រុងសារនាថ (Sarnath) ជិតក្រុង ពារាណសី (Varanasi, Banares, Kashi) នៅក្នុងរដ្ឋឧត្តរប្រទេស (Uttar Pradesh) ភាគខាងជើងនៃប្រទេសឥណ្ឌា ។ ពាក្យថា ធម្មចក្ក (Setting in Motion the Wheel of Dharma) គឺជាធម៌ដូចជាកង់ ដែលព្រះពុទ្ធទ្រង់ត្រាស់សម្តែង ជាដំបូងបង្អស់ក្នុងកាលព្រះអង្គបានត្រាស់ ទើបបាន ៥៩ ថ្ងៃ ។ នៅទី

---

160 ព្រះត្រៃបិដក សៀវភៅលេខ ៣៣ ទំព័រទី ២៧៤ ( សុត្តន្តបិដក សំយុត្តនិកាយ ថេរវគ្គ )

នោះទ្រង់បានសម្តែងអំពីអរិយសច្ច ៤ (Four Noble Truths) បង្វិលដំណើរសេចក្តីដូចជាកង់រទេះ ដើម្បីឲ្យមនុស្សលោកស្គាល់សេចក្តីពិត ពោលគឺ ទុក្ខ (សេចក្តីព្រួយលំបាក), កំណើតទុក្ខ ឬហេតុដែលនាំឲ្យកើតទុក្ខ, សេចក្តីរំលត់ទុក្ខ ឬធម៌សម្រាប់រំលត់ទុក្ខ និង ផ្លូវ ឬឧបាយនៃសេចក្តីរំលត់ទុក្ខ ។

គួរកត់សម្គាល់ថា នៅពុទ្ធសម័យមនុស្សច្រើននាក់ មានគំនិតកែប្រែរបៀបគិតពិចារណា និង របត់សង្គមនៅក្នុងប្រទេសរបស់ខ្លួន ។ នៅប្រទេសឥណ្ឌា លោក មហាវីរៈ (*Mahavira*) កើតនៅខ្ទង់ឆ្នាំ ៥៩៩ មុនគ្រិស្តសករាជ និង ស្លាប់នៅខ្ទង់ឆ្នាំ ៤៨០ មុនគ្រិស្តសករាជ ។ លោក មហាវីរៈ គឺជាមេដឹកនាំសាសនា ជៃន (Jainism) ដ៏ល្បីល្បាញ, ជាអាចារ្យ (*Tirthankara*) ទី ២៤ និង ជាអាចារ្យចុងក្រោយនៃសាសនា ជៃន ។ គោលដៅរបស់លោក មហាវីរៈ គឺលើកកម្ពស់គុណភាពនៃជីវិតរបស់មនុស្សលោក ។ នៅប្រទេសឥណ្ឌាដដែល ព្រះអង្គសិទ្ធត្ថ គោតម ឬព្រះពុទ្ធ បានប្រសូតនៅខ្ទង់ឆ្នាំ ៥៦៣ មុនគ្រិស្តសករាជ និង បរិនិព្វាននៅខ្ទង់ឆ្នាំ ៤៨៣ មុនគ្រិស្តសករាជ ។ ព្រះពុទ្ធបានតស៊ូពុះពារគ្រប់ឧបសគ្គដើម្បីជួយរំដោះជនជាតិឥណ្ឌា ពិសេសមនុស្សនៅក្នុងវណ្ណៈសូទ្រ (Shudra) និង ពួកចណ្ឌាល (Dalit, Untouchable people) ឲ្យរួចពីមនោគមវិជ្ជាពួកព្រាហ្មណ៍ និង ព្រហ្មញ្ញសាសនា ដែលជានិច្ចកាលរួមដៃគ្នានឹងមនុស្សនៅក្នុងវណ្ណៈក្សត្រ (មេដឹកនាំ) ប្រើប្រាស់កិច្ចពិធីសាសនា និង ទំនៀមទម្លាប់ចាស់គំរិលដើម្បីជិះជាន់ កេងប្រវ័ញ្ច យ៉ាងអយុត្តិធម៌ទៅលើប្រជាជនសាមញ្ញ ។ ពួកទស្សនវិទូនៅបស្ចិមប្រទេសបានហៅព្រះធម៌ ឬសេចក្តីបង្រៀនរបស់ព្រះពុទ្ធ ថាជាទស្សនវិជ្ជា (Philosophy) និង ហៅព្រះពុទ្ធ ថាជាទស្សនវិទូ (Philosopher) ។ នៅប្រទេសចិន លោក ខុងជឺ (*Kong Qiu, Kong Fuzi,* Confucius) កើតនៅខ្ទង់ឆ្នាំ ៥៥១ មុនគ្រិស្តសករាជ និង ស្លាប់នៅខ្ទង់ឆ្នាំ ៤៧៩ មុនគ្រិស្តសករាជ ។ លោក ខុងជឺ គឺជាគ្រូបង្រៀន, ជាអ្នកនយោបាយ និង ជាទស្សវិទូដ៏

ល្បីល្បាញមួយរូប ព្រោះលោកបានចំណាយពេលមួយជីវិតដើម្បីកែប្រែរបៀបគិតពិចារណា និង របៀបដឹកនាំប្រទេសប្រកបដោយយុត្តិធម៌ គុណធម៌ និង សមធម៌ ។ នៅប្រទេសក្រិច (Greece) លោកសូក្រាត (Socrates) កើតនៅខ្ទង់ឆ្នាំ ៤៧០ មុនគ្រិស្តសករាជ និង ស្លាប់នៅខ្ទង់ឆ្នាំ ៣៩៩ មុនគ្រិស្តសករាជ ។ លោក សូក្រាត គឺជាទស្សនវិទូក្រិចមួយរូប ដែលបានចំណាយពេលនៅតាមផ្លូវថ្នល់ នៃក្រុងអាថែន (Athens) ដើម្បីបង្រៀនយុវជនក្រិច ឲ្យចាប់ផ្តើមរបៀបគិតពិចារណាថ្មី ខុសពីរបៀបគិតរបស់ពួកសូហ្វីស (Sophists) ដែលពូកែប្រើវោហាសាស្ត្រ បំភ្លៃការពិត (rhetorics) ។ មនុស្សនៅលើពិភពលោក បានស្គាល់លោកសូក្រាត តាមរយៈសិស្សជំនិតគាត់គឺលោក ប្លាតុង (Plato) តាមរយៈស្នាដៃនិពន្ធឈ្មោះ "កិច្ចសន្ទនា" (Dialogues) ។ ពួកទស្សនវិទូលោកខាងលិច បានយករបៀបគិតពិចារណារបស់លោកសូក្រាត មកកែច្នៃឲ្យកាន់តែប្រសើរឡើងថែមទៀត ដើម្បីធ្វើជាមូលដ្ឋាននៃទស្សនវិជ្ជាបស្ចិមប្រទេស ពោលគឺ "វិធីរបស់លោកសូក្រាត" (Socratic Method) ។

# ១៣.៣ ព្រះសង្ឃ

ព្រះសង្ឃគឺជាសង្ឃសាវករបស់ព្រះពុទ្ធ, គឺជាស្រែបុណ្យ ឬបុញ្ញក្ខេត្តរបស់ពុទ្ធមាមកជន និង ជាអ្នកបន្តវេនផ្សព្វផ្សាយព្រះពុទ្ធដីកា ទៅដល់មនុស្សទាំងឡាយនៅលើពិភពលោក ។ ព្រះសង្ឃ ត្រូវបានបែងចែកចេញជា ២ ប្រភេទ គឺ សម្មតិសង្ឃ (សង្ឃបុថុជ្ជន) និង អរិយសង្ឃ (សង្ឃប្រសើរ) ។

## ១៣.៣.១ សម្មតិសង្ឃ

សម្មតិសង្ឃ ឬសង្ឃបុថុជ្ជន គឺជាក្រុមភិក្ខុ ដែលឃើញភ័យក្នុងវដ្តសង្សារ, មានការភ្ញាក់រឭក និង ចូលបួសក្នុងពុទ្ធសាសនា ។ សម្មតិសង្ឃពុំទាន់បានកាត់ផ្តាច់សំយោជនកិលេសណាមួយនៅឡើយទេ ប៉ុន្តែភិក្ខុទាំងនោះ ខំព្យាយាមប្រព្រឹត្តិធម៌ធ្វើកាយវាចាចិត្តឲ្យស្ងប់ចាកបាប ដោយចម្រើនសមថកម្មដ្ឋាន ឬ វិបស្សនាកម្មដ្ឋាន

តាមគន្លងព្រះពុទ្ធោវាទ ។ នៅក្នុងកិច្ចសន្ទនារវាង ជាណុស្សោណិព្រាហ្មណ៍ (*Janussoni*) [161] និង ព្រះពុទ្ធ ជាណុស្សោណិព្រាហ្មណ៍បានសួរព្រះពុទ្ធថា "បពិត្រព្រះគោតមដ៏ចំរើន ចុះពួកសមណៈមានអ្វីជាទីប្រាថ្នា មានអ្វីជាទីពិចារណា មានអ្វីជាទីតាំងមាំ មានអ្វីជាទីប្រកាន់ មានអ្វីជាទីបំផុត" ។ ព្រះពុទ្ធទ្រង់បានតបថា "ម្នាលព្រាហ្មណ៍ ពួកសមណៈមានខន្តិនិងភាវៈស្ងៀមជាទីប្រាថ្នា មានបញ្ញាជាទីពិចារណា មានសីលជាទីតាំងមាំ មានសេចក្តីមិនកង្វល់ជាទីប្រកាន់ មាននិព្វានជាទីបំផុត " ។ ចំណុចនេះមានន័យថា ភិក្ខុដែលជាសមណៈពិតប្រាកដ ប្រាថ្នាតែភាពស្ងប់ស្ងាត់ ប្រើបញ្ញាពិចារណារកការពិត មានចិត្តតាំងមាំក្នុងសីលក្នុងវិន័យ គ្មានកង្វល់ជាប់ជំពាក់ចិត្តនឹងអាមិសទាន និង ប្រតិបត្តិធម៌ដើម្បីរំលត់រាគៈ ទោសៈ និង មោហៈ ។

សរុបសេចក្តីមក ព្រះសម្មាសម្ពុទ្ធទ្រង់បានរៀបចំការរស់នៅរបស់អ្នកបួសក្នុងសាសនានេះយ៉ាងល្អប្រពៃ ជាភេទខ្ពង់ខ្ពស់ (ឧត្តមភេទ) ដោយធម៌ដ៏ប្រសើរ និង សមជាសាវ័ករបស់ព្រះអង្គពិតៗ ។

## ១៣.៣.២ អរិយសង្ឃ

តាមន័យទូទៅ អរិយសង្ឃ គឺជាសង្ឃសាវ័ក ដែលលោកបានកំចាត់ចោលសំយោជនៈ[162]ពីសន្តានចិត្ត និង មិនចាំបាច់ប្រព្រឹត្តធម៌ទៀតទេ ។ អរិយសង្ឃ ត្រូវ

---

161 ព្រះត្រៃបិដក សៀវភៅលេខ ៤៦ ទំព័រទី ១៦៩ (អង្គុត្តរនិកាយ ឆក្កនិបាត ធម្មិកវគ្គ) (AN 6:52)

162 សំយោជនៈ (*samyojana,* fetter) គឺកិលេសជាគ្រឿងប្រកបចិត្ត ឬកិលេសរឹងត្អឹងជាគ្រឿងទាក់ទ្ធាក់រួបរឹត ដែលអាស្រ័យនៅនឹងចិត្ត ។ សំយោជនៈ មាន ១០ ប្រភេទគឺ **សក្កាយទិដ្ឋិ** គឺការមើលឃើញកាយថាជារបស់ខ្លួន, **វិចិកិច្ឆា** គឺសេចក្តីសង្ស័យស្ទាក់ស្ទើរ, **សីលព្វតបរាមាសៈ** គឺការជាប់ជំពាក់ចិត្តនៅក្នុងកិច្ចខាងសាសនាឬការបួងសួងផ្សេងៗ, **កាមឆន្ទៈ** គឺតម្រេកក្នុងកាម, **បដិឃៈ** គឺសេចក្តីចង្អៀតចិត្ត ឬការថ្នាំងថ្នាក់ចិត្ត, **រូបរាគៈ** គឺតម្រេកក្នុងរូបភព, **អរូបរាគៈ** គឺតម្រេកក្នុងអរូបភព, **មានៈ** គឺសេចក្តីប្រកាន់មាំ, **ឧទ្ធច្ចៈ** គឺចិត្តរសាប់រសល់ និង **អវិជ្ជា** គឺការមិនដឹងច្បាស់នូវអរិយសច្ច និង បដិច្ចសមុប្បាទ ។

បានរាប់បញ្ចូលក្នុងជំពូកអរិយបុគ្គល ៤ ប្រភេទ គឺ (១) ព្រះសោតាបន្ន, (២) ព្រះសកទាគាមី, (៣) ព្រះអនាគាមី និង (៤) ព្រះអរហន្ត ។ ព្រះសោតាបន្ន គឺជាបុគ្គលដែលលះបង់ចោល សំយោជនៈ (fetter) បាន ៣ ពោលគឺ សក្កាយទិដ្ឋិ (belief in a self), វិចិកិច្ឆា (doubt, uncertainty) និង សីលព្វតបរាមាសៈ (attachment to rites and rituals) ។ ព្រះសកទាគាមី គឺជាបុគ្គលដែលលះចោល សំយោជនៈបាន ៣ ដែរ ប៉ុន្តែពួកលោកបានធ្វើឲ្យ កាមឆន្ទៈ (sensual desire) និងបដិឃៈ (repugnance, resentment) ស្រាលជាងសោតាបន្ន ។ ព្រះអនាគាមី ជាបុគ្គលដែលលះសំយោជនៈបាន ៥ គឺ សក្កាយទិដ្ឋិ, វិចិកិច្ឆា, សីលព្វតបរាមាសៈ, កាមឆន្ទៈ និង បដិឃៈ ។ ព្រះអរហន្ត គឺជាបុគ្គលដែលលះចោលសំយោជនៈទាំង ១០ អស់ពីខន្ធសន្តាន ។ ព្រះសោតាបន្ន, ព្រះសកទាគាមី និង ព្រះអនាគាមី មានឈ្មោះថា សេក្ខបុគ្គល ព្រោះលោកបន្តបដិបត្តិធម៌ទៀត ដើម្បីលះសំយោជនៈឲ្យអស់ពីសន្តានចិត្ត ។ ព្រះអរហន្ត មានឈ្មោះថា អសេក្ខបុគ្គល ព្រោះបានលះចោលសំយោជនៈអស់ពីសន្តាន ។

សរុបសេចក្តីមក ពុទ្ធសាសនិកជនទីពឹងព្រះរតនត្រៃ ពុំមែនមានន័យថា ទីពឹងបច្ច័យនោះទេ គឺទីពឹងលើព្រះធម៌ ពឹងលើគំនិតប្រាជ្ញា ដែលជាមធ្យោបាយសម្រាប់ដឹកនាំខ្លួនឲ្យបានសេចក្តីសុខ សេចក្តីចម្រើន ទាំងក្នុងបច្ចុប្បន្នកាល ទាំងក្នុងអនាគតកាល ។

*

ខ្លះបួសគ្មានខ្មាសគ្មានខ្លាចបាប ហៅបួសបន្ទាបព្រះជិនស្រី
បួសមួយជីវិតឥតដឹងអ្វី ដូចគោក្របីនៅនឹងមនុស្ស ។

-- បណ្ឌិត អ៊ូ ចុង ( ស្លាប់ឆ្នាំ ១៩៥៥ )

***

# ១៤. ពុទ្ធសាសនសុភាសិត

សាសនានីមួយៗនៅលើពិភពលោក សុទ្ធសឹងតែមានសុភាសិតសម្រាប់ជាគតិទូន្មាន ប្រៀនប្រដៅបរិស័ទរបស់ពួកគេ ។ ព្រះពុទ្ធសាសនាក៏មានសុភាសិតច្រើនសន្ធឹកដែរ ប៉ុន្តែយើងសូមលើកយកសុភាសិតមួយចំនួន មកជូនពុទ្ធសាសនិកដើម្បីជាជំនួយដល់សតិ បញ្ញា ក្នុងការអប់រំទូន្មានខ្លួនឲ្យបានល្អប្រសើរក្នុងជីវិត ។

## ១៤.១ សម្រង់ពុទ្ធភាសិតខ្លះៗ

ខាងក្រោមនេះគឺជាការកែសម្រួលពាក្យពេចន៍ និង ឃ្លាប្រយោគដើម្បីឲ្យអ្នកអាន និង អ្នកស្តាប់ងាយយល់អត្ថន័យពុទ្ធភាសិត ដែលមានចែងនៅក្នុងគម្ពីរព្រះត្រៃបិដក និង គម្ពីរផ្សេងៗទៀត ។

(១) បុគ្គលគួរទូន្មានខ្លួនឯងឲ្យបានល្អសិនមុននឹងទូន្មានអ្នកដទៃ ព្រោះថាបុគ្គលម្នាក់ៗទូន្មានខ្លួនឯងបានដោយកម្រ ។[163]

(២) យសរមែងកើតមានដល់បុគ្គលដែលមានសេចក្តីព្យាយាម, ភាពរវៀសរវៃ, ការពិចារណា និង ការមិនប្រមាទ (carelessness, negligence) ។

(៣) បុគ្គលសាបព្រោះពូជណារមែងទទួលបានផ្លែផ្កាពីពូជនោះ ។

(៤) បុគ្គលដែលមានសេចក្តីព្យាយាមត្រូវមានការភ្ញាក់រលឹកជានិច្ច, មិនដេកច្រើន និង មិនខ្ជិលច្រអូស ។

(៥) បុគ្គលដែលធ្វើបដិបត្តិបូជាចំពោះព្រះពុទ្ធដោយខន្តី មានឈ្មោះថាជាបុគ្គលដែលបានបូជាដ៏ប្រពៃចំពោះព្រះពុទ្ធ ។

(៦) ខន្តីជាគុណធម៌ដែលធ្វើឲ្យចម្រើនដល់សីល និង សមាធិ ។

---

163 សុភាសិតនេះមានន័យស្រដៀងនឹងសុភាសិតខ្មែរថា "គីង្គក់លក់ថ្នាំស្រែង" ដែរ ។

(៧) ទឹកភ្លៀងរមែងស្រក់ចូលផ្ទះដែលមានដំបូលធ្លុះធ្លាយ ។ រាគៈរមែងដឹកនាំចិត្តបុគ្គលដែលមិនបានអប់រំខ្លួនក៏យ៉ាងនោះដែរ ។

(៨) ភ្នំថ្មតាន់រមែងមិនញាប់ញ័រដោយខ្យល់យ៉ាងណា បណ្ឌិតរមែងមិនរំភើបដោយសារការតិះដៀល និង ការសរសើរក៏យ៉ាងនោះដែរ ។

(៩) បុគ្គលមានសេចក្តីសុខក្នុងបច្ចុប្បន្ន ព្រោះការបរិច្ចាគក្នុងអតីតកាល ។

(១០) ផ្លូវទឹកទាំងឡាយដ៏ពេញព្រៀប តែងញុំាងសាគរឲ្យពេញព្រៀបយ៉ាងណា ទានដែលបុគ្គលធ្វើក្នុងលោកនេះ រមែងសម្រេចផលដល់បុគ្គល នៅឯបរលោកក៏យ៉ាងនោះដែរ ។

(១១) បុគ្គលណាឲ្យចតុប្បច្ច័យដល់ជនដទៃ បុគ្គលនោះឈ្មោះថាបានឲ្យរបស់ទាំងពួង ។ បុគ្គលណាដែលប្រៀនប្រដៅធម៌ដល់ជនដទៃ បុគ្គលនោះឈ្មោះថាឲ្យអមតនិព្វាន ។

(១២) បុគ្គលដែលប្រតិបត្តិតាមពុទ្ធវចនៈ នឹងមិនទៅកាន់ទុគ្គតិឡើយ ។

(១៣) បុគ្គលដែលមានចិត្តក្រអឺតក្រទម តែងមិនចូលចិត្តព្រះសទ្ធម្ម ។

(១៤) បុគ្គលណាប្រព្រឹត្តតាមពុទ្ធវចនៈ បុគ្គលនោះនឹងសម្រេចនិព្វាន ។

(១៥) បុគ្គលដែលប្រាថ្នាសុខលើគំនរទុក្ខរបស់ជនដទៃ រមែងគេចមិនផុតពីកម្មពៀររបស់ខ្លួនឡើយ ។

(១៦) ទោះបីសមណព្រាហ្មណ៍, ច្រាំងសមុទ្រ, ព្រះចន្ទ ឬ ព្រះអាទិត្យមានកម្លាំងមហិមាយ៉ាងណាក៏ដោយ ក៏គង់នៅចាញ់មាយាស្ត្រីដែរ ។

(១៧) មនុស្សសត្វតែងជាប់ជំពាក់នឹងរូប, សម្លេង, ក្លិន, រស, សម្ផស្ស និង មនោ ដែលជាលោកាមិស (អាមិសសុខ) ។

(១៨) បញ្ញាជនអាចរស់នៅសុខស្ងប់ដោយមិនបាច់មានទ្រព្យ រីឯជនពាលដែលមានទ្រព្យមិនអាចរស់នៅដោយសុខស្ងប់បានឡើយ ។

(១៩) ការរស់នៅ ១០០ ឆ្នាំនៃជនពាលមិនស្មើនឹងការរស់នៅមួយថ្ងៃនៃបញ្ញាជនឡើយ ។

(២០) ធម្មកថិកដែលសំដែងធម្មទេសនាប្រកបដោយរោហាសាស្រ្តប៉ុន្តែមិនប្រតិបត្តិតាមពុទ្ធវចនៈនោះ នឹងមិនបានចំណែកនៃសាមញ្ញផលទេ ប្រៀបដូចជាអ្នកគង្វាលគោដែលបានត្រឹមតែរាប់គោឲ្យថៅហ្វាយដូច្នោះដែរ ។

(២១) បាបជនរមែងសោកស្តាយទាំងក្នុងលោកនេះ និង បរលោកនៅពេលពួកគេទទួលផលនៃកម្មដ៏សៅហ្មងរបស់ខ្លួន ។

(២២) ក្អមគង់ពេញដោយតំណក់ទឹកមួយតក់ៗយ៉ាងណា ជនពាលរមែងពេញដោយអំពើបាបដែលពួកគេបានធ្វើបន្តិចម្តងៗក៏យ៉ាងដូច្នោះដែរ ។

(២៣) បុគ្គលដែលប្រកាន់មាំដោយអាងជាតិកំណើត, អាងទ្រព្យសម្បត្តិ, អាងត្រកូល និង មើលងាយសាច់ញាតិរបស់ខ្លួន រមែងជួបប្រទះសេចក្តីវិនាស ។

(២៤) បុរសមិនមែនសុទ្ធតែជាបណ្ឌិតចេះដឹងសព្វអន្លើទេ ។ ស្រ្តីដែលមានប្រាជ្ញាឆ្នើមក៏អាចហៅថាបណ្ឌិតបានដែរ ។

(២៥) ពេលមិនទាន់ជួបប្រទះទុក្ខលំបាក ជនពាលរមែងយល់ខុសថាបាបមិនឲ្យផល ។

(២៦) ជនពាលតែងប្រញាប់ធ្វើកិច្ចការដែលមិនគួរប្រញាប់ និង រួញរាក្នុងកិច្ចការដែលមិនគួររួញរា ។

(២៧) បណ្ឌិតតែងមិនប្រញាប់ធ្វើកិច្ចការដែលគួរបង្អង់ និង មិនរួញរាក្នុងកិច្ចការដែលមិនគួររួញរា ។

(២៨) បើបុគ្គលមិនចង់មានទុក្ខ ចូរកុំធ្វើបាបទាំងក្នុងទីវាលនិងទីកំបាំង ។

(២៩) បុគ្គលគ្រប់រូបតែងស្រឡាញ់ខ្លួនឯងលើសអ្វីៗទាំងអស់ ។ ដូច្នេះបុគ្គលគ្រប់រូបមិនត្រូវបៀតបៀនអ្នកដទៃឡើយ ។

(៣០) មនុស្សសត្វគ្រប់រូបរមែងត្រេកត្រអាលក្នុងកាមគុណ ព្រោះមិនដឹងទោសនៃកាម ប្រៀបដូចជាត្រីដែលមិនស្គាល់លប មមាចមិនស្គាល់ភ្លើង ។

(៣១) បុគ្គលណាដែលមិនស្មោះត្រង់នឹងប្រពន្ធខ្លួន ហើយបែរជាទៅសេពគប់នឹងស្រីផ្កាមាស ឬប្រពន្ធរបស់អ្នកដទៃ បុគ្គលនោះនឹងជួបសេចក្តីវិនាស ។

(៣២) បុគ្គលគ្រប់រូប មិនគួរបណ្តោយឲ្យពេលវេលា កន្លងហួសទៅអសារឥតការឡើយ ។

(៣៣) បុគ្គលដែលគ្រប់គ្រងជីវិតដោយការមិនប្រមាទរមែងរក្សាទ្រព្យដែលខ្លួនរកបានឲ្យនៅគង់វង្ស ។

(៣៤) បុគ្គលអាក្រក់មាន ៥ ពួកគឺគ្រហស្ថល្មោភកាម មនុស្សខ្ជិលច្រអូសបព្វជិតមិនសង្រួម, បណ្ឌិតគ្មានឧបេក្ខាចិត្ត និង ស្តេចគ្មានវិចារណញ្ញាណ ។

(៣៥) មនុស្សមិនមែនថោកទាប ឬខ្ពង់ខ្ពស់ដោយសារជាតិកំណើត[164]ទេ ប៉ុន្តែមនុស្សថោកទាប ឬខ្ពង់ខ្ពស់ដោយសារទង្វើរបស់ខ្លួន ។

(៣៦) សីលគឺជាកម្លាំង, ជាស្បៀង និង ជាគ្រឿងនាំ ដែលជួយឲ្យអ្នករក្សាសីលសម្រេចបំណង ។

(៣៧) សីលគឺជាស្ពានដ៏រឹងមាំ, ជាក្លិនក្រអូបឈ្ងុយ និង ជាគ្រឿងលាបលម្អដ៏វិសេស ដែលជួយឲ្យអ្នករក្សាសីលល្បីឈ្មោះគ្រប់ទិសទី ។

(៣៨) ចិត្តមានភាពបរិសុទ្ធផូរផង់ពីកំណើត ប៉ុន្តែចិត្តក្លាយជាសៅហ្មងនៅពេលមានឧបក្កិលេសថ្មីចូលមកជ្រៀតជ្រែក ។

(៣៩) សត្វលោកត្រូវចិត្តដឹកនាំ ។

---

164 ចំណុចនេះទាក់ទងនឹងការរើសអើង ប្រកាន់វណ្ណៈ ដែលជនជាតិឥណ្ឌានៅក្នុងវណ្ណៈខ្ពស់ (ព្រាហ្មណ៍, ក្សត្រ, វេស្សៈ) មើលងាយមនុស្សកើតនៅក្នុងវណ្ណៈសូទ្រៈ ឬមនុស្សក្រៅវណ្ណៈ (ចណ្ឌាល) ។

(៤០) មនុស្សដែលអប់រំចិត្តបានល្អហើយ រមែងបានសេចក្តីសុខ ។

(៤១) បុគ្គលដែលបណ្តោយខ្លួនតាមអំណាចចិត្តរមែងជួបការលំបាក ។

(៤២) បុគ្គលគប្បីរក្សាចិត្តរបស់ខ្លួនឲ្យនឹងធឹង ប្រៀបដូចគេរក្សាភាជន៍ឲ្យមានប្រេងពេញជានិច្ច ។

(៤៣) បុគ្គលដែលមានចិត្តសៅហ្មង រមែងជួបទុគ្គតិ ។

(៤៤) បុគ្គលដែលមានចិត្តស្អាតបរិសុទ្ធ រមែងជួបសុគតិ ។

(៤៥) បុគ្គលគួរហាមចិត្តឲ្យវៀរចាកឆ្ងាយពីអារម្មណ៍បាបទាំងឡាយ ។

(៤៦) មន្ទិលជាកិលេសដែលធ្វើឲ្យចិត្តសៅហ្មង ប្រៀបដូចធ្យូងដែលធ្វើឲ្យប្រឡាក់វត្ថុស្អាត ។

## ១៤.២ មន្ទិល ៩ ប្រការ

នៅក្នុងទ្រឹស្តីពុទ្ធនិយម មន្ទិល (ដំណើរសៅហ្មង) ត្រូវបានបែងចែកជា ៩ ប្រការ គឺ ៖

១. កោធៈ (anger) គឺការក្រោធខឹង ។

២. មក្ខៈ (denigration) គឺការបំភ្លេចអំពើល្អរបស់អ្នកដទៃ ។

៣. ឥស្សា (envy) គឺការមានចិត្តច្រណែនឈ្នានីសអ្នកដទៃ ។

៤. មច្ឆរិយៈ (stinginess) គឺកំណាញ់ មិនបរិច្ចាគទានដល់អ្នកដទៃ ។

៥. មាយា (deceit) គឺការលាក់ពុតកំហូច ។

៦. សាថេយ្យៈ (fraud) គឺការនិយាយអួតអាងគ្មានការពិត ។

៧. មុសាវាទ (telling lie) គឺការនិយាយកុហក ។

៨. បាបិច្ឆៈ (one who desires evil) គឺការប្រាថ្នាបាប ឬអំពើអាក្រក់ ។

៩. មិច្ឆាទិដ្ឋិ (wrong-view) គឺការយល់ខុសពីការពិត ។

ប្រសិនបើបុគ្គលណាបណ្តោយឲ្យមន្ទិលណាមួយកើតឡើងក្នុងចិត្ត នោះ

ចិត្តរបស់បុគ្គលនោះនឹងសៅហ្មង ។ ដូច្នេះ បានជាព្រះពុទ្ធទ្រង់ត្រាស់ថា "មន្ទិលជាគ្រឿងសៅហ្មងចិត្ត" ។ ដើម្បីធ្វើចិត្តឲ្យបរិសុទ្ធផូរផង់ បុគ្គលត្រូវទូន្មានចិត្តរបស់ខ្លួនឲ្យវៀរចាកឆ្ងាយពីអារម្មណ៍បាបទាំងឡាយ ត្រូវគ្រប់គ្រងចិត្តឲ្យបានល្អ ប្រៀបដូចពុទ្ធវចនៈថា "ឈ្នះខ្លួនឯងប្រសើរជាងឈ្នះអ្វីៗទាំងអស់"[165] ។ នៅក្នុងធម្មបទគាថាព្រះពុទ្ធបានផ្តល់ការប្រៀបធៀបយ៉ាងលម្អិតថា "សូម្បីបុគ្គលអាចយកជ័យជំនះលើមនុស្សបានរាប់ពាន់នាក់ ក្នុងសង្គ្រាមរាប់ពាន់ដងក៏ដោយ ក៏មិនប្រសើរជាងការឈ្នះលើខ្លួនឯងតែម្នាក់ឡើយ, បុគ្គលអ្នកឈ្នះខ្លួនឯង ឈ្មោះថាជាអ្នកឈ្នះសង្គ្រាមដ៏ប្រសើរបំផុត" ។[166][167]

*

"ថ្វាយបង្គំព្រះពុទ្ធត្រូវព្រះស៊ីម៉ង់ត៍ ថ្វាយបង្គំលោកសង្ឃត្រូវកូនអ្នកស្រុក" ។
(ពាក្យស្លោកបុរាណខ្មែរ)

"មនុស្សម្នាក់ៗគួរទទួលបានការគោរព ប៉ុន្តែមិនគួរមានបុគ្គលណាម្នាក់
ត្រូវបានលើកតម្កើង និង គោរពយ៉ាងងុបងុលនោះឡើយ" ។

***“Everyone should be respected as an individual, but no one idolized.”***
-- Albert Einstein (1879-1955)

***

165 គម្ពីរព្រះត្រៃបិដក សៀវភៅលេខ ៥២ ទំព័រទី ៤៤ (ធម្មបទគាថា សហស្សវគ្គ)។

166 គម្ពីរព្រះត្រៃបិដក សៀវភៅលេខ ៥២ ទំព័រទី ៤៤ (ធម្មបទគាថា សហស្សវគ្គ)។

167 “The greatest of all conquerors is not he who conquers a thousand men a thousand times in battle, but he who conquers his own self.” Dhammapada 103-105

# ១៥. អចសានកថា

ពុទ្ធសាសនាគឺជាមាគ៌ានៃជីវិត និង ជាចរិយាវិទ្យា សម្រាប់ឲ្យមនុស្សក្នុងសង្គមរស់នៅចុះសម្រុងគ្នា ។ លក្ខណៈពិសេសទាំង ២ ប្រភេទនេះធ្វើឲ្យពុទ្ធសាសនា ខុសប្លែកពីសាសនាផ្សេងៗនៅលើពិភពលោក ។ ទីមួយ តួអង្គព្រះពុទ្ធបានប្រកាន់ខ្ជាប់ថា ធម្មវិន័យ គឺជាធម្មជាតុប្រសើរថ្លៃថ្លាលើសព្រះអង្គ មានន័យថាធម្មវិន័យដែលព្រះពុទ្ធទ្រង់បានសម្តែងទុក ប្រសើរជាងអ្វីៗទាំងអស់ ។ ទោះបីព្រះពុទ្ធជាអ្នកបានរកឃើញ និង បង្កើតធម្មវិន័យក៏ដោយ ក៏ព្រះអង្គទ្រង់ស្ថិតនៅក្រោមអំណាចនៃធម្មវិន័យដែរ ពោលគឺ ព្រះអង្គមិនបានយកច្បាប់របស់ព្រះអង្គ មកទ្រាប់អង្គុយដូចជាស្តេច ឬ មេដឹកនាំផ្តាច់ការនៅលើពិភពលោកនោះទេ ។ ទីពីរ ព្រះពុទ្ធគឺជាគ្រូដែលផ្តល់សិទ្ធិ និង សេរីភាពដល់សិស្ស ។ ឧទាហរណ៍ព្រះពុទ្ធទ្រង់មិនដែលបង្គាប់បញ្ជាសាវក ឲ្យជឿគ្រប់សេចក្តីបង្រៀនរបស់ព្រះអង្គឡើយ ។ ព្រះពុទ្ធទ្រង់មិនដែលបង្ខំមនុស្សណាម្នាក់ ឲ្យធ្វើតាមសេចក្តីបង្រៀនរបស់ព្រះអង្គដោយខ្វះការពិចារណាទេ ។ ព្រះអង្គទ្រង់បានបង្រៀនមនុស្សទាំងឡាយ ឲ្យពិចារណាដោយខ្លួនឯង នូវគ្រប់សេចក្តីបង្រៀនរបស់ព្រះអង្គជាមុនសិន ហើយបើឃើញថាពុទ្ធោវាទណាមានប្រយោជន៍សឹមធ្វើតាម ។ ទីបី ព្រះពុទ្ធទ្រង់បានដាស់តឿនឲ្យមនុស្សយកទ្រឹស្តីទាំងឡាយទៅពិសោធ ឲ្យឃើញច្បាស់ដោយខ្លួនឯងសិន មុននឹងចំណាយកម្លាំងកាយ ចិត្ត ពេលវេលា និង ទ្រព្យសម្បត្តិទៅលើជំនឿណាមួយ ។

ព្រះពុទ្ធទ្រង់បានដាស់តឿនមនុស្ស ឲ្យពឹងផ្អែកលើសមត្ថភាពរបស់ខ្លួន ។ ព្រះអង្គទ្រង់បានបង្រៀនមនុស្សគ្រប់រូប ឲ្យខិតខំសិក្សារៀនសូត្រ ក្រេបជញ្ជក់ចំណេះវិជ្ជាពិតសម្រាប់ធ្វើជាមធ្យោបាយជួយខ្លួន ។ ប្រសិនបើគ្មានចំណេះដឹងមូលដ្ឋានទេ ពុទ្ធបរិស័ទមិនអាចអាន ឬស្តាប់យល់គោលបំណងរបស់ព្រះពុទ្ធ ដែល

បញ្ជាក់យ៉ាងច្បាស់ថា ត្រូវយកធម៌របស់ព្រះអង្គទៅពិចារណា ដកពិសោធ និង ប្រតិបត្តិឲ្យបានសម្រេចការត្រាស់ដឹងឡើយ ។ ប្រសិនបើលោកអ្នកមានបញ្ញាភ្លឺថ្លា លោកអ្នកនឹងអាចវាយតម្លៃបានយ៉ាងត្រឹមត្រូវថា គោលគំនិត ឬ មនោគមវិជ្ជារបស់មេដឹកនាំសាសនាណា មានសេចក្តីពិត ឬមិនពិត ។

ទ្រឹស្តីសង្គហធម៌នៅក្នុងព្រះពុទ្ធសាសនា មានអត្ថន័យត្រូវគ្នានឹងសុភាសិតសាកល ឬសម្តីមាសមួយឃ្លាដែលចែងថា "ត្រូវស្រឡាញ់អ្នកជិតខាងរបស់អ្នកឲ្យដូចជាអ្នកស្រឡាញ់ខ្លួនអ្នកដែរ" ។ ព្រះពុទ្ធទ្រង់បានដាស់តឿនពុទ្ធបរិស័ទ ឲ្យយកចិត្តទុកដាក់ទៅលើការសំអាតចិត្តខ្លួន ឲ្យបរិសុទ្ធផូរផង់ ។ មនុស្សដែលមានចិត្តបរិសុទ្ធរមែងមានមេត្តា និង ករុណា ដល់សព្វសត្វ ។ អត្ថន័យនៃពាក្យថា ករុណានៅក្នុងពុទ្ធសាសនា មិនត្រឹមតែមានន័យថាការអាណិតមនុស្ស ឬសត្វប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាណិតធម្មជាតិ និង បរិស្ថាន នៅជុំវិញខ្លួនផងដែរ ។ ប្រសិនបើមនុស្សនាំគ្នាបំផ្លាញបរិស្ថាន ពេលនោះមនុស្ស និង សត្វទាំងអស់នឹងមិនអាចរស់នៅប្រកបដោយសេចក្តីសុខឡើយ ។

ពុទ្ធបរិស័ទគួរយល់ច្បាស់ថា ព្រះពុទ្ធទ្រង់បានបង្រៀនមនុស្សឲ្យពឹងលើវិចារណញ្ញាណរបស់ខ្លួន ។ ចំណុចនេះមានន័យថា មនុស្សគ្រប់រូបត្រូវតែប្រើវិចារណញ្ញាណ មុននឹងយកគំនិត ឬ ទ្រឹស្តីណាមួយទៅអនុវត្ត ។

យើងដឹងហើយថា នៅក្នុងការផ្សព្វផ្សាយធម្មវិន័យ ព្រះពុទ្ធទ្រង់បានប្រើសន្តិវិធីជានិច្ច ។ ព្រះអង្គទ្រង់មិនដែលប្រើអំណាច, ការប្រណាំងប្រជែង ឬការបង្គាប់បញ្ជា ដើម្បីអូសទាញមនុស្សឲ្យដើរតាមព្រះអង្គឡើយ ។ ប្រសិនបើបរិស័ទមិនយល់ច្បាស់ ឬមិនយល់ស្របតាមឱវាទរបស់ព្រះអង្គទេ, ពួកគេអាចជំទាស់ ឬ តស៊ូមតិដើម្បីរកឲ្យឃើញសច្ចធម៌ ។ បរិស័ទមានសិទ្ធិក្នុងការរក្សាគំនិតដើមរបស់ខ្លួន ឬ ទទួលយកឱវាទរបស់ព្រះអង្គ នៅពេលពួកគេបានពិចារណាឱវាទទាំងនោះ

គ្រប់ជ្រុងជ្រោយរួចហើយ ។

រួមសេចក្តីមក ព្រះពុទ្ធទ្រង់ជាមនុស្ស ប្រកបដោយបញ្ញាគុណ វិសុទ្ធគុណ ករុណាគុណ និង ជាមគ្គុទ្ទេសក៏ដ៏ឈ្លាសវៃ ។ គុណសម្បត្តិ និង ប្រាជ្ញារបស់ព្រះអង្គ បានធ្វើឲ្យទស្សនវិទូនៅបស្ចិមប្រទេសចាប់អារម្មណ៍ខ្លាំង រហូតពួកគេបានថ្វាយព្រះនាមព្រះអង្គថា "មហាបុរសដ៏មានបេះដូង ពេញដោយប្រាជ្ញាញាណ" (168) ។

តើសាសនាដទៃ មានទ្រឹស្តីដូចជាឱវាទរបស់ព្រះពុទ្ធឬទេ ? តើសាសនាទាំងនោះផ្តល់សិទ្ធិ សេរីភាព ដល់បរិស័ទរបស់ពួកគេដូចព្រះពុទ្ធបានធ្វើចំពោះបរិស័ទរបស់ទ្រង់ឬទេ ? តើសាសនាទាំងនោះមានទ្រឹស្តីអរិយសច្ចៈដូចពុទ្ធសាសនាឬទេ? ការសិក្សាប្រៀបធៀបទ្រឹស្តីរបស់សាសនាទាំងឡាយ បានបង្ហាញថាសាសនាទាំងនោះ គ្មានទ្រឹស្តីដូចជាឱវាទរបស់ព្រះពុទ្ធទេ ។ មេដឹកនាំនៅក្នុងសាសនាទាំងនោះតែងពោលមិនដាច់ពីមាត់ថា គ្រប់ពាក្យពេចន៍នៅក្នុងគម្ពីររបស់សាសនាពួកគេ គឺជាពាក្យសម្តីរបស់ព្រះអាទិទេពរបស់ពួកគេ ។ ដូច្នេះគ្មាននរណាម្នាក់អាចកែប្រែពាក្យពេចន៍ណាមួយ នៅក្នុងគម្ពីររបស់ពួកគេឡើយ ។ បរិស័ទនៃសាសនាទាំងនោះជឿយ៉ាងមុតមាំថា ព្រះអាទិទេព, គម្ពីរ និង សាសនារបស់ពួកគេសំខាន់ជាងជីវិតមនុស្ស ។ ចំណែកព្រះពុទ្ធវិញ ទ្រង់បានឲ្យតម្លៃជីវិតមនុស្ស, ជីវិតសត្វ និង បរិស្ថាន យ៉ាងខ្លាំង ។

យើងដឹងហើយថា ព្រះពុទ្ធទ្រង់ជាអ្នកវិចារណនិយម និង វិសោធននិយម ។ ចំណុចពិសេសនៃពុទ្ធសាសនា គឺព្រះពុទ្ធទ្រង់គ្រាន់តែជាអ្នកផ្តល់ផែនទីឲ្យមនុស្សប្រតិបត្តិ ដើម្បីសម្រេចការត្រាស់ដឹង រីឯលទ្ធផល គឺស្រេចលើអ្នកអនុវត្ត ។

ព្រះពុទ្ធទ្រង់បានចំណាយពេលវេលា និង ព្រះកាយពលដើម្បីបង្រៀនមនុស្សឲ្យយល់ច្បាស់នូវទុក្ខ និង មាគ៌ារួចចាកទុក្ខ ។ ដូច្នេះមនុស្សមិនត្រូវយកព្រះ

---

[168] The Intelligent Heart

ពុទ្ធសាសនា ផ្ដើមុខរបរដើម្បីកេងចំណេញខាងផ្នែកសម្ភារៈ និង យសស័ក្តិទេ ។ ទ្រឹស្តីកម្មផលបញ្ជាក់ថា បុគ្គលសាបព្រោះអំពើណា នឹងច្រូតកាត់យកផលផ្លែផ្កានៃអំពើនោះ ។ បុគ្គលម្នាក់ៗទទួលផលនៃកម្មដោយខ្លួនឯង ព្រោះបុគ្គលជាអ្នកសាងកម្មនោះ ។ ទោះបីពុទ្ធសាសនាគ្មានតុលាការ នគរបាល ឬពន្ធនាគារ សម្រាប់ដាក់ទោសជនល្មើសក៏ដោយ ក៏ពុទ្ធសាសនាមានច្បាប់នៃកម្ម ឬទ្រឹស្តីកម្មផល សម្រាប់កាត់ទោសជនល្មើសជានិច្ច ។ បើបុគ្គលណាមិនចង់ឲ្យមានទុក្ខ គេមិនត្រូវសាងបាបទាំងក្នុងទីវាល និង ទីកំបាំង ។ បុគ្គលសាបព្រោះពូជណា រមែងបានផ្លែផ្កានៃពូជនោះវិញ ។ អ្នកធ្វើអំពើល្អនឹងបានផលល្អ អ្នកធ្វើអំពើអាក្រក់នឹងបានផលអាក្រក់ ។

ជាអវសាន សូមជូនពរមិត្តអ្នកអានបានជួបប្រទះពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ និង ពលៈ[169] កុំបីឃ្លៀងឃ្លាតឡើយ ។ សូមព្រះពុទ្ធសាសនាស្ថិតស្ថេរគ្រប់កំណត់ ៥០០០ ព្រះវស្សាដើម្បីជាម្លប់សាខាដល់សព្វសត្វ ។

សូមប្រទេសកម្ពុជាមានសុខសន្តិភាព ប្រាសចាកសឹកសង្គ្រាមជាដរាប ។ សូមប្រជារាស្ត្រខ្មែររួចផុតពីការរើសអើងគ្រប់ប្រភេទ ចៀសផុតពីការបែងចែកវណ្ណៈ ឈប់មានការជិះជាន់កេងប្រវ័ញ្ច និង អំពើអយុត្តិធម៌ក្នុងសង្គម ។

សូមវឌ្ឍនភាព សុខុមាលភាព និង សុភមង្គល កើតមានដល់ប្រជាពលរដ្ឋខ្មែរទូទាំងប្រទេស ។ សូមប្រជារាស្ត្រខ្មែរគ្រប់រូបរួចផុតពីភាពក្រីក្រ រស់នៅចុះសម្រុងគ្នា គោរពសិទ្ធិជាមូលដ្ឋានរបស់មនុស្សគ្រប់រូប និង ចេះជួយសង្គ្រោះគ្នាតាមលទ្ធភាពរបស់ខ្លួន ៕ (ចប់ដោយសន្ទតិ)

---

[169] ព្រះត្រៃបិដក សៀវភៅលេខ ៥២ ទំព័រទី ៤៥ ("អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ" ។ ធម៌ ៤ ប្រការ គឺ អាយុ, វណ្ណៈ, សុខៈ, និង ពលៈ រមែងចម្រើនដល់អ្នកដែលមានសេចក្តីឱនកាយថ្វាយបង្គំ ជាប្រក្រតីមានសេចក្តីកោតក្រែង ដល់បុគ្គលដែលចម្រើនជាងខ្លួនអស់កាលជានិច្ច ។) (សហស្សវគ្គ)

# ១៦. ឯកសារយោង


| ចំណងជើងសៀវភៅ | ឆ្នាំ | អ្នកនិពន្ធ |
|---|---|---|
| Buddha: The Intelligent Heart | 1992 | Alistair Shearer |
| Buddhism | 1961 | Richard A. Gard |
| Buddhism Made Plain | 1985 | Antony Fernando |
| The Foundation of Buddhist Meditation | 1984 | Kalu Rinpoche |
| Introducing Buddha | 1994 | Jane Hope |
| Buddhism (The Basics Series) | 1995 | Herbert Ellinger |
| Hinduism (The Basics Series) | 1996 | Herbert Ellinger |
| Introduction to Zen Buddhism | 1956 | D. T. Suzuki |
| Mindfulness Meditation | 2006 | Miles I. Neales |
| Psychotherapy Without the Self | 2008 | Mark Epstein |
| Religious Giving and the Invention of Karma in Theravada Buddhism | 2002 | James R. Egge |
| The Annihilation of Caste | 1935 | B. R. Ambedkar |
| The Four Noble Truths | 1992 | Ajahn Sumedho |
| The Four Noble Truths | 1994 | Lobsang Gyatso |
| The Light of Asia | 1879 | Sir Edwin Arnold |
| The Path of Purification: Visuddhimagga | 1956 | Buddhaghosa (translated by Nyanamoli) |
| What Buddhist Believe | 2002 | K. Sri Dhammanada |
| What the Buddha Taught | 1974 | Walpola Rahula |
| ការសាកល្បងពិចារណាទ្រឹស្ដីព្រះពុទ្ធសាសនា | 1998 | ឆាយ ឈឿន |
| ច្បាប់ក្រមង៉ុយ | 1955 | ភិរម្យភាសាអ៊ូ (ង៉ុយ) |
| ច្បាប់គោរពមាតាបិតា | 1955 | អ៊ូរ ចុង |
| ជីវិតម៉ែ | 1964 | ប៉ាង ខាត់ |
| បញ្ញានិទ្ទេស | 1942 | ឈឹម ទូច |
| បុណ្យតបគុណមាតាបិតា | 1999 | ភិក្ខុមហា ឃិន នឿន |
| ប្រជុំបុញ្ញប្រវត្តិ | 1968 | ឃិន វន់ |
| ប្រស្នាពុទ្ធប្រវត្តិពិស្ដារ | 1951 | ប៊ូ ប៉ូ |
| ប្រស្នាសង្ខេបនៃពុទ្ធប្រវត្តិ | 1968 | គាំ សូត្រ |

| | | |
|---|---|---|
| បំភ្លឺបុណ្យ | 1990 | ព្រះសង្ឃត្ថេរ អ៊ុម ស៊ុម |
| ពន្លឺអាស៊ីទ្វីប | 1995 | ពុទ្ធសាសនបណ្ឌិត្យ |
| ពុទ្ធប្បវត្តិទូរេនិទាន ពិស្តារ | 1954 | ឱម ណាគ្រី |
| ពុទ្ធសាសនាក្នុងសង្គមប្រជាធិបតេយ្យ | 1971 | ភិក្ខុមហា អ៊ុង មាន |
| ព្រះពុទ្ធជាអ្វី ? | 1997 | ឱម ប៊ុនហ៊ួ |
| ព្រះពុទ្ធសាសនាដូចម្តេច ? | 1970 | ប៉ាង ខាត់ |
| ព្រះរស់ | 1965 | សុង ស៊ីវ |
| សាសនសុភាសិត | 1953 | ពុទ្ធសាសនបណ្ឌិត្យ |
| សាសនាគឺអ្វី ? | 1951 | ម៉ិញ ន៉ាគ្រី |
| ស្រីហិតោបទេស | 1954 | ប៉ាង ខាត់ |
| អត្ថាធិប្បាយសាសនសុភាសិត | 1965 | សែម សូរ |
| អរិយធម៌ខ្មែរ | 1975 | អ្នកស្រី ត្រឹង ងា |
| អវិជ្ជាកថា | 1951 | ភិក្ខុ កៅ ស៊ឹម |
| អានិសង្សសាមសិប | 1969 | ចាប ពិន |
| លោកគ្រូអិកអី | 1953 | កវី សុក បឿ |

*

"ពេលអ្នកនិយាយ អ្នកគ្រាន់តែនិយាយឡើងវិញនូវអ្វីដែលអ្នកបានដឹងប៉ុណ្ណោះ ។
ប៉ុន្តែប្រសិនបើអ្នកស្តាប់ អ្នកអាចនឹងរៀនចេះដឹងរឿងថ្មីទៀត" ។

***"When you talk, you are only repeating what you already know.
But if you listen, you may learn something new."***

--The 14th Dalai Lama (1935-Present)

***

# សេចក្តីជូនដំណឹង

ប្រសិនបើពុទ្ធបរិស័ទត្រូវការសៀវភៅ "ទ្រឹស្តីកម្មផល" ដើម្បីចែកជាធម្មទាន ដល់មហាជនទូទៅ សូមទាក់ទង ៖

១- ភិក្ខុវិនយធរោ **មហា យិន នឿន**
ប្រធានពុទ្ធិកសមាគមខ្មែរ, វត្តសាន់តាអាណា
ក្រុងសាន់តាអាណា, រដ្ឋខាលីហ្វ័រញ៉ា, សហរដ្ឋអាមេរិក
2630 N. Grand Avenue
Santa Ana, CA 92705, USA
ទូរស័ព្ទលេខ (714) 417-8542 / (714) 744-2834

២- លោក **ទ៉ូច គា**
ផ្ទះលេខ ២៥៦ ក្រុមលេខ ៩ ភូមិទួលតាឯក
ឃុំទួលតាឯកស្រុកបាត់ដំបង ខេត្តបាត់ដំបង
ទូរស័ព្ទលេខ 012-726-856

៣- លោក **ហុខ ប៊ូហ៊ិន**
ក្រុងភ្នំពេញ ទូរស័ព្ទលេខ 012-245-476

សូមជម្រាបថា លោកអ្នកអាចទាញយកស្នាដៃរបស់ខ្ញុំទាំងអស់ពីគេហទំព័រ
**www.dhamma4khmer2.org**

| | |
|---|---|
| ព្រះពុទ្ធដីកា | រៀបរៀងនៅ ព.ស. ២៥៥២, គ.ស. 2008 |
| អាមិសទានធម្មទាន | រៀបរៀងនៅ ព.ស. ២៥៥៤, គ.ស. 2010 |
| និព្វានគឺជាអ្វី? | រៀបរៀងនៅ ព.ស. ២៥៥៦, គ.ស. 2012 |
| សត្រូវនៃព្រហ្មចរិយធម៌ | រៀបរៀងនៅ ព.ស. ២៥៥៧, គ.ស. 2013 |
| ពោធិបក្ខិយធម៌ | រៀបរៀងនៅ ព.ស. ២៥៥៨, គ.ស. 2014 |

# ១៧. បញ្ជីរាយនាមសប្បុរសជន

| លរ | គោត្តនាម និង នាម | ថវិកា |
|---|---|---|
| 1. | ឧបាសក ឡូ ប៊ុនឡេង និង ឧបាសិកា អ៊ាប ឆៃគីម | ៥០០ |
| 2. | លោក ពត សុខុម និង អ្នកស្រី កុល មល្លិកា | ៥០០ |
| 3. | លោក ឈួន ចន្ទឆាយា និង អ្នកស្រី សេង សំណាង | ៣០០ |
| 4. | ឧបាសក ឃុន គឹមអៀត និង ឧបាសិកា តូប៊ុនឡាំ | ៣០០ |
| 5. | លោក ឃុន ប៊ូ និង អ្នកស្រី ឃូ សុខលី ព្រមទាំងបុត្រ (កម្ពុជា) | ២០០ |
| 6. | ឧបាសក ង៉ូវ គា និង ឧបាសិកា ឃុន គឹមអេង (កម្ពុជា) | ២០០ |
| 7. | ឧបាសកលឹម គឹមស៊ា, ឧបាសិកាអេង មុយគា ព្រមទាំងគ្រួសារ | ២០០ |
| 8. | លោក នូវ ចន្ទតារា និង អ្នកស្រី អ៊ឹង ស៊ូហ៊្គិច ព្រមទាំងគ្រួសារ | ២០០ |
| 9. | ឧបាសក ហុង កុកហ៊្វឺរ និង ឧបាសិកា ហុង ទីសាម៉ុន | ២០០ |
| 10. | ភិក្ខុ មី ឡៃម | ២០០ |
| 11. | ភិក្ខុ សៀង ឡេង | ១៥០ |
| 12. | ឧបាសក នូ សំបាន និង ឧបាសិកា នូ សំបូរ | ១៥០ |
| 13. | ភិក្ខុ យិន នឿន | ១០០ |
| 14. | អ្នកស្រី មួង រ៉ូម៉ានី ព្រមទាំងបុត្រ (កម្ពុជា) | ១០០ |
| 15. | ឧបាសក ជាម គឹមឈាង និង ឧបាសិកា ពឹង ប៊ុនយី (កម្ពុជា) | ១០០ |
| 16. | ឧបាសក លឹម រ ស៊ាង | ១០០ |
| 17. | ឧបាសក ព្រាប ហុក និង ឧបាសិកា ឈួន ភោគ ហៅ ស៊ីណាត | ១០០ |
| 18. | លោក ខៀវ ស៊ីណារេត និង អ្នកស្រី វ៉ាន់ នីសា | ១០០ |
| 19. | លោក សៅ សាត និង អ្នកស្រី ហង្ស សុខលីន ព្រមទាំងបុត្រី | ១០០ |
| 20. | ឧបាសិកា តែ ហ៊្គិចណៃ ព្រមទាំងបុត្រ | ១០០ |
| 21. | លោក សែម ប៊ុនហេង និង អ្នកស្រី សារ សុន្ទារី ព្រមទាំងបុត្រ | ១០០ |

| | | |
|---|---|---|
| 22. | លោក លឹម គឹមស៊ាន និង អ្នកស្រី ង៉ូវ វេងណាង | ១០០ |
| 23. | លោក ង៉ូវ វេងអាង | ១០០ |
| 24. | ឧបាសិកា ឈុន យ៉េន ព្រមទាំងបុត្រ | ១០០ |
| 25. | លោក រស់ សឿន និង អ្នកស្រី រស់ ពុទ្ធា | ១០០ |
| 26. | ឧបាសិកា ស៊ូ ហាច ព្រមទាំងគ្រួសារ | ១០០ |
| 27. | ឧបាសិកា យឹម លឹម ព្រមទាំងបុត្រ | ៥០ |
| 28. | លោក សូ វីថា និង អ្នកស្រី អ៊ួង លក្ខណា | ៥០ |
| 29. | ឧបាសក លី ថុង និង ឧបាសិកា គឹម សាន | ៥០ |
| 30. | កញ្ញា ឡាង សំបូរ (កម្ពុជា) | ៣០ |
| 31. | ឧបាសិកា ហេង ឈាប ព្រមទាំងបុត្រ | ២៥ |
| 32. | អ្នកស្រី អ៊ុល ស្រីមុំញ (កម្ពុជា) | ២០ |

សូមសប្បុរសជនទាំងអស់ទទួលផលានិសង្ស ដែលកើតឡើងពីធម្មទាននេះ ដោយចិត្តប្រាមោទ្យជ្រះថ្លា ។ លោកអ្នកប្រាថ្នាយ៉ាងណា សូមឲ្យបានសម្រេចដូចបំណង ។ សូមសិរីសួស្តី ជ័យមង្គល វិបុលសុខ មហាប្រសើរ កើតមានដល់លោកអ្នកទាំងអស់ជានិច្ចនិរន្តរ៍ រហូតអវសានកាល ។

*

"ចំពោះរាល់ទង្វើនីមួយៗ នឹងមានប្រតិកម្មប្រឆាំងតបវិញស្មើគ្នា ។"

***"To every action there is always opposed an equal reaction."***

– Isaac Newton (1642-1726)

***

# សព្វទានំ ធម្មទានំ ជិនាតិ
# ធម្មទានឈ្នះអស់ទានទាំងពួង

**The gift of Dhamma surpasses all other gifts.**

“ សូម្បីបុគ្គលអាចយកជ័យជំនះលើមនុស្ស បានរាប់ពាន់នាក់
ក្នុងសង្គ្រាមរាប់ពាន់ដងក៏ដោយ ក៏មិនប្រសើរជាងការឈ្នះលើខ្លួនឯង
តែម្នាក់ឡើយ ។ បុគ្គលអ្នកឈ្នះខ្លួនឯង ឈ្មោះថាអ្នកឈ្នះ
សង្គ្រាមដ៏ប្រសើរបំផុត ” ។

“ ចិត្ត ជាធម្មជាតិបរិសុទ្ធ ផូរផង់ពីកំណើត តែចិត្តនេះ កាលណាមាន
ឧបក្កិលេសឬឹចូលទៅ ទើបសៅហ្មង ” ។

**“ ចិត្តេន នីយតិលោកោ**
សត្វលោកត្រូវចិត្តដឹកនាំ ” ។

លោកថា “ គឺចិត្តនេះហើយ ដែលបុគ្គលទូន្មានបានដោយកម្រ ” ។

## រូបំ ជីរតិ មច្ចានំ នាមគោត្តំ ន ជីរតិ

“ រូបកាយរលត់រលាយទៅ កេរ្តិ៍ឈ្មោះគង់នៅជិតរសាយ
ល្អឬអាក្រក់ឮរែងឆ្ងាយ គួរស្តាយខំសាងអំពើល្អ ” ។

**ស្រមីចបីយ៉ាច :**

ស្រវឹងទ្រព្យភ្លេចបុណ្យ ស្រវឹងប្រពន្ធភ្លេចម្តាយ ស្រវឹងកាយភ្លេចចាស់